ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ប្រាសាទព្រះវិហារ
- ការកាត់ទោសពីការបង្អត់អាហារ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១០៣ ខែកក្កដា ឆ្នាំ២០០៨

# ស្វែងរកការពិត

លេខ១០៣ ខែកក្កដា ឆ្នាំ២០០៨


## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ ប្រាសាទព្រះវិហារ ....................................................................... ១

**ផ្នែកឯកសារ**

◆ បដិវត្តន៍ដើម្បីរស់ ....................................................................... ២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ កាលប្បវត្តិសំខាន់ៗរបស់តុលាការខ្មែរក្រហម ................................. ៤

◆ ការពិត ការរៀបរាប់ និងនយោបាយដើម្បីការបង្រួបបង្រួម .................. ១៦

◆ ពិធីរំឭកខួបកំណើតបដិវត្តន៍កម្ពុជា ................................................ ២៤

◆ របាយការណ៍ពីខេត្តពោធិ៍សាត់ ..................................................... ២៩

**ផ្នែកច្បាប់**

◆ សេចក្តីសង្ខេបលើកិច្ចប្រជុំ ........................................................... ៣៥

◆ សេចក្តីប្រកាសព័ត៌មានលើសំណុំរឿង កាំង ហ្គិចអ៊ាវ ............................ ៣៩

◆ សេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះអំពី ................................. ៤១

◆ បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹង ................................. ៤២

**វេទិកាពិភាក្សាសាធារណៈ**

◆ ការកាត់ទោសពីការបង្អត់អាហារ ................................................... ៤៦

◆ ការព្យាយាមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ......................................... ៥១

**ទំព័រស្រាវជ្រាវរកក្រួសារ**

◆ វាលពិឃាតនៅព្រៃខ្មោច ............................................................. ៥៤

◆ រស់នៅជាស្ត្រីមេម៉ាយ .................................................................. ៦០




បុគ្គលិកមជ្ឈមណ្ឌលពន្យល់ណែនាំហាកិម-តួនអំពីការបំពេញពាក្យបណ្តឹង



សកម្មភាពអ្នកភូមិកំពុងអានទស្សនាវដ្តីស្វែងរកការពិត


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នេរលេខនេះ :** អាឡិច ហ៊ីន គុន, សារ៉ា ថូម៉ាស់, ជី ទេរិទ្ធិ, រ៉េនដល ដឺហ្វាល់កូ, ចារ៉េត វ៉ាត់ឃីន, ដេ. សូឡូមិន បាស៊ី, សូ សារឿន និង ប៊ាង ពីរីន
**អ្នកនិពន្ធនិងស្រាវជ្រាវ :** គាត លក្ខិណា, សោម ប៊ុនថន **អ្នកបកប្រែ:** ដា ផល្លា **និពន្ធនាយកទូទៅ:** ឆាំង យុ **ជំនួយការនិពន្ធនាយក:** ទេព ម៉េងឃាន
**ក្រាហ្វិកកុំព្យូទ័រ:** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ:** ឆេង វេង Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ ៖*

# ប្រាសាទព្រះវិហារ

ក្នុងនាមជាប្រាសាទបុរាណមួយដ៏អស្ចារ្យ ប្រាសាទព្រះវិហារ គឺកម្រមានការសិក្សាណាស់និងមិនមានការសិក្សាទាល់តែសោះ ដោយបុរាណវិទូនិងអ្នកប្រវត្តិសាស្ត្រខ្មែរ ។ ក្នុងខណៈពេលនេះ ប្រាសាទព្រះវិហារបានក្លាយទៅជាសម្បត្តិវប្បធម៌ពិភពលោក បុរាណវិទូបរទេសនឹងព្យាយាមបង្កើតគម្រោងស្រាវជ្រាវផ្សេងៗ ដើម្បីសិក្សាអំពីប្រាសាទនេះ បើទោះបីជាមានឬមិនមានដៃគូជនជាតិកម្ពុជាក៏ដោយ ។

យុវជនយុវនារីខ្មែរបច្ចុប្បន្ន និងអ្នកជំនាន់ក្រោយចាំបាច់គួរតែផ្តោតការសិក្សាទៅលើប្រាសាទព្រះវិហារនិងប្រាសាទបុរាណដទៃទៀតដែលនៅតាមបណ្តោយព្រំប្រទល់ព្រំដែនកម្ពុជា-ថៃ និងវៀតណាម ។ ការសិក្សានេះគឺជាការបង្កើនការយល់ដឹងដល់សាធារណជនកម្ពុជាស្តីអំពីប្រាសាទព្រះវិហារ ដែលជាកន្លែងដ៏ពិសិដ្ឋរបស់ខ្មែរ កសាងឡើងដោយបុព្វមហាក្សត្រខ្មែរដើម្បីឧទ្ទិសដល់ព្រះសិវៈនៃសាសនាហិណ្ឌូ ។

បញ្ហាប្រាសាទព្រះវិហារសព្វថ្ងៃនេះ បានឆ្លុះបញ្ចាំងអំពីការព្រួយបារម្ភចំពោះការបង្កើនសមត្ថភាពចំណេះដឹងនៅក្នុងប្រទេសរបស់យើង និងការស្រាវជ្រាវរួមគ្នារវាងអ្នកស្រាវជ្រាវកម្ពុជានិងថៃ ។ កន្លងមកនេះ ខ្ញុំបានជួបបុរាណវត្ថុវិទូនិងអ្នកប្រវត្តិសាស្ត្រសិក្សាពីសម័យបុរាណដែលជាជនជាតិខ្មែរតែពីរបីនាក់ប៉ុណ្ណោះ ។ ចំណែកឯចំណេះដឹងរបស់អ្នកស្រាវជ្រាវជនជាតិថៃស្តីអំពីជីវភាពខ្មែរនិងសំណង់សម័យបុរាណ គឺមានការឈានមុខជាងខ្មែរយើងជាខ្លាំង ។ អ្នកសិក្សាស្រាវជ្រាវថៃបានធ្វើការសិក្សាយ៉ាងច្រើនក្នុងរយៈពេលប្រមាណ២០ទៅ៣០ឆ្នាំចុងក្រោយនេះដោយបានសិក្សានៅភីម៉ៃ ភ្នំរូង និងការសិក្សាអំពីសំណង់ប្រាសាទបុរាណជាច្រើនកន្លែងផ្សេងទៀត សូម្បីតែកន្លែងតូចៗក៏ដោយ ។ ខ្ញុំសង្ឃឹមថា និស្សិតកម្ពុជាជំនាន់ក្រោយនឹងធ្វើការសិក្សាអំពីប្រាសាទព្រះវិហារនិងសិក្សាស្រាវជ្រាវលើប្រាសាទនានាដទៃទៀត ហើយដែលគួរតែគេចផុតអំពីការស្រាវជ្រាវបែបបារាំងនិងឥទ្ធិពលបរទេសដទៃទៀតក្នុងរយៈពេល១០០ឆ្នាំចុងក្រោយនៃការសិក្សាស្រាវជ្រាវវត្ថុបុរាណនៅក្នុងស្រុករបស់យើង ។

ការសិក្សា និងស្វែងយល់អំពីតម្លៃនៃប្រាសាទនានាគឺជាការស្តារឡើងវិញនូវអត្តសញ្ញាណជាតិខ្មែរទាំងមូល ។ **ឆាំង យុ**





# បដិវត្តន៍ដើម្បីរស់

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើង ការដឹកនាំនិងការគ្រប់គ្រងប្រទេសត្រូវបានផ្លាស់ប្តូរទាំងស្រុង ដែលធ្វើឲ្យប្រជាជននៅគ្រប់ភូមិឃុំទាំងអស់គ្មាននរណាម្នាក់ហ៊ានជំទាស់ឬប្រឆាំងនឹងបញ្ជារបស់អង្គការដែលបានចាត់តាំងឡើយ ។ ដូច្នេះទើប ឡេង ដែលរស់នៅឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង បានសម្រេចចិត្តចូលធ្វើបដិវត្តន៍តាំងពីអាយុ១៣ឆ្នាំ ដោយសារតែខ្លាចខ្មែរក្រហមយកទៅសម្លាប់ ។

ភូមិទាហានក្រោមគឺជាតំបន់មួយត្រូវបានកងទ័ពខ្មែរក្រហមចូលមកកាន់កាប់តាំងពីឆ្នាំ១៩៧៣ ។ ពេលនោះ ស្ថានភាពក្នុងភូមិក៏ចាប់ផ្តើមច្របូកច្របល់ ដោយខ្មែរក្រហមបានទៅធ្វើការឃោសនាឲ្យយុវជននិងយុវនារីចូលបដិវត្តន៍ ។ ក្រោយពីសម្រេចចិត្តឈប់រៀនមកជួយធ្វើការឪពុកម្តាយ ឡេង ក៏បានចូលកងកុមារតាមការឃោសនានេះ ។ *«បើប្រកែកមិនចូល អង្គការនឹងរករឿងថាគេចវេះ ហើយអាចត្រូវយកទៅសម្លាប់ចោលទៀត»* ។ អង្គការបានចាត់តាំង ឡេង ឲ្យទៅមើលក្របីដែលមានគ្នា១០នាក់ ក្នុងចំណោមនោះមានប្រុស៨នាក់និងស្រី២នាក់ ដោយម្នាក់ៗមានតួនាទីមើលថែទាំក្របីមួយនឹម ក្រោមការទទួលខុសត្រូវរបស់ប្រធានកងឈ្មោះ ម៉ៅ ជាអ្នកភូមិកសាង និងគណៈឃុំ ឈ្មោះ តាមី ជាអ្នកភូមិសាមគ្គី ។ ឡេង ត្រូវឃ្វាលគោចាប់ពីម៉ោង៩ឬម៉ោង១០ព្រឹក រហូតដល់ម៉ោង៦ល្ងាច ទើបអាចត្រឡប់មកផ្ទះបានជាធម្មតា ព្រោះនៅមិនឆ្ងាយប៉ុន្មានពីទីកន្លែងស្នាក់នៅ ។ នៅឆ្នាំ១៩៧៥ ឡេង បានឃើញព្រឹត្តិការណ៍គួរឲ្យរន្ធត់មួយ ដោយពូជីដូនមួយរបស់គាត់ឈ្មោះ អេង (សព្វថ្ងៃបាត់ខ្លួន) និងមនុស្សប្រហែល១០នាក់ផ្សេងទៀតត្រូវបានអង្គការចងបណ្តើរយកទៅសម្លាប់ ។

នៅឆ្នាំ១៩៧៦ ឪពុកម្តាយរបស់ ឡេង ព្រួយបារម្ភពីអាយុជីវិតរបស់គាត់យ៉ាងខ្លាំង ក្រោយពីអង្គការប្រាប់ថា ឈ្មោះរបស់ ឡេង ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅភ្នំពេញ ។ *«ខ្ញុំខ្លាចតែបញ្ជូនទៅរហូតមិនត្រឡប់មកវិញទេ»* ។ ក្រោយពីរៀបចំអីវ៉ាន់រួច រថយន្តប្រហែលជា២០គ្រឿងបានមកដឹក ឡេង និងមនុស្សដែលមានអាយុស្របាលៗនឹង ឡេង ជាច្រើននាក់ទៀតធ្វើដំណើរចេញពីទន្លេបិទទៅអ្នកលឿង ។

**ការងារនៅតាខ្មៅ**

ធ្វើដំណើរអស់រយៈពេលជាច្រើនម៉ោង រថយន្តបានបើកមកដល់តាខ្មៅដែលជាកន្លែងចិញ្ចឹមសត្វ ដែលនៅទីនេះមានបែងចែកជាផ្នែកចិញ្ចឹមសត្វក្រពើ ត្រី និងសត្វគ្រប់ប្រភេទផ្សេងទៀត ។ ឡេង ស្ថិតនៅក្នុងក្រុមដែលមានគ្នា១០នាក់ មានភារកិច្ចចិញ្ចឹមសត្វមាន់និងជ្រូកចាប់ពីព្រឹកព្រលឹមរហូតដល់ម៉ោង៩យប់ ។ ក្រោយសម្រាកពីការងារ ឡេង ត្រូវទៅចូលរួមប្រជុំតាមក្រុមដើម្បីរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន ។ ឡេង សម្គាល់ឃើញថា កិច្ចប្រជុំនេះអង្គការមិនដែលលើកសរសើរថាធ្វើការងារបានល្អទេ តែងតែធ្វើការរិះគន់វិញថា *«ធ្វើការមិនសកម្ម មិនស្វាហាប់ ខ្ជិលច្រអូសណាស់»* ។ ជាក់ស្តែង ដូចជា អង្គការបានវាយធ្វើបាបកុមារម្នាក់ ក្រោយពីកសាងចំនួនពីរលើកមិនស្តាប់ ក្រោយមកក៏ចាប់កុមារនោះដាក់លើរថយន្តបញ្ជូនទៅបាត់ ។



បុគ្គលិករបស់មជ្ឈមណ្ឌលកំពុងសម្ភាសន៍ជាមួយអ្នកភូមិនៅខេត្តក្រចេះ

**ការងារនៅច្រាំងចំរេះ**

បីខែក្រោយមក ឡេង ត្រូវបានផ្លាស់ឲ្យទៅធ្វើការនៅប្រាំង ចំរេះព្រែកញ្ញែវិញក្រោមការគ្រប់គ្រងរបស់ តាស ជាប្រធានពាណិជ្ជកម្ម ។ ពេលនោះ ឡេង គិតថាគាត់ប្រាកដស្លាប់មិនខាន ព្រោះអ្នកដែលផ្លាស់ទៅភាគច្រើនមិនដែលបានត្រឡប់មកវិញទេ ។ ពេលទៅដល់ អង្គការបានចាត់តាំង ឡេង ឲ្យដាំបន្លែនិងចិញ្ចឹមសត្វដូចមុន ។ ប៉ុន្តែការងារនេះរវល់ជាងកន្លែងមុន ព្រោះត្រូវធ្វើការស្ទើរតែគ្មានពេលឈប់សម្រាក លើកលែងតែឈឺប៉ុណ្ណោះ ។ ឡេង រៀបរាប់ថា «ប្រសិនបើឈឺមិនធ្ងន់ធ្ងរទេ ក្រោយពីឲ្យពេទ្យពិនិត្យនិងលេបថ្នាំហើយត្រូវទៅធ្វើការទៀត ដែលធ្វើឲ្យរាងកាយរបស់ប្រជាជនឡើងស្គមស្គាំងដោយសារការហូបមិនគ្រប់គ្រាន់និងការធ្វើការហួសកម្លាំង» ។ ដូច្នេះ ទោះបីជាឈឺធ្ងន់ក៏ដោយ ក៏ ឡេង ត្រូវក្រោកទៅធ្វើការដែរដើម្បីកុំឲ្យអង្គការស្តីបន្ទោស ។

នៅទីនេះ រយៈពេលប្រហែលជាមួយខែ ឡេង តែងតែឃើញ តាស ចុះមកត្រួតពិនិត្យការងារម្តង ប៉ុន្តែ គាត់មិនដែលបាននិយាយឆ្លើយឆ្លងអ្វីជាមួយនឹង តាស ទេ ។

### ការងារនៅរោងចក្របកផ្លែគ

នៅឆ្នាំ១៩៧៧ តាស ក៏បានផ្លាស់ ឡេង ឲ្យមកធ្វើការនៅរោងចក្របកផ្លែគនៅតាខ្មៅវិញ ។ នៅទីនេះ ឡេង ត្រូវរៀនបណ្តើរនិងធ្វើការអនុវត្តផ្ទាល់បណ្តើរពីរបៀបពត់ដែក គ្រីបសំឡីគ របៀបការពារកុំឲ្យមានគ្រោះថ្នាក់និងសរសៃរស្វាកលើផលិតផលក្រោមការបង្ហាត់បង្រៀនរបស់ វឿន ជាប្រធានក្រុម ។ រយៈពេលបីខែក្រោយមក ទើប ឡេង អាចធ្វើការទាំងនេះបានស្ទាត់ហើយត្រូវបានចាត់តាំងឲ្យនៅក្នុងក្រុមទទួលបន្ទុកខាងគ្រីបសំឡីគ ដែលមានសមាជិកចំនួន៧នាក់ ។ ការងារនេះ ឡេង មិនសូវទទួលរងនូវការលំបាកប៉ុន្មានទេ ព្រោះអង្គការមិនបានកំណត់ចំនួនគឺធ្វើអាស្រ័យទៅលើសំឡីដែលមាន ។ ប៉ុន្តែ ភាគច្រើន ឡេង អាចគ្រីបបានចំនួន១០០គីឡូស្មើនឹងចំនួនមួយបាវក្នុងមួយថ្ងៃ ។ ក្រោយពីគ្រីបហើយ សំឡីទាំងនេះត្រូវដឹកយកទៅបញ្ចូលក្នុងទូររទេះភ្លើងហើយស្តុកទុកក្នុងឃ្លាំងដើម្បីដឹកទៅប្រទេសចិន ។ ក្រៅពីការងារទាំងនេះ ឡេង ត្រូវទៅយកផ្លែគនៅកំពង់ផែ(ម្តុំមាត់ទឹកផ្សារចាស់)យាមនៅពេលយប់ដើម្បីត្រួតពិនិត្យផ្លែគដែលដឹកចេញ និងចូលរួមប្រជុំអំពីបញ្ហាដែលនាំឲ្យមានការគ្រីបដាច់ដែកដាច់ខ្សែនិងវិធីការពារកុំឲ្យមានបញ្ហានេះកើតឡើងម្តងទៀត ។

ចាប់តាំងពីចាកចេញពីផ្ទះមក ឡេង មិនដែលបានសុំការអនុញ្ញាតពីអង្គការទៅលេងផ្ទះទេ ព្រោះគាត់ធ្លាប់ឃើញសំណើរបស់អ្នកដែលធ្វើការជាមួយគាត់ត្រូវបាន តាស បដិសេធជាច្រើនលើក ។

### ត្រឡប់មកផ្ទះកំណើត

ក្រោយពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ឡេង បានរត់គេចខ្លួនទៅខេត្តតាកែវ ។ រយៈពេលប្រហែលមួយខែក្រោយពីទទួលបានសំបុត្រតាមរយៈអ្នកលក់ដូរដែលម្តាយចិញ្ចឹមរបស់ ឡេង ផ្ញើឲ្យ ឪពុករបស់គាត់បានមកយកគាត់ត្រឡប់ទៅរស់នៅខេត្តស្វាយរៀងវិញ ។ ពេលមកដល់ផ្ទះ ឡេង ស្ទើរតែមិនអាចចំណាំមុខបងប្អូននិងសាច់ញាតិរបស់ខ្លួនបាន ព្រោះតែបែកពីគ្នាអស់រយៈពេលជាច្រើនឆ្នាំ ។ ឡេង យល់ថា ការបម្រើបដិវត្តន៍របស់គាត់មិនបានទទួលលទ្ធផលអ្វីទាំងអស់ គឺមានតែវិប្បដិសារីប៉ុណ្ណោះ ព្រោះដោយសារតែបដិវត្តន៍នេះហើយទើបធ្វើឲ្យបងប្រុសរបស់គាត់បាត់ខ្លួនរហូតដល់សព្វថ្ងៃ ។

ចុងក្រោយ ឡេង គិតថា មានតែតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមប៉ុណ្ណោះទើបអាចរកយុត្តិធម៌ជូនក្រុមគ្រួសារគាត់ក៏ដូចជាប្រជាជនទាំងមូលបាននិងទុកជាប្រវត្តិសាស្ត្រឲ្យកូនចៅជំនាន់ក្រោយបានដឹងផង ។ **គាត លក្ខិណា**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ ព្រឹក និងម៉ោង៧:០០-៧:៣០ ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# កាលប្បវត្តិសំខាន់ៗរបស់តុលាការខ្មែរក្រហម

**(តពីលេខមុន)**

◆ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤ ឧបនាយករដ្ឋមន្ត្រី ស ខេង យល់ស្របចំពោះការបង្កើតគណៈកម្មាធិការពិសេសមួយ ដើម្បីធានាសុវត្ថិភាពអ្នកចូលរួមក្នុងសាលាក្តី ។ គណៈកម្មាធិការនេះនឹងត្រូវដឹកនាំដោយរដ្ឋលេខាធិការក្រសួងមហាផ្ទៃ លោក ឯម សំអាន និងអនុប្រធានជាច្រើនរូបទៀតរួមមាន លោក មៅ ចាន់ដារ៉ា អគ្គនាយករងនគរបាលជាតិ លោក ប៉ុល សារឿន មេបញ្ជាការរងកងយោធពលខេមរភូមិន្ទ លោក នេត សាវឿន អគ្គនាយករងនគរបាលជាតិ និង លោក នៅ សំ នាយសេនាធិការរងនៃកងយោធពលខេមរភូមិន្ទ ។ គណៈកម្មាធិការពិសេសនេះក៏មានតំណាងម្នាក់មកពីក្រសួងហិរញ្ញវត្ថុ និងតំណាងអភិបាលខេត្ត-ក្រុង ព្រមទាំងសាក្សីនិងជនសង្ស័យរស់នៅទីនោះចូលរួមផងដែរ ។

◆ នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៤ ព្រះរាជអាជ្ញាមកពីខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប ព្រងើយកន្តើយចំពោះដីកាសាលាឧទ្ធរណ៍ដែលឲ្យចាប់ខ្លួនមេដឹកនាំខ្មែរក្រហម លោក ខៀវ សំផន និង នួន ជា ។ លោក យ៉ឹម យ៉េត ព្រះរាជអាជ្ញាខេត្តបាត់ដំបងបាននិយាយថា គាត់បានទទួលដីកានៅថ្ងៃទី៩ ខែមេសា រួចហើយ ប៉ុន្តែគាត់មិនទាន់ធ្វើសកម្មភាពទេ ។ មានតែចៅក្រម ពិសេសរបស់សាលាក្តីខ្មែរក្រហម និងអន្តរជាតិប៉ុណ្ណោះដែលអាចចេញដីកាចាប់ខ្លួនបាន ។ លោក សូ វ៉ា ព្រះរាជអាជ្ញាខេត្តសៀមរាបក៏បានអះអាងដែរថា គាត់បានទទួលដីកាពីអគ្គព្រះរាជអាជ្ញាហើយ ប៉ុន្តែគាត់ខ្វះភ័ស្តុតាងដែលជាឯកសារប្រឆាំងនឹងអតីតមេដឹកនាំទាំងនោះ និងនីតិវិធីស៊ើបអង្កេតពួកគេ ។ លោក ឱម យិនទៀង ទីប្រឹក្សានាយក រដ្ឋមន្ត្រី ហ៊ុន សែន និងជាអនុប្រធានក្រុមការងាររៀបចំសាលាក្តីបាននិយាយថា គាត់មានការភ្ញាក់ផ្អើលពេលសាលាឧទ្ធរណ៍សម្រេចចេញដីកាខណៈដែលអ្នកច្បាប់គណបក្សប្រឆាំងលោក សុន ឆៃ បានតវ៉ាថា មន្ត្រីរដ្ឋាភិបាលបានគាបសង្កត់ព្រះរាជអាជ្ញាខេត្តមិនឲ្យចាប់អតីតមេដឹកនាំខ្មែរក្រហម ។ ព្រះរាជអាជ្ញាទាំងនោះគួរតែត្រូវពិន័យ ដោយសារពួកគេមិនគោរពតាមការបញ្ជារបស់អគ្គព្រះរាជអាជ្ញា ។

◆ នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៤ នាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា តុលាការកម្ពុជាមិនមានយុត្តាធិការចេញបញ្ជាឲ្យចាប់ខ្លួនអតីតមេដឹកនាំខ្មែរក្រហមទេ ប៉ុន្តែមានតែសាលាក្តីគាំទ្រដោយអង្គការសហប្រជាជាតិប៉ុណ្ណោះទើបមានអំណាចនាំពួកគេមកកាត់ទោសបាន ។ គ្មានការចាប់ខ្លួនត្រូវបានធ្វើឡើងទេរហូតដល់សាលាក្តីត្រូវបានបង្កើត ។ ការធ្វើសច្ចាប័ននៃសាលាក្តីនឹងក្លាយជារបៀបវារៈដំបូងសម្រាប់រដ្ឋសភាជាតិដែលទើបបង្កើតថ្មី ។ គាត់បានថ្លែងថា គាត់មិនព្រួយបារម្ភថា លោក ខៀវ សំផន ឬលោក នួន ជា នឹងព្យាយាមគេចពីសាលាក្តីទេ ។ អ្នកទាំងពីរមិនដឹងថា ត្រូវគេចទៅកន្លែងណាឡើយ ។ គាត់នឹងប្រឈមមុខក្នុងសាលាក្តី ។ ការចំណាយប៉ាន់ស្មាននៃការកាត់ទោសខ្មែរក្រហមឥឡូវនេះអស់ជាង ៦០លានដុល្លារ ច្រើនជាងការប៉ាន់ស្មានដំបូង១០លានដុល្លារ ។ សមាជិកការិយាល័យរដ្ឋបាលសាលាក្តីអ្នកស្រី ហេលែន ចារីស បានអះអាងថា ការចំណាយប៉ាន់ស្មានឥឡូវអស់ជាង៦០លាន-ដុល្លារ ហើយអាចនឹងពិភាក្សានិងត្រួតពិនិត្យឡើងវិញដោយអ្នកផ្តល់ជំនួយសំខាន់ដែលមានរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ។

◆ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៤ ប្រទេសអូស្ត្រាលីសន្យាផ្តល់ទឹកប្រាក់៥លានដុល្លារអូស្ត្រាលីទៀតសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ បន្ថែមលើទឹកប្រាក់១លាន៥សែនដុល្លារអូស្ត្រាលីដែលបានប្រកាសកាលពីពេលមុន ។ ទឹកប្រាក់សរុប៣លានដុល្លារអូស្ត្រាលី (២លាន ២សែនដុល្លារអាមេរិក) ត្រូវបានបន្ថែមលើប្រាក់២៦៦.០០០ដុល្លារអូស្ត្រាលីដែលបានផ្តល់ជាជំនួយបច្ចេកទេសទាក់ទងការកាត់ក្តីរួចហើយ ។

◆ នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០០៤ ឯកឧត្តម ស៊ាន វិសុទ្ធ ប្រធានការិយាល័យរដ្ឋបាលសាលាក្តីខ្មែរក្រហមរបស់រាជរដ្ឋាភិបាលកម្ពុជានិយាយថា ក្រុមការងារអង្គការសហប្រជាជាតិដែលដឹកនាំដោយលោក ខាស្តែន ហ៊ែរែល នឹងមកដល់កម្ពុជានៅថ្ងៃទី២៣ ខែសីហា ដើម្បីប៉ាន់ប្រមាណពីថវិកាសាលាក្តី ។ លោកបានបន្ថែមទៀតថា ការកាត់ក្តីត្រូវបានរំពឹងថានឹងចំណាយអស់ទឹកប្រាក់៧លានដុល្លារ ហើយការចំណាយចុងក្រោយនឹងត្រូវដោះស្រាយជាមួយប្រទេសជាម្ចាស់ជំនួយ ឬក្រុមប្រទេសដែលចាប់អារម្មណ៍ ។

◆ នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៤ គណៈរដ្ឋមន្ត្រីបានយល់ស្របចំពោះសេចក្តីព្រាងច្បាប់ពីរ គឺទីមួយៈ វិសោធនកម្មច្បាប់ឆ្នាំ២០០១ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ ទីពីរៈ ការឲ្យសច្ចាប័នកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដែលបានចុះហត្ថលេខានៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ។

វិសោធនកម្មដែលត្រូវបានយល់ព្រម គឺមានគោលបំណងដើម្បីភាពចុះសម្រុងរវាងច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀងហើយវាឆ្លុះបញ្ចាំងពីកិច្ចព្រមព្រៀងដែលស្នើដោយលោក ហាន់ កូរ៉ែល នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៣ ។ បន្ថែមពីលើនេះ ការពង្រីកលក្ខន្តិកៈនៃដែនកំណត់ក្រោមមាត្រា៣ ត្រូវបានស្នើឡើងឲ្យផ្លាស់ប្តូរពី២០ឆ្នាំ ទៅ៣០ឆ្នាំ ។

◆ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៤ ចៅក្រម និងព្រះរាជអាជ្ញាចំនួន៣០រូប ដែលជ្រើសរើសដោយក្រុមប្រឹក្សានៃអង្គចៅក្រមចាប់ផ្តើមបើកវគ្គបណ្តុះបណ្តាលពីរសប្តាហ៍ ស្តីពីច្បាប់មនុស្សធម៌អន្តរជាតិនៅឯសាលាភូមិន្ទចៅក្រម ។ យោងតាមសេចក្តីថ្លែងការណ៍ពីកម្មវិធីអភិវឌ្ឍ អង្គការសហប្រជាជាតិដែលជួយដល់វគ្គបណ្តុះបណ្តាលចៅក្រមនិងព្រះរាជអាជ្ញានឹងត្រូវបានណែនាំពីបញ្ហាដែលរួមមានឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការកាត់ទោសដោយយុត្តិធម៌ និងដំណើរការដោយរលូន ។

◆ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៤ គណៈកម្មការនីតិកម្មរបស់រដ្ឋសភាជាតិប្រគល់ទៅឲ្យក្រុមការងារសាលាក្តីនូវសេចក្តីព្រាងច្បាប់សម្រាប់បង្កើតសាលាក្តីជាមួយនឹងការរិះគន់ពីខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ។ ប្រធានគណៈកម្មការ ឯកឧត្តម ឯក សំអុល មានប្រសាសន៍ថា សេចក្តីព្រាងច្បាប់មានកំហុសជាច្រើន ហើយតម្រូវឲ្យមានការផ្លាស់ប្តូរជាច្រើនដែរ ។ ប៉ុន្តែប្រធានការងាររដ្ឋបាល លោក ស៊ានវិសុទ្ធ បាននិយាយថា កំហុសទាំងនោះជាកំហុសអក្ខរាវិរុទ្ធដែលអាចដោះស្រាយបានដោយងាយ ។ គណៈកម្មាធិការគ្រាន់តែសុំឲ្យកែកំហុសអក្ខរាវិរុទ្ធខ្លះប៉ុណ្ណោះ ។

◆ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៤ បន្ទាប់ពីការប្រកាសការត្រឡប់មកវិញរបស់គណៈប្រតិភូអង្គការសហប្រជាជាតិដើម្បីរៀបចំថវិកានិងភ័ស្តុភារសម្រាប់សាលាក្តី មន្ត្រីរដ្ឋាភិបាលបានលុបចោលទស្សនកិច្ចរបស់ក្រុមអង្គការសហប្រជាជាតិ ។ ទស្សនកិច្ចនេះត្រូវបានពន្យារពេលរហូតដល់រដ្ឋសភាជាតិផ្តល់សច្ចាប័នលើច្បាប់សម្រាប់បង្កើតសាលាក្តី ។ ទីប្រឹក្សារបស់នាយករដ្ឋមន្ត្រី លោក ឱម យិនទៀង បាននិយាយថា ក្រុមនេះនឹងត្រូវអញ្ជើញឲ្យត្រឡប់មកវិញនៅពេលសេចក្តីព្រាងច្បាប់ត្រូវបានអនុម័ត ។ គាត់បានបន្ថែមថា “ខ្ញុំគិតថាការពន្យារពេលមិនមែនជាការខ្ជះខ្ជាយពេលវេលាទេ” ។

◆ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៤ នាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា កម្ពុជានឹងមិនរួមចំណែកសម្រាប់ការកាត់ក្តីអតីតមេដឹកនាំខ្មែរក្រហមដែលពន្យារពេលដ៏យូរនោះទេ ។ ឆាប់ៗនេះនឹងមានការជជែកពីថវិកា ។ ខ្ញុំចង់និយាយថា កម្ពុជាអាចផ្តល់ឲ្យតែសាលប្រជុំ បង់ថ្លៃទឹកភ្លើង និងកងសន្តិសុខប៉ុណ្ណោះ ។ ពួកគេមិនអាចសុំឲ្យកម្ពុជាចំណាយសម្រាប់សាលាក្តីទេ ។ បើអ្នកចង់ឲ្យមានសាលាក្តីអ្នកត្រូវចំណាយ ។ គាត់បានមានប្រសាសន៍បន្ថែមថា យើងត្រូវតែច្បាស់លាស់លើរឿងនេះ ។ កម្ពុជាអាចដំណើរការកាត់ក្តីបាន ប៉ុន្តែពួកគេនិយាយថា ពួកគេមិនជឿថាកម្ពុជាអាចផ្តល់នូវយុត្តិធម៌បានទេ ។

◆ នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៤ រដ្ឋមន្ត្រីក្រសួងការបរទេស លោក ហោ ណាំហុង មានប្រសាសន៍ថា លោក កូហ្វី អាណាន់ បានសុំឲ្យរាជរដ្ឋាភិបាលកម្ពុជាផ្ញើលិខិតមួយទៅអង្គការសហប្រជាជាតិ បន្ទាប់ពីផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងអង្គការសហប្រជាជាតិដើម្បីឲ្យគាត់ស្នើ ឬរៀបចំការប្រជុំជាមួយម្ចាស់ជំនួយដើម្បីស្វែងរកថវិកាគាំទ្រសាលាក្តី ។ អគ្គលេខាធិការអង្គការសហប្រជាជាតិបានប្រាប់អ្នកយកព័ត៌មានថា ផ្ញើអ៊ីមែលទើបអង្គការសហប្រ

ជាជាតិស្វែងរកអ្នកផ្តល់ជំនួយសម្រាប់ប្រាក់ប្រមាណជា៥០លានដុល្លារដែលត្រូវការដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។

◆ នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៤ សមាជិក១០៧រូបនៃរដ្ឋសភាជាតិក្នុងចំណោម១២៣រូបបានបោះឆ្នោតផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាស្តីពីការកាត់ទោសក្រោមច្បាប់កម្ពុជា ពីព្រោះឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់ពីការបោះឆ្នោត នាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា "អ្វីដែលយើងបានរង់ចាំដ៏យូរនោះបានកើតឡើងនៅថ្ងៃនេះហើយ" ។

ក្នុងសន្និសីទកាសែតមួយនៅមុខរដ្ឋសភាជាតិបន្ទាប់ពីការប្រជុំផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសថាគាត់នឹងឲ្យមន្ត្រីរដ្ឋាភិបាលនិងប្រជាជនកម្ពុជាឈប់សម្រាកមួយថ្ងៃនៅថ្ងៃដែលសាលាក្តីខ្មែរក្រហមបើកសវនាការដំបូង ។ ការប្រកាសនេះត្រូវបានធ្វើឡើងដើម្បីជាការឆ្លើយតបទៅនឹងសំណូមពររបស់លោក ឆាំង យុ ដើម្បីបង្កើតជាថ្ងៃនៃការចងចាំនិងយុត្តិធម៌ ។

លិខិតមួយច្បាប់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្ញើទៅលោក កូហ្វី អាណាន់ ស្តីពីការយល់ព្រមរបស់រដ្ឋសភាជាតិលើសេចក្តីព្រាងច្បាប់ដែលឯកភាពលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាអំពីការកាត់ទោសក្រោមច្បាប់កម្ពុជាចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។

◆ នៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៤ សមាជិក៩៦រូបក្នុងចំណោមសមាជិក៩៨រូបនៃរដ្ឋសភាជាតិបោះឆ្នោតយល់ព្រមចំពោះការធ្វើវិសោធនកម្ម២៩មាត្រានៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់ការកាត់ទោសឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ មាត្រាទាំង ២៩ នោះរួមមានមាត្រា ២ ៣ ៩ ១០ ១១ ១៤ ១៧ ១៨ ២០ ២១ ២២ ២៣ ២៤ ២៧ ២៩ ៣១ ៣៣ ៣៤ ៣៥ ៣៦ ៣៧ ៣៩ ៤០ ៤២ ៤៣ ៤៤ ៤៥ ៤៦ និងមាត្រា៤៧ ។ វិសោធនកម្មជារួមពឹងផ្អែកលើទិដ្ឋភាពបច្ចេកទេសនៃតុលាការពិសេសដូចជា រចនាសម្ព័ន្ធ យុត្តាធិការនិងនីតិវិធី ។

◆ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ពីរសប្តាហ៍បន្ទាប់ពីធ្វើជាអធិបតីក្នុងការផ្តល់សច្ចាប័នកិច្ចព្រមព្រៀងនិងវិសោធនកម្មមាត្រានៃឧបញ្ញត្តិដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ប្រធានរដ្ឋសភា សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ប្រាប់ចោលថវិកាសម្រាប់សាលាក្តី ដោយមានព្រះរាជបន្ទូលថា ថវិកាគ្រោងនោះគួរតែចំណាយលើការអភិវឌ្ឍវិស័យកសិកម្មរបស់ប្រទេសប្រសើរជាង ។ ព្រះអង្គមានព្រះបន្ទូលប្រាប់អ្នកយកព័ត៌មាននៅក្រៅរដ្ឋសភាជាតិថា "បើសិនខ្ញុំមានប្រាក់៥៥លានដុល្លារ ខ្ញុំនឹងយកប្រាក់នោះទៅអភិវឌ្ឍប្រទេសវិញ ។ វាមានប្រយោជន៍ជាងការកាត់ទោសមេដឹកនាំចាស់ៗនៃរបបខ្មែរក្រហម ។ វាមានយុត្តិធម៌ពីរប្រភេទ គឺយុត្តិធម៌សម្រាប់ជនរងគ្រោះ និងយុត្តិធម៌សម្រាប់ជនក្រីក្រ ។ ប្រាក់៥០លានដុល្លារគឺច្រើនខ្លាំងណាស់" ។ ព្រះអង្គបានបន្ថែមថា "តើយើងអាចដឹកប្រឡាយបានប៉ុន្មានជាមួយនឹងប្រាក់ទាំងនោះ" ។

◆ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៤ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាដែលយល់ព្រមដោយរដ្ឋសភាជាតិនៅថ្ងៃទី២៤ ខែតុលា ត្រូវបានប្រកាសដោយប្រមុខរដ្ឋស្តីទី សម្តេច ជា ស៊ីម ។

◆ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៤ ក្រុមប្រឹក្សាធម្មនុញ្ញបានយល់ស្របចំពោះការកែប្រែច្បាប់ស្របតាមរដ្ឋធម្មនុញ្ញ ។

◆ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ច្បាប់ខ្មែរក្រហមដែលបានធ្វើវិសោធនកម្មនឹងយល់ព្រមដោយរដ្ឋសភាជាតិនៅថ្ងៃទី៥ ខែតុលា ត្រូវបានប្រកាសដោយប្រមុខរដ្ឋស្តីទី សម្តេច ជា ស៊ីម ។

◆ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជាចេញសេចក្តីថ្លែងការណ៍មួយប្រកាសបញ្ចប់ការងារផ្នែកច្បាប់សម្រាប់សាលាក្តី ។

◆ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ឧបនាយករដ្ឋមន្ត្រី សុខ អាន ផ្ញើលិខិតមួយច្បាប់ទៅអគ្គលេខាធិការរងនិងទីប្រឹក្សាផ្នែកច្បាប់នៃអង្គការសហប្រជាជាតិ លោក នីកូឡា មីសែល ដើម្បីណែនាំគាត់ថា យោងតាមមាត្រា៣២នៃកិច្ចព្រមព្រៀង តម្រូវការផ្នែកច្បាប់ដើម្បីឲ្យកម្ពុជាប្រើប្រាស់អំណាចត្រូវបានគោរពតាម ។

◆ នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៤ នាយករដ្ឋមន្ត្រី ហ៊ុន សែន សម្តែងក្តីព្រួយបារម្ភថា ការមិនស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិដើម្បីចំណាយសម្រាប់សាលាក្តីនឹងពន្យារពេល ហើយដំណើរការយូរនេះអាចធ្វើឲ្យអតីតមេដឹកនាំខ្មែរក្រហមស្លាប់មុនពេលកាត់ក្តី ។ លោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ពេលធ្វើបុណ្យខួបរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាថ្ងៃទី២ធ្នូ ថា ឥឡូវនេះយើងមានច្បាប់សម្រាប់កាត់ទោសខ្មែរក្រហម ប៉ុន្តែអង្គការសហប្រជាជាតិថ្លែងថាពួកគេមិនមានថវិកា ។ គាត់បានបន្ថែមថា ប្រជាជននិងខ្ញុំព្រួយបារម្ភថា អតីតមេដឹកនាំខ្មែរក្រហមនឹងស្លាប់មុនពេលកាត់ក្តី ។ នេះជាក្តីបារម្ភរបស់យើង ។ ថវិកាជាបន្ទុករបស់អង្គការសហប្រជាជាតិ ។

◆ នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០០៥ នាយករដ្ឋមន្ត្រី ហ៊ុន សែន សុំឲ្យសហគមន៍អន្តរជាតិផ្តល់ជំនួយដល់ប្រទេសដែលត្រូវបានបំផ្លិចបំផ្លាញដោយរលកស៊ូណាមីនៅថ្ងៃទី២៦ ខែធ្នូ ដោយមិនទាន់កាត់ទោសមេដឹកនាំខ្មែរក្រហម ។ លោកនាយករដ្ឋមន្ត្រីមានប្រសាសន៍ថា «ចំនួនប្រជាជនដែលស្លាប់ដោយស៊ូណាមីមានចំនួនតិចជាង១០ភាគរយ បើប្រៀបធៀបនឹងការខូចខាតនិងចំនួនមនុស្សស្លាប់នៅក្នុងរបបខ្មែរក្រហម» ។ លោកបន្ថែមទៀតថា «គ្មាននរណាម្នាក់ចង់យកខ្មែរក្រហមទៅកាត់ទោសជាង ហ៊ុន សែន ទេ» ។

◆ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៥ សម្តេចនរោត្តម សីហនុ មានព្រះរាជបន្ទូលថា ការកាត់ទោសមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យមួយក្តាប់តូចគ្រាន់តែជា «រឿងកំប្លែងនិងការលាក់ពុត» ប៉ុណ្ណោះ ព្រោះបានចំណាយអស់ជាង៥៦លានដុល្លារអាមេរិក ដើម្បីបង្កើតតុលាការ ហើយការ «ជួយឧបត្ថម្ភក្នុងរយៈពេលបីឆ្នាំ អាចធ្វើឲ្យចៅក្រមមានជីវភាពខ្ពង់ខ្ពស់» ។ ព្រះអង្គស្នើថា វាប្រហែលជាមានយុត្តិធម៌ជាង ប្រសិនយើងអាចផ្តល់ដីដែលមានជីជាតិនិងប្រព័ន្ធផ្លូវទឹកទៅឲ្យគ្រួសាររបស់ជនរងគ្រោះក្នុងរបបខ្មែរក្រហម ។ ព្រះអង្គបានសរសេរនៅលើគេហទំព័ររបស់ទ្រង់ថា «ខ្ញុំដឹងថាការផ្តន្ទាទោសមេដឹកនាំខ្មែរក្រហមដោយប្រើប្រាស់អង្គជំនុំជម្រះរបស់កម្ពុជានិងអង្គការសហប្រជាជាតិអាចធ្វើឲ្យខ្ញុំមានអារម្មណ៍ធូរស្រាល» ។

◆ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៥ សម្តេច សីហនុ រំឭកថា គួរតែកាត់ទោសការបះបោរប្រឆាំងនឹងរដ្ឋាភិបាលរបស់អតីតខ្មែរក្រហមផង ប្រសិនបើមានការកាត់ទោសដោយអង្គជំនុំជម្រះដែលមានការផ្តល់ជំនួយពីអង្គការសហប្រជាជាតិ ។

◆ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៥ ប្រទេសអង់គ្លេសប្រកាសថានឹងផ្តល់ជំនួយ៩៨ម៉ឺនដុល្លារអាមេរិកទៅឲ្យអង្គជំនុំជម្រះ ។

◆ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៥ នាយករដ្ឋមន្ត្រី ហ៊ុន សែន ជំរុញឲ្យអ្នកផ្តល់ជំនួយជាតិឆាប់ផ្តល់មូលនិធិទៅឲ្យអង្គជំនុំជម្រះមុនពេលមេដឹកនាំខ្មែរក្រហមដែលមានវ័យចំណាស់ស្លាប់បាត់បង់ជីវិត ។

◆ នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៥ ជប៉ុនតាំងចិត្តថានឹងផ្តល់ថវិកា ២១,៥លានដុល្លារអាមេរិក ទៅឲ្យអង្គជំនុំជម្រះតាមរយៈអង្គការសហប្រជាជាតិនៅចុងខែមីនា ។

◆ នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០០៥ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ ដែលជាលេខាផ្ទាល់ខ្លួនរបស់សម្តេចនរោត្តម សីហនុ តាំងចិត្តថានឹងប្តឹងរដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង ដើម្បីស្វែងរកការស្លាប់របស់ព្រះមាតាបិតាទ្រង់ ពេលដែលតុលាការខ្មែរក្រហមត្រូវបង្កើតឡើង ។ ដើម្បីបង្ហាញចម្ងល់ទៅកាន់អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលចំពោះអង្គជំនុំជម្រះដែលប្រជាជនទន្ទឹងរង់ចាំជាយូរណាស់មកហើយ ព្រះអង្គម្ចាស់ ធម្មិកោ មានព្រះរាជបន្ទូលថា ទ្រង់ចង់ស្វែងរកយុត្តិធម៌អំពីការស្លាប់របស់ព្រះមាតាបិតាព្រះអង្គ គឺព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មេថាវី និងព្រះនាង ណាណែត មេថាវី ដែលជាបងស្រីរបស់ម្ចាស់ក្សត្រី នរោត្តម មុនីនាថ ។

◆ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៥ ចៅក្រមស៊ើបអង្កេតរបស់តុលាការយោធាកម្ពុជានិយាយថា តាម៉ុក និង កាំង ហ្គិចអ៊ាវ ហៅ ឌុច ត្រូវបានចោទប្រកាន់នៅខែកុម្ភៈ ពីបទឧក្រិដ្ឋកម្មសង្គ្រាមនិងការធ្វើទុកបុកម្នេញលើជនជាតិបរទេសនៅអំឡុងឆ្នាំ១៩៧៥ ដល់១៩៧៩ ។

◆ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៥ រដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង ឆ្លើយតបនឹងសេចក្តីថ្លែងការណ៍របស់ព្រះអង្គម្ចាស់

ធម្មិកោ ដោយរំពឹងថា លោកនឹងទាមទារសំណងជាប្រាក់ដ៏ច្រើន សន្ធឹកសន្ធាប់ចំពោះពាក្យបណ្តឹងដែលប្តឹងគាត់នៅក្នុងតុលាការដែលនឹងមាននៅខាងមុខ ។ ចំពោះសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ព្រះអង្គម្ចាស់ ធម្មិកោ ក្នុងការតាំងចិត្តដាក់ពាក្យប្តឹងប្រឆាំងលោករដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង លោកបានប្រាប់អ្នកសារព័ត៌មានថា អ្នកដែលមានបំណងប្តឹងលោកពីករណីនេះ សុំត្រៀមប្រាក់ដើម្បីបង់ជាសំណងឲ្យហើយទៅ ។

◆ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៥ លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជានិយាយថា «មកដល់សព្វថ្ងៃនេះ រដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិមានប្រាក់គ្រប់ចំនួនដើម្បីចំណាយសម្រាប់អង្គជំនុំជម្រះនៅឆ្នាំដំបូង ការប៉ាន់ស្មានទឹកប្រាក់មានចំនួន ៥៦លានដុល្លារអាមេរិក ក្នុងនោះមានប្រាក់ចំនួន ៣៩លានដុល្លារដែលជាជំនួយមកពីប្រទេសជប៉ុន អូស្ត្រាលី ចក្រភពអង់គ្លេស និងបារាំង» ។ លោកអំពាវនាវឲ្យមានជំនួយនិងការជួយគាំទ្រពីសហគមន៍អន្តរជាតិដើម្បីធ្វើឲ្យអង្គជំនុំជម្រះដែលប្រជាជនរង់ចាំជាយូរណាស់មកហើយក្លាយទៅជាការពិត ។ គាត់និយាយថា «ខ្ញុំសង្ឃឹមថាសហគមន៍អន្តរជាតិនឹងចាប់ផ្តើមជួយដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្សនៅអាស៊ីខ្លាំងក្លាជាងមុន ដូចជានៅអឺរ៉ុបនិងអាហ្វ្រិក» ។ «ការជួយប្រជាជនកម្ពុជាដើម្បីស្វែងរកយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលប្រព្រឹត្តនៅក្នុងទឹកដីរបស់ខ្លួន គឺជារឿងប្រវត្តិសាស្ត្រមួយ» ។

◆ នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៥ យោងទៅតាមលោក រួម រិត អ្នកសរសេរលិខិតឆ្លើយឆ្លងជាមួយសម្តេច សីហនុ បានឲ្យដឹងថា សម្តេច សីហនុ ដែលបានដាក់រាជ្យមានព្រះរាជបន្ទូលថា ទ្រង់នឹងផ្តល់ប្រាក់ចំនួន១ម៉ឺនដុល្លារជំនួសព្រះអង្គម្ចាស់ស៊ីសុវត្ថិ ធម្មិកោ ប្រសិនបើរដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង ប្តឹងព្រះអង្គម្ចាស់ពីបទបរិហារកេរ្តិ៍ ។

◆ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥ ប្រទេសកាណាដាប្រកាសថានឹងផ្តល់លុយ២លានដុល្លារកាណាដា (១,៦៨លានដុល្លារអាមេរិក) ទៅឲ្យអង្គការសហប្រជាជាតិដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយចំណាយ១លានដុល្លារកាណាដាទៅលើប្រតិបត្តិការនៅឆ្នាំដំបូង និង៥សែនដុល្លារកាណាដានៅឆ្នាំទីពីរនិងទីបី ។

រដ្ឋាភិបាលកម្ពុជាប្រកាសថា មានតែ១,៥លានដុល្លារអាមេរិកក្នុងចំនួនថវិកា១៣,៣ដុល្លារដែលបានរំពឹងទុក ដូច្នេះត្រូវតែស្នើសុំមូលនិធិបន្ថែមពីប្រទេសដែលចាប់អារម្មណ៍លើបញ្ហានេះ ដើម្បីបំពេញលើការខ្វះខាត១១,៨លានដុល្លារទៀត ។ ទីប្រឹក្សាជាន់ខ្ពស់របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន លោក ឱម យិនទៀង មានប្រសាសន៍ថា ប្រទេសកម្ពុជានឹងទទួលខុសត្រូវថវិកាចំនួន៦,៧លានដុល្លារ ប៉ុន្តែសន្តិសុខនិងអ្វីផ្សេងៗទៀតដែលមិនរួមបញ្ចូលក្នុងថវិកានេះគឺជាការព្រួយបារម្ភ ។

◆ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៥ ប្រទេសជាសមាជិករបស់អង្គការសហប្រជាជាតិសន្យាថានឹងផ្តល់ថវិកា៣៨,៤៨លានដុល្លារដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូច្នេះ ខ្វះថវិកា៤,៥២លានដុល្លារ ទើបគ្រប់គោលដៅ៤៣លានដុល្លារ ។ ប្រទេសដែលសន្យានោះរួមមាន ៖ ជប៉ុន ២១លាន ៦សែនដុល្លារ, បារាំង ៤លាន ៨សែនដុល្លារ, ចក្រភពអង់គ្លេស ២លាន ៨សែន ៧ម៉ឺនដុល្លារ, អូស្ត្រាលី ២លាន ៣សែន៥ម៉ឺនដុល្លារ, ហូល្លង់ ២លានដុល្លារ, កាណាដា ១លាន ៦សែន ១ម៉ឺនដុល្លារ, ន័រវ៉េស ១លានដុល្លារ, អាល្លឺម៉ង់ ១លានដុល្លារ, ដេនម៉ាក ៥សែន ២ម៉ឺន ៥ពាន់ដុល្លារ, អូទ្រីស ៣សែន៦ ម៉ឺនដុល្លារ, ស៊ុតដែន ១សែន ៥ម៉ឺនដុល្លារ, សាធារណរដ្ឋកូរ៉េ ១សែន ៥ម៉ឺនដុល្លារ, លុចសំបួរ ៦ម៉ឺន ៦ពាន់ដុល្លារ ។

អ្នកតំណាងសហរដ្ឋអាមេរិកមានប្រសាសន៍ថា កាលពីដប់ឆ្នាំមុន សហរដ្ឋអាមេរិកបាន «ចំណាយ៧លានដុល្លារទៅលើថ្លៃស្រាវជ្រាវនិងថ្លៃឯកសារដើម្បីស្វែងរកឧក្រិដ្ឋកម្មនៅក្នុងប្រទេសកម្ពុជា» ដូច្នេះមិនអាចផ្តល់ថវិកាទៅឲ្យអង្គជំនុំជម្រះថែមទៀតទេ» ។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជានិយាយថា គាត់ជឿជាក់ថាវាប្រាកដជាមានការខ្វះខាតខាងថវិកា ដូច្នេះរដ្ឋាភិបាលកម្ពុជាគួរតែពិចារណាសុំឲ្យក្រុមហ៊ុនឯកជននៅក្នុងប្រទេសជួយបំពេញបន្ថែម ។

◆ នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៥ សាលាក្រុងភ្នំពេញបានផ្តល់សិទ្ធិទៅឲ្យក្រុមហ៊ុនជប៉ុនដើម្បីអភិវឌ្ឍនិងគ្រប់គ្រងវាលពិឃាតជើងឯក ។ មន្ត្រីម្នាក់មានប្រសាសន៍ថា «កិច្ចសន្យាបានអនុញ្ញាត

ឲ្យក្រុមហ៊ុនយកបូជនីយដ្ឋានអំពើប្រល័យពូជសាសន៍ជាទិសដៅទេសចរណ៍សម្រាប់រយៈពេល៣០ឆ្នាំ ដោយផ្តល់ប្រាក់១ម៉ឺន៥ពាន់ដុល្លារក្នុងមួយឆ្នាំ ។ ច្បាប់ចម្លងកិច្ចសន្យាដែលយកមកពីអ្នកគ្រប់គ្រងទូទៅនៅវាលពិឃាតជើងឯកត្រូវបានផ្ញើជូនទៅក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់នៅខណ្ឌដង្កោ ដែលកិច្ចសន្យានេះធ្វើឡើងនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៥ ដោយអភិបាលក្រុង កែប ជុតិម៉ា និងអ្នកតំណាងក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់ លោក ខូជី យ៉ាម៉ាតូ ។ អាសយដ្ឋានរបស់ក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់ដែលសរសេរនៅក្នុងកិច្ចសន្យា គឺផ្ទះលេខ៩២ ផ្លូវ១១០ ខណ្ឌទួលគោក ។ ប៉ុន្តែលោកអភិបាលខណ្ឌទួលគោក សេង រតនៈ មានប្រសាសន៍ថា លោកមិនបានដឹងថាមានផ្លូវនេះនៅក្នុងខណ្ឌដែលលោកគ្រប់គ្រងទេ ។ ផ្លូវ១១០ នៅក្នុងខណ្ឌដូនពេញគឺជាអគារផ្ទះល្វែង ។ ប្រជាជនដែលរស់នៅទីនោះនិយាយថា គេមិនដែលឮពីក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់និងអ្នកតំណាងក្រុមហ៊ុនដែលមានឈ្មោះថា ខូជី យ៉ាម៉ាតូ ទេ ។

◆ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៥ ក្រុមប្រឹក្សារដ្ឋមន្ត្រីម្នាក់ដែលបានចុះហត្ថលេខាលើកិច្ចសន្យាដើម្បីអនុញ្ញាតឲ្យក្រុមហ៊ុនយកវាលពិឃាតជើងឯកធ្វើជាកន្លែងទាក់ទាញភ្ញៀវទេសចរណ៍បានមានប្រសាសន៍ថា លោកក៏ជាប្រធានគ្រប់គ្រងក្រុមហ៊ុនម្នាក់ដែរ ។ ក្រុមប្រឹក្សាប្រធានខុទ្ទកាល័យរដ្ឋមន្ត្រី ជា វណ្ណដិត មានប្រសាសន៍ថា លោកបានកំពុងតែធ្វើការនៅក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់ដែលមានទីតាំងនៅប្រទេសជប៉ុនតាំងពីក្រុមហ៊ុននោះទើបតែបង្កើតឡើងបានប្រហែល៧ខែមកម្ល៉េះ ។

◆ នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០០៥ លោក ឆាំង យុ សរសេរលិខិតមួយច្បាប់ផ្ញើទៅនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយស្នើឲ្យលោកលុបចោលកិច្ចសន្យាដែលធ្វើឡើងដោយសាលាក្រុងភ្នំពេញនិងក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់ ដោយនិយាយថា វាលពិឃាតជើងឯកនេះត្រូវបានបង្កើតឡើង២៥ឆ្នាំមកហើយ ដូច្នេះវាគួរតែគ្រប់គ្រងនិងការពារដោយកម្ពុជា ។

អ្នកគ្រប់គ្រងទូទៅនៅវាលពិឃាតជើងឯកនិយាយថា មន្ត្រីនៅឯសាលាក្រុងភ្នំពេញបានសំណូមពរឲ្យលោកឈប់រៀបរាប់ពីគម្រោងលក់បូជនីយដ្ឋានអំពើប្រល័យពូជសាសន៍នៅសម័យខ្មែរក្រហម ។ ការស្រាវជ្រាវតាមអ៊ីនធឺណេតនៅក្នុងគេហទំព័ររបស់ក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់ដែលចុះឈ្មោះនៅក្រុមហ៊ុនអ៊ីអិលជីផ្លាស់ទៅទីក្រុងតូក្យូ មានតែអាសយដ្ឋាននិងលេខទូរស័ព្ទប៉ុណ្ណោះ ហើយអ្នកយាមជាអ្នកឆ្លើយតបទូរស័ព្ទ ។

◆ នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៥ សាលាក្រុងភ្នំពេញនិយាយថា គេមិនញញើតនឹងការរិះគន់ចំពោះការចុះហត្ថលេខាលើកិច្ចសន្យាអនុញ្ញាតឲ្យក្រុមហ៊ុនជប៉ុនគ្រប់គ្រងវាលពិឃាតជើងឯករយៈពេល៣០ឆ្នាំទេ ។

លោក ឆាំង យុ ផ្ញើលិខិតទៅឲ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថា រដ្ឋាភិបាលគួរតែលុបចោលកិច្ចសន្យា ហើយអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាគ្រប់គ្រងលើវាលពិឃាតជើងឯកវិញ ។ លោកនិយាយថា «ខ្ញុំសុំឲ្យលោកនាយករដ្ឋមន្ត្រីពិចារណាទៅលើកិច្ចសន្យាម្តងទៀត ពីព្រោះកិច្ចសន្យានេះនៅមិនទាន់បានបោះត្រានៅឡើយទេ ហើយខ្ញុំគិតថា លោកនាយករដ្ឋមន្ត្រីមិនទាន់បានដឹងពីកិច្ចសន្យានេះនៅឡើយទេ» ។ សាលាក្រុងនិយាយថា ក្រុងភ្នំពេញកំពុងតែអភិវឌ្ឍ... ហេតុអ្វីបានជាក្រុមហ៊ុនឯកជនមិនអាចថែរក្សាវាលពិឃាតជើងឯក?» ។

នៅក្នុងលិខិតផ្ញើឲ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី៥ ខែមេសា លោក ឆាំង យុ មានប្រសាសន៍ថា «ជើងឯកមិនគួរគ្រប់គ្រងដោយក្រុមហ៊ុនឯកជនទេ ប្រទេសមួយគួរតែការពារប្រវត្តិសាស្ត្រដោយខ្លួនឯង គ្មានប្រទេសដទៃណាអាចគ្រប់គ្រងល្អជាងទេ ។ លោកបន្ថែមទៀតថា ប្រាក់ចំណូលដែលបានមកពីភ្ញៀវទេសចរណ៍រាល់ឆ្នាំមានចំនួនច្រើនជាងប្រាក់ដែលក្រុមហ៊ុនផ្តល់ឲ្យទៅទៀត ដូច្នេះជើងឯកមិនគួរលក់ទៅឲ្យក្រុមហ៊ុនឯកជនទេ ។

នៅក្នុងសេចក្តីប្រកាសព័ត៌មាន ក្រុមប្រឹក្សារដ្ឋមន្ត្រីបង្ហាញពីសេចក្តីលម្អិតរបស់កិច្ចព្រមព្រៀងវាលពិឃាតជើងឯកដែលមានការរិះគន់យ៉ាងខ្លាំងថា សាធារណជននៅមិនទាន់បានដឹងពី «រូបភាពពិតប្រាកដ» របស់កិច្ចព្រមព្រៀងនៅឡើយទេ ។ សេចក្តីថ្លែងការណ៍ដែលមិនទាន់ចុះហត្ថលេខារបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីបានឲ្យដឹងថា ការធ្វើកិច្ចព្រមព្រៀងនេះគឺដើម្បី «ការពារនិងអភិវឌ្ឍជើងឯក «ក្នុងគោលបំណងតម្រូវទៅតាមភ្ញៀវទេសចរណ៍ដែលរំពឹងទុកថានឹងកើនឡើងនៅពេលអនាគត» ។ ក្រុមប្រឹក្សារដ្ឋមន្ត្រី

បានអះអាងថា «ទោះបីជាសាលាក្រុងអាចការពារជើងឯកបាន រយៈពេល២៥ឆ្នាំហើយក៏ដោយ ប៉ុន្តែសាលាក្រុងមិនមានលទ្ធភាពដោះស្រាយបញ្ហាទឹកជំនន់ដែលកើតឡើងរាល់ឆ្នាំនិងការថែរក្សាអគារដែលប៉ះពាល់ដល់វាលពិឃាតជើងឯកទេ» ។

លោក ឆាំង យុ ឆ្លើយតបថា លោកនៅមិនទាន់បានឃើញសេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីនៅឡើយទេ យ៉ាងណាមិញសេចក្តីលម្អិតរបស់សេចក្តីថ្លែងការណ៍នេះក៏មិនមានពាក់ព័ន្ធអ្វីដែរ ព្រោះនៅក្នុងកិច្ចសន្យាមិនបាននិយាយអំពីការចុះហត្ថលេខាលក់និមិត្តរូបជាតិទៅឲ្យក្រុមហ៊ុនបរទេសទេ ។ «ដូច្នេះសេចក្តីថ្លែងការណ៍មិនមែនជាចំណុចសំខាន់ទេ ។ ការបង់ចាំមិនអាចធ្វើកិច្ចសន្យាលក់បានទេ» ។

◆ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៥ មន្ត្រីរដ្ឋាភិបាលបដិសេធនឹងក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់ដែលចង់អភិវឌ្ឍផ្លូវទៅកាន់ជើងឯក ។ ការបដិសេធនេះធ្វើឡើងមួយថ្ងៃមុនពេលមានសេចក្តីថ្លែងការណ៍លម្អិតរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលគាំទ្រការសម្រេចចិត្តរបស់រដ្ឋាភិបាលដើម្បីលក់បូជនីយដ្ឋានអំពើប្រល័យពូជសាសន៍ ការស្នើសុំរបស់ក្រុមហ៊ុនពាក់ព័ន្ធនឹងបទបញ្ញត្តិនៃការអភិវឌ្ឍផ្លូវទៅកាន់វាលពិឃាតជើងឯក ។ ប្រធានធនាគារអភិវឌ្ឍអាស៊ី លោក ស៊ីយ៉ាម បាដៃ ផ្តល់ដំណឹងថា ធនាគារលោកបានរៀបចំមូលនិធិដើម្បីអភិវឌ្ឍផ្លូវពីភ្នំពេញទៅកាន់ជើងឯកហើយ ។ លោកនិយាយថា «លោកនៅមិនទាន់ដឹងថាមានអ្នកផ្សេងចង់អភិវឌ្ឍផ្លូវនេះនៅឡើយទេ» ។

◆ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៥ រដ្ឋាភិបាលប៊ែលហ្ស៊ិកសន្យាថានឹងផ្តល់ប្រាក់១៩.៥០០ដុល្លារ ទៅឲ្យតុលាការខ្មែរក្រហមដែលនឹងបង្កើតឡើងនៅថ្ងៃអនាគត ។ ដើរើន ខរមេន នាយករងនៃគណៈកម្មាធិការស្ថានទូតប៊ែលហ្ស៊ិកប្រចាំនៅបាងកក សរសេរអ៊ីមែលថា ប្រទេសប៊ែលហ្ស៊ិកមិនអាចប្រកាសនៅក្នុងសន្និសីទនៅទីស្នាក់ការអង្គការសហប្រជាជាតិកាលពីថ្ងៃ២៨ ខែមីនា បានទេ ពីព្រោះ «ការសម្រេចចិត្តនៅមិនទាន់បានសម្របសម្រួលគ្នាជាផ្លូវការនៅឡើយនៅពេលមានសន្និសីទ» ។

◆ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៥ នៅក្នុងលិខិតផ្ញើទៅឲ្យអភិបាលក្រុងភ្នំពេញ លោក ឆាំង យុ និយាយថា ប្រជាជនកម្ពុជាបានខិតខំការពារបូជនីយដ្ឋានប្រល័យពូជសាសន៍អស់រយៈពេល២៥ឆ្នាំមកហើយការលក់វាទៅឲ្យក្រុមហ៊ុនឯកជនអាចមានផលប៉ះពាល់ទៅដល់ប្រវត្តិសាស្ត្រជាតិ ។

លោក ឆាំង យុ បានស្នើទៅរដ្ឋាភិបាលជប៉ុនដើម្បីបង្ហាញពីទំនាក់ទំនងរបស់ខ្លួនជាមួយនឹងក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល ហើយនឹងបង្ហាញពីអ្វីដែលលោកអភិបាលរងក្រុង ម៉ម ប៊ុននាង និយាយនៅក្នុងកាសែតខេមបូឌាដេលីដែលថា ជប៉ុនប្រហែលជាឈប់ផ្តល់ជំនួយដល់ប្រទេសយើងប្រសិនបើយើងលុបចោលកិច្ចសន្យាលក់វាលពិឃាតជើងឯក ។

ដូនចំពោះលោកអគ្គរាជទូត

នៅក្នុងកាសែតខេមបូឌាដេលីថ្ងៃនេះ លោកអភិបាលរងក្រុងទីមួយលោក ម៉ម ប៊ុននាង បាននិយាយថា «ប្រទេសជប៉ុនប្រហែលជាឈប់ផ្តល់ជំនួយដល់ប្រទេសយើង ប្រសិនបើយើងលុបចោលកិច្ចសន្យាលក់វាលពិឃាតជើងឯក» ។

ការគំរាមកំហែងមិនច្បាស់លាស់នេះធ្លាប់កើតមាននៅក្នុងនយោបាយកម្ពុជា ហើយតែងតែត្រូវបានយកមកប្រើប្រាស់នៅពេលដែលសមាជិករដ្ឋាភិបាលក៏ដូចជាបក្សនយោបាយបម្រុងនឹងធ្វើអ្វីមួយមិនល្អ ។ នៅពេលនេះរដ្ឋាភិបាលជប៉ុនក៏ប្រើមធ្យោបាយនេះដើម្បីបង្ហាញពីមហិច្ឆតារបស់ខ្លួនដែរ ។

ទីមួយ ខ្ញុំសង្ឃឹមថារដ្ឋាភិបាលរបស់លោកនឹងបង្ហាញឲ្យច្បាស់ពីទំនាក់ទំនងជាមួយនឹងក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់ ។ ដូចដែលលោកបានដឹងច្បាស់ហើយថា គ្មាននរណាម្នាក់អាចស្វែងរកក្រុមហ៊ុនឬមន្ត្រីរាជការរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ប្រទេសជប៉ុនឬក៏តាមអ៊ីនធឺណែតបានទេ ។ ដូច្នេះដឹងពីស្ថានភាពរបស់ក្រុមហ៊ុននេះ អាចធ្វើឲ្យប្រជាជនកម្ពុជាអស់ការសង្ស័យបាន ។

ទីពីរ វាប្រាកដជាមានលទ្ធផលល្អ ប្រសិនបើរដ្ឋាភិបាលរបស់លោកបង្ហាញពីទំនាក់ទំនងជាមួយក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់ ។ តើប្រទេសជប៉ុនដែលធ្លាប់ជាម្ចាស់ជំនួយអាចលុបចោលទំនាក់ទំនងជាមួយកម្ពុជាដោយសារតែប្រាក់មួយចំនួនតូចដែលវាលពិឃាតជើងឯករកបាននោះទេ? ហើយប្រសិនបើរដ្ឋាភិបាលរបស់លោកគាំទ្រក្រុមហ៊ុនជប៉ុនឲ្យគ្រប់គ្រងជើងឯកនោះ ខ្ញុំគំណាងឲ្យប្រជាជនកម្ពុជាសង្ឃឹមថា ក្រុមហ៊ុននេះនឹងអនុញ្ញាតឲ្យប្រជាជន

ដែលនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យអាចជួយការពារបូជនីយដ្ឋាននេះដែរ ។

ពី ឆាំង យុ

នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

◆ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៥ មជ្ឈមណ្ឌលឯកសារកម្ពុជាស្នើទៅរដ្ឋាភិបាលដែលមានស្ថានទូតមួយចំនួននៅប្រទេសកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនិងស្ថានទូតមួយចំនួនទៀតប្រចាំនៅទីក្រុងបាងកកដែលបានតាមដានព្រឹត្តិការណ៍ខ្មែរក្រហមថា សូមឲ្យអង្គភាពនិងបុគ្គលទាំងនោះផ្តល់ភ័ស្តុតាងដែលគេមានទៅឲ្យអង្គជំនុំជម្រះ ។ មជ្ឈមណ្ឌលក៏បានថ្លែងអំណរគុណដល់បណ្ឌិត ស៊ីវ ហេដ័រ នៃសាកលវិទ្យាល័យទីក្រុងឡុង និង ដេវីដ ហកអតីតមន្ត្រីនៅការិយាល័យកម្ពុជារបស់អង្គការសហប្រជាជាតិដើម្បីសិទ្ធិមនុស្សដែលបានផ្តល់ឯកសារពាក់ព័ន្ធនឹងខ្មែរក្រហមទៅអង្គជំនុំជម្រះដែលបានគ្រោងទុក ហើយមជ្ឈមណ្ឌលក៏បានសង្ឃឹមថាអ្នកឯទៀតនឹងធ្វើបែបនេះដែរ ។

◆ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៥ ទោះបីជាមានការប្រឆាំងយ៉ាងណាក្តី ក៏ពិធីផ្តល់សិទ្ធិជាផ្លូវការត្រូវបានប្រារព្ធឡើងនៅសាលាក្រុងដែរ ។

◆ នៅថ្ងៃ២១ ខែមេសា ឆ្នាំ២០០៥ ក្រសួងការបរទេសសហរដ្ឋអាមេរិកធ្វើសេចក្តីថ្លែងការណ៍ថា «ខណៈពេលដែលសហរដ្ឋអាមេរិកផ្តល់វិភាគទានដល់ដំណើរការនេះ យើងជឿថា វិធានច្បាប់របស់អាមេរិកនឹងធ្វើឲ្យអង្គជំនុំជម្រះមានបទដ្ឋានយុត្តិធម៌ ។ នៅពេលដែលអង្គជំនុំជម្រះមានដំណើរការទៅមុខ យើងត្រូវតែបង្កើតទំនាក់ទំនងជាមួយរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិព្រមទាំងប្រទេសដែលចាប់អារម្មណ៍ដើម្បីសម្រេចគោលដៅនេះ» ។

◆ នៅថ្ងៃ២២ ខែមេសា ឆ្នាំ២០០៥ រដ្ឋាភិបាលវៀតណាមឆ្លើយតបនឹងការស្នើសុំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីថ្ងៃទី១៧ ខែមេសា ចំពោះភ័ស្តុតាងដែលពាក់ព័ន្ធនឹងខ្មែរក្រហមដោយសរសេរថា «លិខិតរបស់អ្នកនឹងត្រូវបានផ្ញើឲ្យរដ្ឋាភិបាលដែលពាក់ព័ន្ធនៃប្រទេសវៀតណាម ។ ខ្ញុំជឿជាក់ថាគេនឹងចាប់អារម្មណ៍រឿងនេះ» ។

◆ នៅថ្ងៃ២៥ ខែមេសា ឆ្នាំ២០០៥ ដើម្បីឆ្លើយតបនឹងការស្នើសុំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីថ្ងៃទី១៧ ខែមេសា ដែលត្រូវការភ័ស្តុតាងពាក់ព័ន្ធនឹងខ្មែរក្រហម អាល្លឺម៉ង់ផ្ញើឯកសារមកឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ។

◆ នៅថ្ងៃ២៩ ខែមេសា ឆ្នាំ២០០៥ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជាដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឆាប់មានប្រសិទ្ធភាព ។ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៥ អគ្គលេខាធិការអង្គការសហប្រជាជាតិសរសេរលិខិតមួយផ្ញើជូននាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីជម្រាបថា តម្រូវការផ្នែកច្បាប់ខាងប្រទេសរបស់លោកបានរៀបចំរួចរាល់អស់ហើយ ។ យោងទៅតាមមាត្រា៣២នៃកិច្ចព្រមព្រៀងច្បាប់នេះនឹងមានប្រសិទ្ធភាពនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ។ នៅថ្ងៃបន្ទាប់ លោក សុខ អាន បានជូនដំណឹងដល់លោក នីកូឡាមីសេល អំពីតម្រូវការផ្នែកច្បាប់សម្រាប់ប្រទេសកម្ពុជាដែលបានស្នើកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០០៤ ថាបានរៀបចំរួចរាល់ដែរ ។

យោងទៅតាមរបាយការណ៍សារព័ត៌មានរបស់អង្គការសហប្រជាជាតិ កិច្ចសន្យាដែលមានប្រសិទ្ធភាពនិងវិភាគទានបច្ចុប្បន្នតម្រូវឲ្យផ្តល់ប្រាក់ខែដល់បុគ្គលិកជាតិនិងអន្តរជាតិដែលធ្វើការនៅអង្គជំនុំជម្រះ ។

គណៈកម្មាធិការសហភាពអឺរ៉ុបសន្យាថាផ្តល់ប្រាក់១លាន ៣សែនដុល្លារដល់តុលាការខ្មែរក្រហម ។

◆ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៥ កម្ពុជាស្វាគមន៍ចំពោះការប្រកាសរបស់អង្គការសហប្រជាជាតិដែលថាមានថវិកាគ្រប់គ្រាន់នៅក្នុងដៃដើម្បីបង្កើតសាលាក្តី ។

◆ ថ្ងៃទី៦ ខែឧសភា ឆ្នាំ ២០០៥ ប្រទេសបារាំងប្រកាសថានឹងផ្តល់ថវិកាចំនួន១លាន ៣សែនដុល្លារ បន្ថែមនៅឆ្នាំ២០០៥ សម្រាប់ដំណើរការកាត់ទោសសម្រាប់ឆ្នាំ២០០៦ ។ តាមសេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រីក្រសួងការបរទេសបារាំងបានឲ្យដឹងថា «ប្រទេសបារាំងធ្វើបែបនេះ គឺដើម្បីលើកទឹកចិត្តប្រទេសជាដៃគូឲ្យខិតខំប្រឹងប្រែងរកជំនួយនិងថវិកាដែលមានស្រាប់សម្រាប់ចាប់ផ្តើមសវនាការដែលមានរយៈពេល៣ឆ្នាំ» ។

◆ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៥ ជាការឆ្លើយតបនឹងការ

*ស្នើសុំសម្ភារៈដែលទាក់ទងនឹងខ្មែរក្រហមនៅថ្ងៃ១៧ ខែមេសា របស់មជ្ឈមណ្ឌលឯកសារកម្ពុជាចក្រភពអង់គ្លេសបានផ្ញើឯកសារមកឲ្យមជ្ឈមណ្ឌល ។*

◆ *នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៥ រដ្ឋាភិបាលជប៉ុនបង្ហាញពីទំនាក់ទំនងជាមួយក្រុមហ៊ុនដេស៊ីរ៉ូយ៉ាល់ថាៈ*

*១) វាស្រេចទៅលើការសម្រេចចិត្តរបស់អាជ្ញាធរកម្ពុជាថាតើបូជនីយដ្ឋានអំពើប្រល័យពូជសាសន៍ជើងឯកគួរតែថែរក្សាអភិវឌ្ឍនិងគ្រប់គ្រងដោយរបៀបណា បើពិចារណាទៅតាមអារម្មណ៍របស់ប្រជាជនកម្ពុជាចំពោះទីកន្លែងនេះ ។*

*២) រដ្ឋាភិបាលជប៉ុនមិនជាប់ពាក់ព័ន្ធនឹងបញ្ហាផ្តល់សម្បទានការពារ អភិវឌ្ឍនិងគ្រប់គ្រងបូជនីយដ្ឋានអំពើប្រល័យពូជសាសន៍ជើងឯកទេ ។ គ្មានបុគ្គលឬអង្គភាពណាធ្លាប់បានពិគ្រោះពីបញ្ហានេះឡើយ ។*

*៣) ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានខ្លះបានឲ្យដឹងថា ការលុបចោលកិច្ចសន្យាអាចធ្វើឲ្យមានផលប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចរបស់ជប៉ុននិងកម្ពុជា ។ យ៉ាងណាមិញ វាគ្មានការទាក់ទងរវាងគោលនយោបាយរបស់រដ្ឋាភិបាលជប៉ុនទៅលើជំនួយអភិវឌ្ឍកម្ពុជាជាផ្លូវការនិងការធ្វើសម្បទាននេះទេ ដូចដែលបានអះអាងនៅចំណុច១និង២ ។ ការព្យាយាមភ្ជាប់បញ្ហាទាំងពីរនេះជាមួយគ្នាមានលក្ខណៈឥតប្រយោជន៍និងមិនសមស្រប ។*

*៤) រដ្ឋាភិបាលជប៉ុនបានផ្តួចផ្តើមគំនិតនៅក្នុងសហគមន៍អន្តរជាតិ ហើយនឹងបន្តធ្វើទៅមុខទៀតដើម្បីសម្រេចឲ្យបាននូវសន្តិភាពក្នុងប្រទេសកម្ពុជា និងជួយកសាងឡើងវិញ ព្រមទាំងកិច្ចប្រឹងប្រែងកសាងជាតិរបស់ប្រជាជនកម្ពុជា ។ យើងទាំងអស់គ្នាសុទ្ធតែដឹងពីស្លាកស្នាមដែលខ្មែរក្រហមបន្សល់ទុកនៅក្នុងសង្គមកម្ពុជា ដូច្នេះយើងគួរតែគាំទ្រកិច្ចខំប្រឹងប្រែងរបស់ប្រជាជនកម្ពុជាដើម្បីឲ្យមានការទទួលស្គាល់តុលាការខ្មែរក្រហមដែលមានបទដ្ឋានអន្តរជាតិ និងជំរុញវិធានច្បាប់កម្ពុជាបន្ថែមទៀត ។*

◆ *នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ ប្រទេសជប៉ុនបាត់បង់ឱកាសជួយប្រទេសកម្ពុជា*

◆ *នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៥ មជ្ឈមណ្ឌលឯកសារកម្ពុជាស្នើឲ្យរដ្ឋាភិបាលជប៉ុនបង្ហាញពីឥរិយាបថខ្លួនចំពោះការលក់ជើងឯកទៅឲ្យក្រុមហ៊ុនឯកជន ។ មួយខែក្រោយមក ស្ថានទូតជប៉ុនចេញសេចក្តីប្រកាសព័ត៌មានមួយដោយនិយាយថា ១) វាអាស្រ័យទៅលើការសម្រេចចិត្តរបស់អាជ្ញាធរកម្ពុជាថាតើត្រូវចាត់ចែងវាលពិឃាតជើងឯកដោយរបៀបណា ។ ២) រដ្ឋាភិបាលជប៉ុនមិនជាប់ពាក់ព័ន្ធនឹងការធ្វើសម្បទាន ហើយបញ្ហានេះមិនទាន់ត្រូវបានយកមកពិគ្រោះទេ ។ ៣) ជំនួយអភិវឌ្ឍរបស់ប្រទេសជប៉ុនមិនមានទំនាក់ទំនងនឹងការធ្វើសម្បទានទេ ។ ៤) រដ្ឋាភិបាលជប៉ុនគាំទ្រតុលាការខ្មែរក្រហមដែលអាចនឹងជំរុញឲ្យមានវិធានច្បាប់នៅក្នុងកម្ពុជា ។*

*ប្រជាជនកម្ពុជាភាគច្រើនពេញចិត្តយ៉ាងខ្លាំងនូវការគាំទ្ររបស់ជប៉ុនចំពោះតុលាការ ។ ប៉ុន្តែដោយរង់ចាំនូវសេចក្តីប្រកាសព័ត៌មានអំពីកិច្ចសន្យាយូរពេក ស្ថានទូតបានបាត់បង់ឱកាសជួយជំរុញឲ្យមានវិធានច្បាប់កម្ពុជា ។ ការពន្យារពេលនេះហាក់ដូចជាជំរុញឲ្យប្រជាជនកម្ពុជាព្រួយបារម្ភថា ជប៉ុននឹងឈប់ផ្តល់ជំនួយប្រសិនបើក្រុមហ៊ុនជប៉ុនមិនទទួលបានជើងឯក ។*

*ប្រទេសជប៉ុនអាចប្រើប្រាស់ឥទ្ធិពលគាបសង្កត់ទៅលើមន្ត្រីរាជការចំពោះកិច្ចសន្យានោះ ដើម្បីក្លាយខ្លួនទៅជាជើងឯកក្នុងការគ្រប់គ្រងដ៏មានតម្លាភាព ។ ប៉ុន្តែ ជប៉ុនបែរជាដកខ្លួនឆ្ងាយពីកិច្ចការនេះ ហើយផ្តល់ការជឿជាក់ទៅឲ្យអ្នកដែលលក់មរតកវប្បធម៌ទៅវិញ ។*

*«បច្ចុប្បន្នទំនាក់ទំនងវៀតណាម-កម្ពុជានៅខេត្តសៀមរាបបានឈប់ដំណើរការ ហើយមន្ត្រីរាជការដែលអនុម័តកិច្ចសន្យាមិនចាំឈ្មោះក្រុមហ៊ុនដែលទិញដីនោះទេ ។ ដូច្នេះហេតុអ្វីបានជារដ្ឋាភិបាលត្រូវទទួលខុសត្រូវ? បន្ទាប់ពីនេះ យើងចាំមើលថាតើនឹងមានអ្វីកើតឡើងនៅវាលពិឃាតជើងឯក ។ យើងទាំងអស់គ្នាបានត្រឹមតែឆ្ងល់ថាតើបូជនីយដ្ឋានប្រល័យពូជសាសន៍មួយណាទៀតនឹងត្រូវបានលក់» ។*

◆ *ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៥ សហរដ្ឋអាមេរិកនិយាយថានឹងមិនចូលរួមក្នុងសាលាក្តីខ្មែរក្រហមទេ បើសិនជាសាលាក្តីមិនយុត្តិធម៌និងមានឥទ្ធិពលនយោបាយ ។ លោក ព្យែរ រីឆាតប្រូស្ពើ (Pierre Richard Prosper ) អគ្គរដ្ឋទូតអាមេរិកទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាមបានប្រាប់អ្នកយកព័ត៌មាននៅអំឡុងទស្សនកិច្ចពីរថ្ងៃ*

ក្នុងក្រុងភ្នំពេញថា «សហរដ្ឋអាមេរិកចង់ស្ថិតនៅក្នុងជំហរមួយដែលយើងអាចគាំទ្របញ្ហានេះដោយផ្នែកនយោបាយនិងហិរញ្ញវត្ថុ» ។ លោកបន្ថែមទៀតថា «អ្វីដែលយើងចង់ចៀសវាងនោះគឺបញ្ហាខ្វះដែលកើតឡើងក្នុងប្រព័ន្ធតុលាការធម្មតាដែលត្រូវផ្លាស់ប្តូរទៅជាសាលាក្តីខ្មែរក្រហម ។ សាលាក្តីត្រូវតែគ្មានអំពើពុករលួយ ។ ត្រូវតែគ្មានការគ្រប់គ្រងឬឥទ្ធិពលនយោបាយនិងត្រូវតែមានតម្លាភាព ។

◆ ថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០០៥ ប្រជាជនខ្មែរចំនួន ១០០០នាក់ បានជួបជុំគ្នានៅវាលពិឃាតជើងឯក ដើម្បីរំឭកដល់ជនរងគ្រោះដែលបានបាត់បង់ជីវិតពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ និងស្នើឲ្យអតីតមេដឹកនាំខ្មែរក្រហមប្រឈមមុខនឹងតុលាការឲ្យបានឆាប់ ។ ញាតិសន្តានជនរងគ្រោះ សិស្ស និស្សិត មន្ត្រីរាជការ និងព្រះសង្ឃបានចូលរួមក្នុងកម្មវិធីនោះ ដែលគេប្រារព្ធធ្វើជារៀងរាល់ឆ្នាំដើម្បីរំឭកដល់របបកសិកម្ម សមូហភាវូបនីយកម្មម៉ៅនិយមនៅវាលពិឃាតជើងឯក ប៉ែកនិរតីនៃទីក្រុងភ្នំពេញ ។

◆ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៥ ឧបនាយរដ្ឋមន្ត្រីកម្ពុជា សុខ អាន ស្នើឲ្យអ្នកការទូតបរទេសនៅទីក្រុងភ្នំពេញជួយកម្ពុជាក្នុងការចំណាយទឹកប្រាក់មួយចំណែក (១៣,៣លានដុល្លារ) នៃទឹកប្រាក់ចំណាយរបស់សាលាក្តីដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ លោក ស៊ាន វិសុទ្ធ លេខាធិការនៃក្រុមការងារសាលាក្តីរបស់រដ្ឋាភិបាលបាននិយាយថា «ប្រទេសឥណ្ឌា សិង្ហបុរី និងថៃបានបង្ហាញពីចំណាប់អារម្មណ៍ក្នុងការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ។ គាត់បានបន្ថែមទៀតថា សហគមន៍អឺរ៉ុបកំពុងសម្រេចចិត្តថាតើនឹងផ្តល់ប្រាក់១,៣លានដុល្លារដែលបានសន្យាចំពោះអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា» ។

◆ ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៥ អង្គទូតនិងអ្នកតំណាងមកពីស្ថានទូតចំនួន១៣នៅទីក្រុងភ្នំពេញបានធ្វើទស្សនកិច្ចទៅកាន់ទីតាំងអង្គជំនុំជម្រះវិសាមញ្ញដែលបានស្នើឲ្យដាក់នៅកំបូល ។

◆ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៥ អ្នកជំនួញកម្ពុជាសំខាន់ៗជាច្រើននាក់និយាយថា ពួកគាត់នឹងផ្តល់ប្រាក់ដើម្បីជួយចំណាយលើថវិកាដែលរដ្ឋាភិបាលនៅខ្វះចំនួន១១,៨លានដុល្លារសម្រាប់សាលាក្តីខ្មែរក្រហម ប្រសិនបើរដ្ឋាភិបាលធ្វើសំណូមពរជាផ្លូវការ ។ លោកសុខ គង់ អគ្គនាយកក្រុមហ៊ុនសូគីម៉ិចបានមានប្រសាសន៍ថា «ខ្ញុំនឹងបរិច្ចាគថវិកាសម្រាប់សាលាក្តីដើម្បីជួយរដ្ឋាភិបាល ។ គាត់បានបន្ថែមទៀតថា គាត់ជឿថាមិនមែនមានតែគាត់ទេដែលជាអ្នកជំនួញត្រៀមនឹងជួយនោះ ។ លោក គិត ម៉េង ប្រធានក្រុមហ៊ុនរ៉ូយ៉ាល់គ្រុបបាននិយាយដូចគ្នាដែរថា «បើសម្តេច ហ៊ុន សែន បង្កើតគោលនយោបាយ ឬសំណូមពរជាផ្លូវការ យើងនឹងមិនបដិសេធឡើយ» ។

◆ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៥ អ្នកនាំពាក្យគណបក្ស សម រង្ស៊ី លោក អ៊ុឹង ប៊ុនអាង បានស្នើឲ្យរដ្ឋាភិបាលកម្ពុជារៀបចំការរៃអង្គាសថ្នាក់ជាតិមួយដើម្បីបំពេញថវិកាដែលខ្វះដែលរដ្ឋាភិបាលបាននិយាយថា ជាឧបសគ្គចុងក្រោយនៃការបង្កើតសាលាក្តីដែលគេរង់ចាំមើលជាយូរមកហើយ ។ គាត់បាននិយាយក្នុងសេចក្តីថ្លែងការណ៍មួយថា «ហាក់ដូចថាអ្នកគ្រប់គ្នាបានចូលរួមផ្តល់មូលនិធិសម្រាប់សាលាក្តីខ្មែរក្រហម លើកលែងតែប្រជាជនខ្មែរនៅទីនេះនិងនៅក្រៅប្រទេស» ។

◆ ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៥ នួន ជា សារភាពថាសុខភាពរបស់ខ្លួនកំពុងទ្រុឌទ្រោម ហើយសម្ពាធឈាមខ្ពស់កំពុងបង្កបញ្ហាដល់គាត់ ។ ប៉ុន្តែគាត់និយាយថា គាត់កំពុងព្យាយាមថែរក្សាសុខភាពគាត់ក្នុងករណីដែលគាត់ត្រូវកោះហៅទៅបង្ហាញខ្លួននៅសាលាក្តីខ្មែរក្រហមដែលជាប់គាំងយូរមកហើយនោះ ។ គាត់បានថ្លែងថា «ខ្ញុំកំពុងថែរក្សាខ្លួននិងសុខភាពរបស់ខ្ញុំ ពីព្រោះខ្ញុំកំពុងត្រៀមខ្លួនទៅកាន់តុលាការ ប៉ុន្តែខ្ញុំមិនដឹងថាខ្ញុំអាចទ្រាំទ្រដល់ពេលណាទេ» ។

◆ ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៥ សម្តេច ហ៊ុន សែន បានបដិសេធសំណើរៃអង្គាសមូលនិធិថ្នាក់ជាតិដើម្បីជួយបំពេញថវិកាដែលខ្វះខាត១១,៨លានដុល្លាររបស់រដ្ឋាភិបាលសម្រាប់សាលាក្តីខ្មែរក្រហម ។ នេះជាទង្វើមួយដែលអ្នកអង្កេតខ្លះជឿថាអាចបង្កភាពងឿងឆ្ងល់ពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះសាលាក្តីដែលខ្លួនរង់ចាំអស់រយៈពេលដ៏យូរនេះ ។ ជាការផ្តល់យោបល់លើសំណើរៃអង្គាសប្រាក់សម្រាប់សាលាក្តីខ្មែរក្រហមពីការបរិច្ចាគរបស់ប្រជាជនខ្មែរក្នុងប្រទេស ហ៊ុន សែន មានប្រសាសន៍ថា «ខ្ញុំគិតថាសំណើបែបនេះមិនអាចទទួលយកបានទេ ។

ប្រជាជនខ្មែររកប្រាក់គ្រាន់តែចិញ្ចឹមជីវិតប៉ុណ្ណោះ» ។ លោក ឌិម យិនទៀង សមាជិកក្រុមការងារសាលាក្តីខ្មែរក្រហមរបស់រដ្ឋាភិបាលបាននិយាយបន្តថា វាមិនគួរមានការអំពាវនាវទៅអ្នកជំនួញធំៗ ឬអ្នកដទៃទៀតដើម្បីឲ្យគេជួយនោះទេ» ។

◆ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥ ក្រសួងការបរទេសជប៉ុននិយាយថា «ប្រទេសជប៉ុនមិនអាចផ្តល់ហិរញ្ញវត្ថុដោយផ្ទាល់ដើម្បីចំណាយទឹកប្រាក់១១,៨លានដុល្លារ ដែលខ្វះសម្រាប់សាលាក្តីខ្មែរក្រហមរបស់កម្ពុជាទេ ប៉ុន្តែគេកំពុងសិក្សាពីលទ្ធភាពនៃការបង្កើតមូលនិធិតាមរយៈជំនួយទ្វេភាគីរបស់ជប៉ុនមកកម្ពុជា» ។ លោក ហាតស៊ុយហ៊ី តាកា ស៊ីម៉ា *Hatsuhisa Taka shima* បានប្រាប់អ្នកយកការណ៍នៅក្នុងសន្និសីទកាសែតមួយថា «រដ្ឋាភិបាលជប៉ុនតាមរយៈរដ្ឋមន្ត្រីក្រសួងការបរទេស *Nobutaka Machimura* ចង់ឃើញសាលាក្តីខ្មែរក្រហមចាប់ផ្តើមឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។ ធ្វើដូច្នោះ រដ្ឋាភិបាលជប៉ុនស្ម័គ្រចិត្តពិភាក្សាដោយលម្អិតអំពីជំនួបដែលអាចឲ្យជប៉ុនមានមធ្យោបាយផ្តល់ហិរញ្ញវត្ថុតាមរយៈជំនួបទ្វេភាគីរវាងកម្ពុជានិងជប៉ុន» ។

◆ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៥ រដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង ថ្លែងថា ឧបសគ្គមួយទៀតនៃការបង្កើតសាលាក្តីខ្មែរក្រហមត្រូវបានដោះស្រាយជាមួយនឹងសេចក្តីប្រកាសដែលថាកម្ពុជានឹងប្រើប្រាស់មូលនិធិពិសេសមួយដែលបង្កើតឡើងដោយរដ្ឋាភិបាលជប៉ុនដើម្បីចំណាយលើចំណែកដែលនៅសល់នៃថវិកាសាលាក្តីខ្មែរក្រហម ។ លោករដ្ឋមន្ត្រីបានបន្ថែមថា «រដ្ឋាភិបាលជប៉ុនបានផ្តល់ប្រាក់រួចហើយ ។ យើងនឹងប្រើប្រាស់លុយនេះ ដូច្នេះយើងសង្ឃឹមថាសាលាក្តីខ្មែរក្រហមអាចដំណើរការបានក្នុងពេលឆាប់ៗនេះ» ។

◆ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ សេចក្តីប្រកាសរបស់លោក ហោ ណាំហុង ដែលថាកម្ពុជានឹងប្រើប្រាស់មូលនិធិពិសេសមួយដែលបង្កើតឡើងដោយរដ្ឋាភិបាលជប៉ុនដើម្បីចំណាយលើចំណែកដែលនៅសល់នៃថវិកាសាលាក្តីខ្មែរក្រហម បានបង្កភាពភ្ញាក់ផ្អើលដល់ស្ថានទូតជប៉ុននៅទីក្រុងភ្នំពេញ ។ មន្ត្រីកិច្ចការនយោបាយរបស់ស្ថានទូតនេះ *Fumio Goto* បានមានប្រសាសន៍ថា កម្មវិធីជំនួយទ្វេភាគីរបស់ជប៉ុនមិនអាចចេញការចំណាយទាំងអស់របស់កម្ពុជាទេ ហើយគាត់បានសុំឲ្យប្រទេសដទៃរួមចំណែកផងដែរ ។ គាត់បានបន្ថែមថា «ដោយសារមិនមែនមានតែជប៉ុនទេដែលជួយសាលាក្តីខ្មែរក្រហម ដូច្នេះយើងអាចយល់បានថា ឥឡូវរាជរដ្ឋាភិបាលកម្ពុជាត្រៀមខ្លួនអំពាវនាវដល់ប្រទេសផ្តល់ជំនួយទាំងអស់ដើម្បីជួយរួមចំណែកដល់កម្ពុជាដែលត្រូវចំណាយផង» ។

◆ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ០០៥ ប្រទេសអាល្លឺម៉ង់ជំរុញឲ្យសាលាក្តីខ្មែរក្រហមខិតទៅរកការចាប់ផ្តើម ដោយប្រកាសបរិច្ចាគប្រាក់១៩លានដុល្លារបន្ថែមទៀតសម្រាប់ថវិកាចំណាយ ៥៦,៣លានដុល្លាររបស់សាលាក្តី ។

◆ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៥ អ្នកការទូតម្នាក់បាននិយាយដោយមិនបញ្ចេញឈ្មោះថា អង្គការសហប្រជាជាតិយល់ព្រមយកអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទនៅជាយក្រុងភ្នំពេញដាក់ជាទីតាំងសាលាក្តីខ្មែរក្រហម ។ ការសម្រេចចិត្តនេះត្រូវបានធ្វើឡើងនៅក្នុងការប្រជុំសម្ងាត់មួយនៅទីក្រុងញូវយ៉ក កាលពីថ្ងៃទី៣០ ខែមិថុនា រវាងអង្គការសហប្រជាជាតិ និងអ្នកតំណាងមកពីប្រទេសដែលជាប់ពាក់ព័ន្ធនឹងសាលាក្តីនេះ ។

◆ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ០០៥ អង្គការសហប្រជាជាតិស្នើឲ្យប្រទេសជាសមាជិកប្រគល់ឈ្មោះចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិដែលត្រូវបានតែងតាំងសម្រាប់សាលាក្តីខ្មែរក្រហម ។ លេខាធិការដ្ឋានអង្គការសហប្រជាជាតិបានផ្ញើលិខិតមួយច្បាប់ទៅប្រទេសជាសមាជិកនៅថ្ងៃទី៣០ ខែមិថុនា ជាមួយការតែងតាំងសម្រាប់តំណែងសរុប៩ ពីសហគមន៍អន្តរជាតិដែលត្រូវប្រគល់ត្រឹមថ្ងៃទី២៩ ខែសីហា ។ នីកូឡា មីសែល អគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលខុសត្រូវកិច្ចការច្បាប់បានសរសេរថា គាត់នាមឲ្យអគ្គលេខាធិការ កូហ្វី អាណាន់ ខ្ញុំមានកិត្តិយសស្នើសុំឲ្យរដ្ឋាភិបាលស្នើឈ្មោះអ្នកដែលអគ្គលេខាធិការអាចតែងតាំងបាន ។ លិខិតនោះត្រូវបានសរសេរថា មន្ត្រីតុលាការអន្តរជាតិនឹងត្រូវការលុយ១២៩,៨០០ដុល្លារក្នុងមួយឆ្នាំដោយគណនាលើរយៈពេលដែលមន្ត្រីទាំងនោះធ្វើការងារជាក់ស្តែង ។ មន្ត្រីទាំងនោះនឹងចាប់ផ្តើមនៅពេលផ្សេងគ្នានិងបម្រើសម្រាប់អំឡុងពេលផ្សេងគ្នាផ្អែកលើដំណាក់កាល ដូចជាដំណាក់កាលស៊ើបអង្កេត ការកាត់ទោស និងការប្តឹងនៃសាលាក្តីដែលពួកគេចូលរួម ។

◆ *ខែមិថុនា ២០០៥ លោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ស្នើឲ្យរដ្ឋាភិបាលអាស៊ានចូលរួមបន្ថែមទៀតនៅក្នុងដំណើរការសាលាក្តីខ្មែរក្រហម (ដោយផ្តល់ជំនួយដែលត្រូវការខ្លាំង ដូចជាជំនួយបច្ចេកទេសផ្តល់ឯកសារដែលពាក់ព័ន្ធនឹងខ្មែរក្រហមទៅសាលាក្តី) ការប្រឹក្សាជួយប្រជាជនដែលរងការឈឺចាប់ដោយសារជំងឺបាក់ស្បាត កុំព្យូទ័រ មធ្យោបាយដឹកជញ្ជូន រថយន្តដឹកទំនិញធំៗ ឬរថយន្តក្រុងតូចៗ សម្រាប់ដឹកប្រជាជនពីជនបទមកចូលរួមការកាត់ក្តីនៅទីក្រុង និងវិទ្យុ ។*

◆ *ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៥ មន្ត្រីរដ្ឋាភិបាលម្នាក់និយាយនៅក្នុងសន្និសីទស្តីពីសាលាក្តីថា «រដ្ឋាភិបាលនៅកំពុងរង់ចាំអ្នកផ្តល់ជំនួយអន្តរជាតិដើម្បីបំពេញថវិកាជាចំណែករបស់កម្ពុជាសម្រាប់សាលាក្តីខ្មែរក្រហមដែលនៅខ្វះ១១,៨លានដុល្លារ និងដើម្បីអង្គការសហប្រជាជាតិតែងតាំងតំណាងអ្នកសម្របសម្រួលមុនពេលដំណើរការទៅមុខ ។ ស៊ាន វិសុទ្ធ លេខាធិការនៃក្រុមការងារសាលាក្តីខ្មែរក្រហមរបស់រដ្ឋាភិបាលបាននិយាយថា «ពេលណាយើងទទួលបានព័ត៌មានពីអង្គការសហប្រជាជាតិអំពីអ្នកដែលនឹងមកកាន់តំណែងជាតំណាងអ្នកសម្របសម្រួល ពេលនោះកម្ពុជានឹងស្វែងរកអ្នកសម្របសម្រួលរបស់ខ្លួន ។ យើងកំពុងរង់ចាំអង្គការសហប្រជាជាតិ» ។ អង្គការសហប្រជាជាតិបានបិទប្រកាសជ្រើសរើសតំណាងអ្នកសម្របសម្រួលនៅខែមេសា ។ ការដាក់ពាក្យផុតកំណត់នៅថ្ងៃទី៨ ខែឧសភា ។ យោងតាមមន្ត្រីទាំងនោះ អង្គការសហប្រជាជាតិបានទទួលពាក្យសុំជាង១០០ច្បាប់ ។ អគ្គរាជទូត ជប៉ុន ហ្វូមីអាគី តាកាហាស៊ី (Fumiaki Takahashi) បានមានប្រសាសន៍នៅឯសន្និសីទដែលរៀបចំឡើងដោយសាកលវិទ្យាល័យកម្ពុជាថា វាជាដំណាក់កាលចុងក្រោយនៃការសម្រេចថានរណានឹងកាន់ការងារនោះ ។*

◆ *ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៥ អ៊ាន ភាសិន (Ian Pearson) រដ្ឋមន្ត្រីការិយាល័យបរទេសសម្រាប់កិច្ចការពាណិជ្ជកម្មរបស់ចក្រភពអង់គ្លេសបាននិយាយបន្ទាប់ពីជំនួបជាមួយនាយករដ្ឋមន្ត្រី ហ៊ុន សែន ពិភាក្សាពីសាលាក្តីថា «ចក្រភពអង់គ្លេសនឹងបរិច្ចាគប្រាក់ប្រមាណ២,៦លានដុល្លារដល់សាលាក្តីខ្មែរក្រហមដែលគេទន្ទឹងរង់ចាំជាយូរមកហើយ ។ យើងបាននិយាយហើយថា យើងប្តេជ្ញាផ្តល់ប្រាក់២,៦លានដុល្លារសម្រាប់ពេល៣ឆ្នាំខាងមុខទៅឲ្យភាគីអន្តរជាតិរបស់សាលាក្តី» ។*

◆ *ថ្ងៃទី១ ខែសីហា ឆ្នាំ២០០៥ ហារុហិស្សា ហាន់ដា (Haruhisa Handa) អ្នកបរិច្ចាគ មេដឹកនាំសាសនា អ្នកជំនាញពាណិជ្ជកម្មតាមស៊ីលផ្ទាល់ខ្លួន និងជាអ្នកនិពន្ធដែលមានឈ្មោះថា តូស្យូ ហ្វូកាមី (Toshu Fukami) ប្រកាសផ្តល់មូលនិធិរំឭកនិងសងជំងឺចិត្តដល់ជនរងគ្រោះនៃរបបខ្មែរក្រហមចំនួន១,៣លានដុល្លារ ។ គាត់បាននិយាយថា « ហារុហិស្សា ហាន់ដា ដែលជាស្ថាបនិកសមាគមកីឡាកូនហ្គោលជនពិការជប៉ុននឹងផ្តល់មូលនិធិ៣០០,០០០ដុល្លារ ចំណែកឯអង្គការសុខុមាលភាពរបស់គាត់ឈ្មោះ វើល មេត (World Mate) នឹងចេញចំណាយថវិកាដែលនៅសល់ ។ អ្នកដែលនៅរស់ពីរបបនេះនឹងត្រូវហៅឲ្យទៅដាក់ពាក្យសុំថវិកាពីមូលនិធិនេះ ដែលមានគោលបំណងផ្តល់ប្រាក់១០០ដុល្លារក្នុងមួយគ្រួសារ សម្រាប់គ្រួសារចំនួន១០.០០០ ។ ហារុហិស្សា ហាន់ដា បាននិយាយថា «បើខ្ញុំទទួលប្រាក់បរិច្ចាគច្រើនជាងនេះ ខ្ញុំអាចផ្តល់ប្រាក់ដល់ប្រជាជនច្រើនជាងនេះដែរ» ។*

◆ *ថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៥ មុនពេលបញ្ចប់ដំណើរការតែងតាំងសម្រាប់ការជ្រើសរើសចៅក្រមនិងព្រះរាជអាជ្ញានៅអង្គជំនុំជម្រះវិសាមញ្ញថ្មី មិនដល់មួយខែផង អង្គការលើកលែងទោសអន្តរជាតិកំពុងស្នើឲ្យគ្រប់រដ្ឋទាំងអស់តែងតាំងបេក្ខជនដែលសក្តិសមបំផុតទៅអង្គជំនុំជម្រះវិសាមញ្ញ ។ ដោយសារតែចំណុចខ្សោយដ៏ធ្ងន់ធ្ងរនៅក្នុងប្រព័ន្ធតុលាការជាតិ អង្គការលើកលែងទោសអន្តរជាតិត្រូវបានច្រានចោលដោយសម្រេចតែងតាំងចៅក្រមកម្ពុជាភាគច្រើនដើម្បីបម្រើការងារក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ ចៅក្រម១១រូបក្នុងចំណោម១៩រូប និងសហព្រះរាជអាជ្ញាម្នាក់ក្នុងចំណោម២នាក់ជាជនជាតិខ្មែរ ។ អង្គការលើកលែងទោសអន្តរជាតិគិតឃើញថា ប្រព័ន្ធតុលាការកម្ពុជាបន្តចុះខ្សោយ ហើយប្រឈមមុខនឹងសម្ពាធនយោបាយ ជាពិសេសករណីសំខាន់ៗ ។ ពេលថ្មីៗនេះវាមិនអាចធានាថា សាលាក្តីនឹងធ្វើឡើងស្របទៅតាមច្បាប់អន្តរជាតិ និងស្តង់ដារយុត្តិធម៌បានទេ ។*

***(នៅមានត)***

**គាត លក្ខិណា**

# ការពិត ការរៀបរាប់ និងនយោបាយដើម្បីការចងចាំ បន្ទាប់ពីអំពើប្រល័យពូជសាសន៍

នៅពេលដែលប្រជាជនកម្ពុជាពិភាក្សាអំពីរបបកម្ពុជាប្រជាធិបតេយ្យ នៅអំឡុងពេលនៃការគ្រប់គ្រងរបស់ខ្មែរក្រហមដែលបានធ្វើឲ្យប្រជាជនពីរលាននាក់ក្នុងចំណោមប្រជាជនខ្មែរសរុប ៨លាននាក់ស្លាប់បាត់បង់ជីវិតចាប់ពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ អ្នកទាំងនេះនឹកឃើញពីមធ្យោបាយជាច្រើននៃការបំផ្លិចបំផ្លាញនេះ ។ ការចងចាំនេះក្លាយទៅជាស្រមោល និងបទឧក្រិដ្ឋមួយ ។

ឆ្វាត ជាមន្ត្រីរដ្ឋបាលខេត្តថ្នាក់ក្រោមនិងជាអតីតសិស្សម្នាក់នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ បានរំពុកឡើងវិញនូវមរណភាពបងប្រុសរបស់គាត់ឈ្មោះ ស្រួន ។ សញ្ញប់សញ្ញឹងដោយទឹកមុខមាំ ឆ្វាត ជាមនុស្សម្នាក់ក្នុងចំណោមប្រជាជនទាំងនោះ ដែលប្រហែលជាអាចរៀនបានខ្ពង់ខ្ពស់ប្រសិនបើបដិវត្តន៍ខ្មែរក្រហមមិនបានបំផ្លាញដំណើរជីវិតរបស់គាត់ទេនោះ ។ ភាពញញឹមបានឆ្លុះបញ្ចាំងពីជីវិតរបស់ ឆ្វាត ដែលតស៊ូដើម្បីភាពជោគជ័យ ហើយតែងតែព្រួយបារម្ភនិងព្យាយាមបំភ្លេចឲ្យអស់នូវការឈឺចាប់ទាំងប៉ុន្មាន ។ យើងក៏បាននិយាយជាច្រើនដងអំពីដំណើរជីវិតរបស់គាត់ដែលរួមបញ្ចូលនូវរយៈពេលនៃការចងចាំឧក្រិដ្ឋកម្មមួយ ។

ឫសគល់នៃបទពិសោធន៍ក្នុងសង្គមវិស្សុកម្ម ខ្មែរក្រហមបានធ្វើការឃោសនាអំពីការឈ្លានពានពីអតីតកាល ដើម្បីស្វែងរកវិធីលុបបំបាត់អ្វីៗដែលជាកម្អែលរបស់មូលធននិយម «ឯកជននិយម» និងវណ្ណៈជិះជាន់ ។ ការឃោសនានេះកាន់តែរីករាលដាលខ្លាំងឡើងថែមទៀត ។ និយាយឲ្យចំ ខ្មែរក្រហមសំដៅលើព្រះពុទ្ធសាសនា គ្រួសារ រចនាសម្ព័ន្ធភូមិ សកម្មភាពសេដ្ឋកិច្ច និងការអប់រំសាធារណៈ (ទាំងអស់នេះជាស្ថាប័នសង្គមវប្បធម៌ដ៏សំខាន់ដែលនាំទៅរកការផ្លាស់ប្តូរនូវការចងចាំមានលក្ខណៈជាផ្លូវការ ក្រៅផ្លូវការនិងជាទម្លាប់) ។ កាន់តែច្បាស់ជាងនេះ ខ្មែរក្រហមបានបំផ្លាញការចងចាំក្នុងសង្គមតាមរយៈការដុតសៀវភៅ វាយកម្ទេចបណ្ណាល័យ ការហាមប្រាមតន្ត្រីសម័យ ភាពយន្ត ប្រព័ន្ធផ្សព្វផ្សាយ របៀបស៊ីវិល័យ និងបំផ្លិចបំផ្លាញវត្តអារាម កាត់បន្ថយការប្រាស្រ័យទាក់ទង លុបបំបាត់ពិធីបុណ្យតាមបែបប្រពៃណី និងសាសនា បំបែកសមាជិកគ្រួសារឲ្យនៅដាច់ដោយឡែក ការស្លៀកពាក់ដូចៗគ្នា លុបបំបាត់ទ្រព្យសម្បត្តិឯកជន ដែលរួមមានរូបថត វត្ថុចងចាំ និងវត្ថុអនុស្សាវរីយ៍ផ្សេងទៀត ។

ជម្លោះអតីតកាលត្រូវបានបង្ហាញឲ្យឃើញជាលើកដំបូង នៅពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាច ដោយធ្វើការជម្លៀសប្រជាជនចេញពីទីក្រុងទៅនៅជនបទ បង្ខំប្រជាជនឲ្យចាកចេញពីផ្ទះដោយមិនបានប្រកាសឲ្យដឹងមុន ធ្វើឲ្យប្រជាជនរាប់រយពាន់នាក់កកស្ទះនៅលើវិថីនានាដែលធ្វើដំណើរចេញពីភ្នំពេញនិងពីទីរួមខេត្ត ។ ភាពច្របូកច្របល់ ការធ្វើដំណើរដោយគ្មានទិសដៅច្បាស់លាស់ឆ្លងកាត់វត្តអារាម សាលារៀន រោងកុន ភោជនីយដ្ឋាន សួនឧទ្យាន ផ្លូវនានា ផ្ទះដែលមានរបៀបរៀបរយ ទីក្រុងត្រូវបានបំភ្លេចចោល ក្រដាសប្រាក់ដែលគ្មានតម្លៃប៉ុន្មានរសាត់ទៅតាមខ្យល់ រថយន្តទំនើបគ្មានសាំងចាក់ អាហារផ្អូមដោយសារកម្តៅថ្ងៃ សៀវភៅជាច្រើនដែលមិនអាចយកទៅជាមួយបាន មនុស្សចាស់ជរា និងជនពិការដែលមិនអាចទ្រាំទ្រនឹងការធ្វើដំណើរបាន ។ ទាំងអស់នេះហើយ ដែលធ្វើឲ្យគេនៅតែចងចាំអំពីអតីតកាលដ៏ឈឺចាប់ដែលបានជួបប្រទះកន្លងមក ។

នៅក្នុងសង្គមបដិវត្តន៍ថ្មី ប្រជាជនគ្រប់រូបត្រូវតែដើរតាមមាគ៌ាបដិវត្តន៍មហាអស្ចារ្យប្រៀបដូចជាការដំដែកដែលខ្មែរក្រហមហៅថា «លត់ដំ» ។ ប្រជាជនជម្លៀសម្នាក់បានពន្យល់ថាប្រយោគដែលគួរឲ្យភ័យខ្លាចនោះគឺ «លត់ដំ» ។ លត់ មានន័យថាដែកមួយប្រភេទដែលគេយកទៅដាក់ក្នុងភ្លើងឲ្យឡើងពណ៌ក្រហម និងទន់ដើម្បីងាយស្រួលដំ ។ ចំណែក ដំ មានន័យថាដំដោយញញួរ គឺយកដែកដែលដុតឡើងពណ៌ក្រហមទៅដាក់លើទ្រនាប់ហើយវាយឲ្យទៅជាបែបសណ្ឋានណាមួយដែលយើងចង់បាន ។ លត់ដំ

បានពិពណ៌នាពីវិធីសាស្ត្រដែលប្រជាជនគិតថាជាការរៀបចំឡើងដោយអង្គការដើម្បីប្រែក្លាយឲ្យទៅជាប្រទេសកុម្មុយនីស្តពិតប្រាកដនៅថ្ងៃអនាគត ។

ការចងចាំត្រូវបានផ្លាស់ប្តូរក្នុងអំឡុងពេលនៃដំណើរការគ្រប់គ្រង ដើម្បីតម្រង់ទិសទៅតាមគោលគំនិតរបស់អង្គការដែលកែប្រែអតីតកាលឲ្យក្លាយទៅជាបដិវត្តន៍ក្រហមឆ្អិនឆ្អៅ ។ ការចម្លងទ្រឹស្តីរបស់ម៉ៅដើម្បីភ្ជាប់ជាមួយទ្រឹស្តីព្រះពុទ្ធសាសនាដែលបានអប់រំពីដំណើរជីវិតនិងការប្រតិបត្តិតាមផ្លូវធម៌ ខ្មែរក្រហមចង់និយាយសំដៅទៅលើពាក្យ «កង់ប្រវត្តិសាស្ត្រ» ដែលគ្រប់គ្រងប្រទេសតាមច្បាប់ធម្មជាតិ និងដែលគេយល់ដឹងតាមរយៈ «វិទ្យាសាស្ត្រ» របស់ម៉ាកឡេនីនដើម្បីយកមកអនុវត្តនិងកែប្រែកម្ពុជាឲ្យក្លាយទៅជាប្រទេសកុម្មុយនីស្តនិងកម្ទេចចោលនូវអ្វីដែលរាំងស្ទះដល់កិច្ចការរបស់ខ្លួន ។ ចក្ខុវិស័យពីអតីតកាល បានបង្ហាញយ៉ាងច្បាស់នៅក្នុងសុន្ទរកថារបស់ ប៉ុល ពត ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ១៩៧៧ ក្នុងទិវារំឭកខួបអនុស្សាវរីយ៍លើកទី១៧របស់បក្សកុម្មុយនីស្តកម្ពុជា ។ សុន្ទរកថាមិនត្រឹមតែប្រកាសជាសាធារណៈស្តីពីវត្តមានដំបូងរបស់បក្សកុម្មុយនីស្តកម្ពុជា និង ប៉ុល ពត ជាមេដឹកនាំបក្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានរៀបរាប់ពីប្រវត្តិនៃចលនាតស៊ូបដិវត្តន៍ក្នុងប្រទេសកម្ពុជាដែលធ្លាក់ចូលទៅក្នុងដំណាក់កាល «ទាសភាព» «សក្តិភូមិ» និង «សក្តិភូមិ-នាយទុននិយម» ដោយសារតែខ្វះ «គោលជំហរនយោបាយ» ។ គោលនយោបាយនេះបានបង្ហាញការពិតពេលដែល ប៉ុល ពត ប្រកាសនៅឯសន្និបាតបក្សកុម្មុយនីស្តកម្ពុជាលើកទី១ដែលប្រារព្ធឡើងនៅថ្ងៃទី២៨-៣០ ខែកញ្ញា ឆ្នាំ១៩៦០ ដោយមានអ្នកបដិវត្តន៍ចំនួន ២១រូបលាក់ខ្លួននៅក្នុងបន្ទប់សម្ងាត់មួយក្នុងស្ថានីយរថភ្លើងក្រុងភ្នំពេញ ។

ការយល់ដឹងតាមរយៈ «ការវិភាគបែបវិទ្យាសាស្ត្រ» នៃវិវាទនៅក្នុងសង្គមកម្ពុជារវាង «ប្រជាជនកម្ពុជានិងចក្រពត្តិនិយម ជាពិសេសចក្រពត្តិអាមេរិក» និងជម្លោះវណ្ណៈ (ជាពិសេសអ្នកមូលធននិងម្ចាស់ដី) បក្សអាចបង្កឲ្យមានអណ្តាតភ្លើងបដិវត្តន៍ប្រៀបដូចជា «ចំបើងនៅក្នុងវាលស្រែនារដូវក្តៅ» ។ ផ្តើមចេញពីចំណុចនេះ ប៉ុល ពត បានថ្លែងថា សង្គ្រាមរីករាលដាលពេញប្រទេស ហើយចលនាបដិវត្តន៍នឹងវាយរំលំរបបសាធារណរដ្ឋខ្មែរនិងសហរដ្ឋអាមេរិក ។ ខណៈនោះ បក្សបដិវត្តន៍បានបង្កើតឲ្យមានខ្មែរក្រហម ដូច្នេះហើយទើបធ្វើឲ្យបក្សងាយស្រួលក្នុងការដឹកនាំប្រទេសកម្ពុជាឆ្ពោះទៅរករដ្ឋកុម្មុយនីស្តយ៉ាងឆាប់រហ័ស ។

ការសម្រេចបាននូវគោលដៅនេះ តម្រូវឲ្យប្រទេសមានការចូលរួមពីអ្នកបដិវត្តន៍ថ្មីដែលឆ្លងកាត់ការលត់ដំការងារពលកម្មជាទម្ងន់ ការប្រជុំទិតៀន ការបើកវគ្គនយោបាយនិងការអប់រំសតិអារម្មណ៍ជាប្រចាំ ដើម្បីធ្វើឲ្យមានការយល់ដឹងកាន់តែជ្រៅជ្រះខាងផ្នែកនយោបាយ ហើយស្របទៅនឹងគោលនយោបាយរបស់បក្សនិងប្រវត្តិសាស្ត្រទៀតផង ។ ចំណុចទាំងនេះបញ្ជាក់ពីភាពដែលមិនអាចអូសទាញខ្លួនគេឲ្យធ្លាក់ទៅក្នុងអំពើ «ពុករលួយ» ពីអតីតកាលបានទេ ។ ជាឧទាហរណ៍ ការបរិយាយដ៏វែងអន្លាយរបស់អ្នកដែលនៅរស់រានមានជីវិតម្នាក់អំពីការត្អូញត្អែរពីលក្ខខណ្ឌរស់នៅលំបាក មិនមានឱកាសកម្សាន្ត ការប្រព្រឹត្តកំហុសឆ្គងនៅក្នុងការងារឬទៅធ្វើការងារមិនបានខ្ជាប់ខ្ជួន ដែលទាំងអស់នេះខ្មែរក្រហមនិយាយថាជា «ជំងឺសតិអារម្មណ៍» ។ ប្រសិនបើជំងឺនេះជាជំងឺរ៉ាំរ៉ៃ ឬមិនអាចព្យាបាលឲ្យជាសះស្បើយឆាប់ទេនោះ វិធីព្យាបាលគឺសម្លាប់ចោល ។ ការសម្លាប់ជាវិធីមួយដែលធ្វើឡើងដើម្បីលុបបំបាត់នូវការចងចាំពីអតីតកាលដែលប្រឆាំងនឹងបដិវត្តន៍ ។

ឆ្វាត ជក់បារីរួចនិយាយប្រាប់ខ្ញុំអំពីរឿងរ៉ាវក្រុមគ្រួសាររបស់គាត់ធ្វើដំណើរប្រជៀតគ្នាចាកចេញពីទីក្រុងភ្នំពេញក្រោមកម្តៅថ្ងៃស្ទើរឆេះ ហើយការធ្វើដំណើរអាចដើរទៅមុខបានតែមួយម៉ែត្រប៉ុណ្ណោះក្នុងរយៈពេលពីរម៉ោង ។ នៅតាមផ្លូវ ខ្មែរក្រហមបានដកយកយកនាឡិកាដៃ សញ្ញាប័ត្រនិងសម្លៀកបំពាក់របស់គាត់ ។ នៅពេលនោះ បងថ្លៃរបស់ ឆ្វាត ជាអតីតមន្ត្រីយោធាម្នាក់បានបង្ហាញពីអត្តសញ្ញាណរបស់ខ្លួន ហើយក៏ត្រូវទាហានខ្មែរក្រហមនាំយកទៅ ដែលចាប់តាំងពីពេលនោះមកមិនដែលឃើញត្រឡប់មកវិញទេ ចំណែកជីតារបស់គាត់ស្លាប់ ហើយកប់នៅតាមចិញ្ចើមផ្លូវដែលមានតែធូបធ្វើជាសញ្ញាសម្គាល់ប៉ុណ្ណោះ ។ ពីដំបូង ឆ្វាត បានហុចបារីឲ្យខ្ញុំមួយដើម តែខ្ញុំបដិសេធ ។ គាត់ញញឹមរួចនិយាយបន្តថា គាត់ចាប់ផ្តើមជក់បារីដំបូងគឺនៅពេលដែលខ្មែរក្រហមបញ្ជូនគាត់ឲ្យទៅដឹកលាមកមនុស្សពីបង្គន់មកធ្វើជី ។ ឆ្វាត រៀបរាប់ថា

«ក្លិនលាមកសាយភាយពេញខ្លួន ហើយបារីអាចកាត់ក្លិនស្អុយបាន ។ ខ្ញុំបន្តជក់រហូតទោះបីជាខ្ញុំឈប់ធ្វើការនៅទីនោះក៏ដោយ ។ ខ្ញុំមិនដែលបានហូបឆ្អែតទេ ប៉ុន្តែនៅពេលដែលខ្ញុំជក់បារីវាអាចជួយកាត់បន្ថយការស្រេកឃ្លានរបស់ខ្ញុំបាន» ។ គាត់ជក់បារីពីព្រោះតែខួរក្បាលរបស់គាត់ស្មុគស្មាញនៅពេលគិតពីរឿងរ៉ាវនៅក្នុងសម័យខ្មែរក្រហម បន្ទាប់ពីជក់ធ្វើឲ្យគាត់បានធូរស្រាលក្នុងចិត្ត ។ នៅពេលដែល ឆ្វាត រំឭកដល់ព្រឹត្តិការណ៍នេះឡើងវិញ ការចងចាំទាំងប៉ុន្មានរបស់គាត់ប្រៀបបានការជក់បារីដែលទីបំផុតនៅសល់តែផេះផង់ប៉ុណ្ណោះ ។

បន្ទាប់ពី ឆ្វាត ចេញពីធ្វើការនៅសាលាខេត្ត យើងតែងតែជួបគ្នាជារៀងរាល់ល្ងាចនៅផ្ទះមិត្តភក្តិម្នាក់ ។ ក្រោមពន្លឺភ្លើងអគ្គិសនីព្រាលៗ យើងអង្គុយនៅជុំវិញតុមូលដែលមានទៀនមួយដើមនិងភ្លើងបារីរបស់ ឆ្វាត ដែលជះពន្លឺអាចឲ្យយើងមើលឃើញពីរូបរាងនិងស្រមោលរបស់គាត់ជាប់នៅនឹងជញ្ជាំង ។ នៅយប់នោះ ឆ្វាត បាននិយាយប្រាប់ខ្ញុំជាលើកដំបូងថា ក្នុងអំឡុងពេលដែលខ្មែរកំពុងធ្វើបន្សុទ្ធកម្មនៅឆ្នាំ១៩៧៧ បងប្រុសរបស់គាត់ក៏ត្រឡប់មករស់នៅវត្តភ្នំប្រុស ។ នៅពេលអ្នកភូមិដឹងថា ក្រុមគ្រួសាររបស់គាត់គឺជាអ្នកទីក្រុង ហើយបងប្រុសរបស់គាត់ឈ្មោះ ស្រួន ធ្លាប់ធ្វើការនៅក្រុមហ៊ុននីហរ័ណអាហរ័ណ ក្រុមគ្រួសាររបស់ ឆ្វាត ក៏វិលត្រឡប់ទៅរស់នៅភូមិកំណើតរបស់ឪពុកម្តាយវិញ ។ កំពុងនិយាយប្រកបដោយសំឡេងទន់ភ្លន់ គាត់ក៏ឈប់មួយស្របក់ ហើយគោះកំញមបារីចេញ ហើយបន្តថា បងប្រុស ស្រួន ត្រូវខ្មែរក្រហមនាំយកទៅកាន់វត្តមួយដែលបានកែប្រែទៅជាមណ្ឌលសម្លាប់វិញ ។

ពីដំបូងយើងឮថា រថយន្តបានមកដឹកប្រជាជនចេញពីសហករណ៍ដែលនៅជាប់គ្នាទៅរស់នៅ «ភូមិថ្មី» ។ ក្រោយមកក៏មានពាក្យចចាមអារ៉ាមថា ប្រជាជនទាំងនោះត្រូវបានបញ្ជូនទៅសម្លាប់ ។ រថយន្តជាច្រើនគ្រឿងបានមកដល់ភូមិរបស់ខ្ញុំដោយមិនបានប្រាប់ឲ្យដឹងមុនទេ ។ ប្រជាជនត្រូវបានដឹកចេញនៅពេលថ្ងៃ ។ យើងដឹងថា ដើមឆ្នាំ១៩៧៥ ជាពិសេសអ្នកដែលខ្ជិលធ្វើការងារ ឬមិនអាចធ្វើការធ្ងន់បាន អ្នកទាំងនោះត្រូវខ្មែរក្រហមបញ្ជាឲ្យទៅរស់នៅភូមិថ្មី ។ បងរបស់ខ្ញុំឈ្មោះ ស្រួន មិនត្រូវបានហៅឲ្យទៅធ្វើការងារទេ ព្រោះគាត់មានជំងឺនិងមិនអាចធ្វើការធ្ងន់ៗបាន គាត់ស្ទើរតែមិនជឿថាគាត់មានសំណាងល្អទេ ។ ឆ្វាត និយាយបន្តថា «ខ្ញុំពិតជាសំណាង ពីព្រោះខ្ញុំបានសាងល្អពីជាតិមុនបានជាខ្ញុំគេចផុតពីស្លាប់ និងថា ប្រជាជនទាំងនោះមិនត្រូវបាននាំទៅកាន់កន្លែងថ្មីទេ អ្នកទាំងនោះត្រូវបានសម្លាប់រួចហើយបោះសាកសពចោល» ។

នៅម៉ោង៨យប់នោះ បងស្រួន នៅតែមិនទាន់បានហៅឈ្មោះនៅឡើយ ។ គាត់ទើបតែនិយាយថា «ខ្ញុំរួចផុតពីគ្រោះថ្នាក់ហើយ ខ្ញុំមិនស្លាប់ទេ» ស្រាប់តែពេលនោះ សៀង ជាប្រធានភូមិបានមកគោះទ្វារហើយប្រាប់បង ស្រួន ថា «ប្រមូលអីវ៉ាន់របស់ឯងទៅ រថយន្តនឹងមកដឹកទៅភូមិថ្មី ។ បងស្រួន ឈប់និយាយហើយអង្គុយនៅលើគ្រែទាំងអារម្មណ៍ភ័យតក់ស្លុតនិងគិតអំពីហេតុការណ៍ដែលនឹងកើតឡើងចំពោះគ្រួសាររបស់គាត់ ។ នៅទីបញ្ចប់គាត់និយាយថា «ដូច្នេះឈ្មោះរបស់ខ្ញុំនៅក្នុងបញ្ជីដែរ» ។ ខ្ញុំ (ឆ្វាត) សង្ស័យថា ច្បាស់ជាមាននរណាម្នាក់ដែលជាបងប្អូនសាច់ឆ្ងាយរបស់ខ្ញុំជាភ្នាក់ងាររបស់ខ្មែរក្រហមឲ្យគេដាក់ឈ្មោះបង


សកម្មភាពរបស់អ្នកភូមិកំពុងបំពេញពាក្យបណ្តឹងនៅខេត្តព្រៃវែង

ប្រុសរបស់គាត់ជំនួសហើយមើលទៅ ។ បងស្រួន បានប្រាប់ប្រពន្ធនិងកូនៗរបស់គាត់ឲ្យត្រៀមខ្លួនចេញដំណើរ ។ គាត់ផ្តាំខ្ញុំថា «ថែរក្សាពុកនិងបងប្អូនរបស់យើងផង» ។ ចំពោះខ្ញុំៗមិនជឿថាពួកគេនាំខ្ញុំទៅកន្លែងថ្មីទេ ។ ពួកគេនាំយើងយកទៅសម្លាប់ ។ អ្វីៗនៅតែដដែល គ្មាននរណាម្នាក់ហ៊ាននិយាយ ។ ទាំងអស់គ្នាអាចឮសូរតែសំឡេងទឹកភ្លៀងប៉ុណ្ណោះ ។

ប្រជាជនដែលមានឈ្មោះត្រូវបានបញ្ជាឲ្យទៅជួបជុំគ្នានៅក្បែរវត្ត ។ ស្រួន បានពកូនប្រុសពៅរបស់គាត់ការពារកុំឲ្យត្រូវភ្លៀងនិងប្រឡាក់ភក់ ហើយប្រពន្ធរបស់គាត់ក៏នៅទីនោះដែរ ។ យប់ណាស់ទៅហើយ ដូច្នេះខ្មែរក្រហមបានបញ្ជាឲ្យប្រជាជនទាំងអស់សម្រាកនៅក្នុងវត្ត ។ កងឈ្លបបានការពារមិនឲ្យប្រជាជនចាកចេញពីបរិវេណនោះ ។ ក្មេងៗបានស្រែកយំដោយសារតែពួកវាឃ្លាន ។ ព្រឹកឡើង ខ្មែរក្រហមបានដឹកប្រជាជនតាមរថយន្តជាច្រើនគ្រឿងចេញទៅ ។ បងស្រួន និងគ្រួសាររបស់គាត់ត្រូវបានសម្លាប់នៅវត្តភ្នំប្រុស ។ ពីរ-បីថ្ងៃក្រោយមក សម្លៀកបំពាក់របស់គាត់ត្រូវបានយកមកចែកឲ្យប្រជាជននៅក្នុងភូមិដែលសម្លៀកទាំងអស់នោះជារបស់ប្រជាជនដែលបានដឹកចេញទៅតាមរថយន្ត ។ ខ្ញុំឃើញពួកគេ (ខ្មែរក្រហម) ចែកសម្លៀកបំពាក់បងប្រុសខ្ញុំ ។



ការចងចាំរបស់ ឆ្វាត ចំពោះការស្លាប់របស់បងប្រុសគាត់គឺជារឿងដែលហាក់ដូចជាកើតឡើងថ្មីៗ ពេលដែលយើងគិតទៅដល់ប្រជាជនរាប់លាននាក់នៅទូទាំងប្រទេសកម្ពុជាដែលប្រឈមនឹងការសម្លាប់ ការឈឺចាប់ និងភាពភ័យរន្ធត់នៅក្នុងរបបកម្ពុជាធិបតេយ្យ ដែលអ្នកទាំងអស់សុទ្ធតែទទួលអារម្មណ៍ក្តុកក្តួលបែបនេះ ។ ការចងចាំនិងអារម្មណ៍ឈឺចាប់នៅតែដក់ជាប់នៅក្នុងចិត្តប្រជាជនកម្ពុជា នៅខណៈដែលមានអ្នកនិពន្ធជាច្រើនបានសរសេរពីរបបកម្ពុជាប្រជាធិបតេយ្យឡើងវិញ ដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹង ។

ជំពូកនេះនឹងសិក្សាស្វែងយល់ពីវិសាលភាពមួយចំនួននៃការចងចាំ ជាពិសេសប្រជាជននៅក្នុងរបបសាធារណរដ្ឋខ្មែរនិងវៀតណាមដែលគាំទ្ររបបកម្ពុជាប្រជាធិបតេយ្យបានផ្សារភ្ជាប់ភាពស្របច្បាប់របស់ខ្លួន ដើម្បីលាតត្រដាងពីអំពើហិង្សាកាលពីអតីតកាល ។ បន្ថែមពីនេះ យើងអាចមើលឃើញយ៉ាងទូលំទូលាយក្នុងការផ្លាស់ប្តូរវិធីសាស្ត្រនៃការចងចាំនៅក្នុងប្រទេសកម្ពុជានៅអំឡុងពេលបោះឆ្នោតជាតិនៅឆ្នាំ១៩៩៣ ដែលគាំទ្រដោយអង្គការសហប្រជាជាតិ ។ ពេលនោះ អង្គការក្រៅរដ្ឋាភិបាលជាច្រើនបានរីកដុះដាលឡើងនៅក្នុងប្រទេសកម្ពុជានិងចាប់ផ្តើមពិភាក្សាទៅលើប្រធានបទនៃការផ្សះផ្សា សិទ្ធិមនុស្ស និងយុត្តិធម៌ដែលជានិច្ចកាលត្រូវបានផ្សារភ្ជាប់ទៅនឹងទ្រឹស្តីព្រះពុទ្ធសាសនាដើម្បីជាការចងចាំពីអំពើប្រល័យពូជសាសន៍អតីតកាល ។ ការផ្លាស់ប្តូរនេះអាចឲ្យយើងមើលឃើញម្តងទៀតជាមួយនឹងការកាត់សេចក្តីអតីតមេដឹកនាំខ្មែរក្រហមដែលគាំទ្រដោយអង្គការសហប្រជាជាតិនៅខែកក្កដា ឆ្នាំ២០០៦ ។ បន្ទាប់ពីមានការពិភាក្សាពីភាពពិតនៃការគ្រប់គ្រងរបស់របបសាធារណរដ្ឋខ្មែរស្តីពីចំណេះដឹង អំណាច និងការចងចាំ ខ្ញុំក៏ពិចារណាអំពីព្រះពុទ្ធសាសនាដែលបានផ្សារភ្ជាប់គ្នា និងជួនកាលមានលក្ខណៈដោយឡែកជាមួយនឹងការពិភាក្សាថ្នាក់រដ្ឋ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ។

## ជ័យជម្នះនិងភាពស្របច្បាប់

នៅខែមករា ឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមឈ្លានពានចូលប្រទេសកម្ពុជា បានធ្វើឲ្យខ្មែរក្រហមបែកបាក់ខ្ចាត់ខ្ចាយ ហើយការចងចាំក៏បានផ្លាស់ប្តូរម្តងទៀត ។ ផ្លូវថ្នល់នានាក្នុងកម្ពុជាពោរពេញទៅដោយមនុស្ស ដែលមួយចំនួនបានស្លាប់បាត់បង់ផ្ទះសម្បែង ខ្លះកំពុងស្វែងរកជម្រកថ្មី ខ្លះទៀតធ្វើដំណើរទៅព្រំដែននិងកន្លែងផ្សេងៗ ដែលខ្លួនមិនធ្លាប់បានស្គាល់ពីមុន ។

ប្រជាជនជាច្រើនក៏ដូចជា ឆ្វាត គ្មាននៅសេសសល់អ្វីទាំងអស់ ហើយត្រូវប្រឈមមុខនឹងបញ្ហាជាច្រើន ថាតើខ្លួនត្រូវរស់និងរៀបចំជីវិតដោយរបៀបណា ។ នៅទីបញ្ចប់ ឆ្វាត បានទទួលការងារធ្វើជាគ្រូបង្រៀន ។ នៅដើមពោធិ៍មួយដើម ភូមិនេះមានទីតាំងនៅក្បែរវត្តភ្នំប្រុសក្នុងខេត្តកំពង់ចាម ដែលគ្មាននៅសេសសល់អ្វីក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ហើយអតីតប្រជាជនដែលធ្លាប់រស់នៅក្នុងភូមិបានវិលត្រឡប់មកផ្ទះរបស់ខ្លួនវិញ ។ ជួនពេលអ្នកទាំងពីរកំពុងជួបជុំគ្នា ធ្វើឲ្យពួកគាត់នឹកឃើញអតីតកាលដ៏គួរឲ្យរន្ធត់ៈ រណ្តៅសាកសពជាច្រើន អណ្តូងទឹកនៅក្នុងភូមិពេញដោយសាកសព ហើយខ្យល់បក់បានជះក្លិនស្អុយចេញពីវត្ត ។ អ្នកទាំងនេះបានរំឭកពីអ្វីដែលខ្លួនដឹងច្បាស់ថា ដីស្រែចម្ការបច្ចុប្បន្នជារបស់គាត់ ហើយវាក៏នៅជាមួយនឹងវាលពិឃាដដែរ ពីព្រោះនៅពេលដែលគាត់ភ្ជួររាស់ម្តងៗ ឆ្អឹងនិងសម្លៀកបំពាក់របស់សាកសពតែងតែជាប់ជាមួយនង្គ័លជានិច្ច ។

នៅទីក្រុងភ្នំពេញ អ្នកថតរូបជនជាតិវៀតណាមពីរនាក់ដែលជាអ្នកអមដំណើរកងទ័ពឈ្លានពានបានដើរតាមក្លិនស្អុយរហូតទៅដល់បរិវេណនៃគុកទួលស្លែង ។ អ្វីដែលអ្នកទាំងនោះបានរកឃើញនៅខាងក្នុង គឺទិដ្ឋភាពដ៏គួរឲ្យខ្ពើមរអើម ។ អ្នកភូមិពោធិ៍ក៏បានរកឃើញថាៈ មានបុរសជាច្រើនត្រូវបានសម្លាប់ដោយអារបំពង់ក សាកសពមួយចំនួននៅជាប់ច្រវាក់ភ្ជាប់ទៅនឹងគ្រែដែក ហើយដេកនៅក្នុងថ្លុកឈាម និងឧបករណ៍ធ្វើទារុណកម្មជាច្រើនដូចជាខ្នោះ ខ្សែតី និងបន្ទប់ដាក់ទោសតូចៗ ។ ភ្លាមៗនោះ ក្រុមអ្នកស្រាវជ្រាវបានរកឃើញកន្លែងលាក់ឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ដែលរៀបតាមលំដាប់ចាប់ពីរូបថតរហូតដល់ចម្លើយសារភាព ។

នៅអំឡុងពេលនៃការផ្លាស់ប្តូរនេះ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលទើបតែបង្កើតថ្មី ក៏បានជួបប្រទះនូវបញ្ហាជាច្រើនរាប់ចាប់ពីផ្នែកសេដ្ឋកិច្ចរហូតដល់ហេដ្ឋារចនាសម្ព័ន្ធដែលស្ថិតក្នុងស្ថានភាពខ្ទេចខ្ទាំនិងគ្រោះទុរ្ភិក្ស ។ ពេលនោះ របបថ្មីនេះក៏ទទួលរងនូវបញ្ហាខាងផ្នែកច្បាប់ផងដែរ ។ រដ្ឋាភិបាលនៃរបបនេះដឹកនាំដោយលោក ហេង សំរិន មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជាមួយប្រទេសវៀតណាមដែលបានបញ្ជូនកងទ័ពចំនួន១៥ម៉ឺននាក់ដើម្បីឈ្លានពាន និងប្រើអំណាចគ្រប់គ្រងលើរបបថ្មីនេះ ។

ក្នុងពេលដែលគំនិតជួយផ្តួចផ្តើមរបស់វៀតណាមក្នុងការផ្តួលរំលំរបបខ្មែរក្រហម ធ្វើឲ្យប្រជាជនកម្ពុជាជាច្រើននៅមានមន្ទិលសង្ស័យចំពោះប្រទេសមួយនេះជាសត្រូវប្រវត្តិសាស្ត្រដែលប្រជាជនជឿជាក់ថាមានចេតនាជាយូរយារដើម្បីលេបយកទឹកដីកម្ពុជា ។ ប្រជាជនជាច្រើននៅតែមានការសង្ស័យថា របបថ្មីនេះប្រហែលជាដូចរបបកម្ពុជាប្រជាធិបតេយ្យដែរ ពីព្រោះទាំងអ្នកសង្គមនិយមនិងមនុស្សមួយចំនួនជាមន្ត្រីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលរួមមាន ហេង សំរិន និង រដ្ឋមន្ត្រីការបរទេសរបស់គាត់គឺលោក ហ៊ុន សែន ដែលត្រូវតែងតាំងជានាយករដ្ឋមន្ត្រីនៅឆ្នាំ១៩៨៥ គឺជាអតីតខ្មែរក្រហមដែលបានរត់គេចពីរបបកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងពេលនៃការបោសសម្អាតរបស់ខ្មែរក្រហម ។ ការមន្ទិលសង្ស័យទាំងនេះត្រូវបានឃោសនាឡើងដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលបានប្រកាសពីអ្នកសង្គមនិយមគួរឲ្យភ័យខ្លាចនៃរបបមុន ។ នៅទីបំផុតរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានគំរាមកំហែងកាន់តែខ្លាំងឡើងពីក្រុមអ្នកតស៊ូនិងកងទ័ពខ្មែរក្រហមដែលបង្កើតឡើងថ្មីៗ បន្ទាប់ពីការធ្វើដំណើរក្នុងស្ថានភាពដ៏លំបាកមកដល់ព្រំដែនថៃ ។ ក្រុមអ្នកតស៊ូទាំងនេះត្រូវបានគាំទ្រដោយបរទេសដែលផ្តោតសំខាន់ទៅលើនយោបាយសង្គ្រាមត្រជាក់ជាជាងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។

ការចងចាំត្រូវបានរួមបញ្ចូលជាមួយនឹងនយោបាយដូចដែលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានរៀបរាប់ពីរឿងរ៉ាវពីអតីតកាល ដែលនេះធ្វើឲ្យមានភាពស្របច្បាប់ទាំងនៅក្នុងស្រុកនិងនៅបរទេស ។ អំពើប្រល័យពូជសាសន៍បានឈរនៅចំកណ្តាលនៃប្រវត្តិសាស្ត្រ ។ នយោបាយថ្មីនៃរបបសាធារណរដ្ឋ

ប្រជាមានិតកម្ពុជាបានលាតត្រដាងពីការដឹកនាំមហាលោតផ្លោះ មហាអស្ចារ្យរបស់ ប៉ុល ពត, អៀង សារី និង ខៀវ សំផន ។ ដោយអនុវត្តយ៉ាងខ្ជាប់ខ្ជួនរបស់អ្នកកាន់លទ្ធិម៉ៅដែលដើរតាមមាគ៌ាសង្គមនិយម បានធ្វើឲ្យរឿងរ៉ាវនេះមានដំណើរការទៅមុខ ។ អ្នកដើរតាមលទ្ធិនេះបានប្រព្រឹត្តខុសនិងបង្ខំឲ្យកម្មាភិបាលខ្មែរក្រហមថ្នាក់ទាប រួមទាំងមេដឹកនាំរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (ដែលជាអតីតខ្មែរក្រហម) ឲ្យចូលរួមនៅក្នុងការឃោសនាពីភាពខុសឆ្គងនៃអំពើប្រល័យពូជសាសន៍ ។ ជាលទ្ធផល អតីតកម្មាភិបាលខ្មែរក្រហមភាគច្រើន អ្នកដែលពាក់ព័ន្ធ រួមទាំងមន្ត្រីសាធារណរដ្ឋប្រជាមានិតកម្ពុជាមិនទទួលខុសត្រូវចំពោះព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ។

សេចក្តីថ្លែងការណ៍របស់អ្នកសង្គមនិយមនៅតែសំខាន់ចំពោះការបរិយាយរឿងនេះដូចដែលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាលើកឡើងនៅពេលដែលចលនាបដិវត្តន៍បានដណ្តើមជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ជ័យជម្នះនេះបានធ្វើឲ្យប្រទេសកម្ពុជារួចផុតពីនឹមអាណានិគមនិយម ចក្រពត្តិនិយមនិងសក្តិភូមិនិយម ។ នៅក្នុងសុន្ទរកថាជាលើកដំបូងចំពោះការឈ្លានពាននេះ លោក ហេង សំរិន បានរៀបរាប់អំពីអំឡុងពេលដែលបនប្រតិកិរិយា ប៉ុល ពត-អៀង សារី ដឹកនាំប្រទេសកម្ពុជាតាមផ្លូវខុស ដែលភ្លាមៗនោះជ័យជម្នះរបស់គេផ្តើមចេញជាគោលការណ៍ជម្លៀសអ្នកទីក្រុងទៅជនបទ បង្ខំឲ្យរស់នៅជាសហករណ៍រួម លុបបំបាត់រូបិយវត្ថុ និងរិះគន់យ៉ាងខ្លាំងទៅលើការរស់នៅជាលក្ខណៈក្រុមគ្រួសារ និងជីវភាពរបស់អ្នកភូមិ ។ សកម្មភាពនេះជាសញ្ញាណបង្ហាញពីការសម្លាប់រង្គាលកាន់តែសាហាវឃោរឃៅនិងព្រៃផ្សៃដែលប្រព្រឹត្តដោយមនុស្សវ័យកណ្តាល ឬដោយពួកហ្វាស៊ីសហ៊ីទ្លែរនិយម ។ ត្រឡប់មកវិញ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានអះអាងថា របបនេះជាអ្នកបដិវត្តន៍ដ៏ពិតប្រាកដ មានការជួយជ្រោមជ្រែងពីវៀតណាមដែលជាបងប្អូនបានរំដោះប្រជាជនឲ្យរួចផុតពីឋាននរក ។ រឿងរ៉ាវនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលមានប្រជាជនជាខ្នងបង្អែកអាចធានាថា ភាពភ័យរន្ធត់នៃរបបកម្ពុជាប្រជាធិបតេយ្យមិនអាចវិលត្រឡប់មកវិញឡើយ ។ ជាមួយនឹងការកើនឡើងនៃអ្នកបដិវត្តន៍ខ្មែរក្រហមនៅតាមព្រំដែន តួនាទីនេះមានសារសំខាន់យ៉ាងខ្លាំងចំពោះប្រជាជននៅតាមទីជនបទ ។

នៅខណៈដែលរដ្ឋាភិបាលនីមួយៗឲ្យនិយមន័យខ្លួនទៅលើពាក្យអតីតកាលដែលស្រមើស្រមៃ អនាគតកាល និងរបបថ្មីជាពិសេសដូចជារបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានឡើងកាន់អំណាចដោយភាពស្របច្បាប់ដែលនៅតែមានមន្ទិលសង្ស័យនោះ បានបូជាកិច្ចខិតខំប្រឹងប្រែងដ៏ខ្លាំងក្លាដើម្បីសម្រេចបាននូវការស្រមើស្រមៃ ។ យន្តការក្នុងការបង្កើតការពិតមានច្រើនបែបខុសៗគ្នា រាប់ចាប់ពីការចងក្រងបង្កើតច្បាប់អប់រំណែនាំដើម្បីបង្កើតបូជនីយដ្ឋាននានា ។ តាមរយៈការបញ្ចូលស្ថាប័នផ្សេងៗគ្នា រដ្ឋាភិបាលអាចបង្កើតការសម្រេចចិត្តដ៏ពេញលេញមួយជា «ឧបករណ៍» ដើម្បីបំពេញគោលដៅជាយុត្តិសាស្ត្ររបស់ខ្លួនដូចជាការរៀបរាប់ដេញដោលពីប្រជាជនដែលជំរុញឲ្យការគ្រប់គ្រងនិងភាពស្របច្បាប់នេះកាន់តែមានភាពប្រសើរឡើង ។

យើងអាចមើលឃើញពីដំណើរការផ្សារក្នុងអំឡុងពេលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា រដ្ឋាភិបាលបានប្រើប្រាស់ស្ថាប័នចម្រុះដែលធ្វើឲ្យរចនាសម្ព័ន្ធគ្រប់គ្រងមានភាពធូររលុងនិងដើម្បីធ្វើឲ្យមានភាពស្របច្បាប់ ។ អ្វីដែលសំខាន់មួយទៀតនោះគឺការអប់រំ ព្រោះវាដើរតួនាទីជាអ្នករំពុកដល់ភាពសាហាវព្រៃផ្សៃនៃរបបកម្ពុជាប្រជាធិបតេយ្យចាប់តាំងពីខ្មែរក្រហមបានបោះបង់ចោលប្រព័ន្ធអប់រំជាផ្លូវការ ហើយប្រែក្លាយសាលារៀនជាច្រើនទៅជាមន្ទីរ គុកនិងកន្លែងផ្ទុកសម្ភារៈ ។ នៅពេលនោះដែររបបកម្ពុជាបជាធិបតេយ្យមានការអប់រំតែនៅថ្នាក់ដំបូងប៉ុណ្ណោះ ព្រោះខ្មែរក្រហមជឿជាក់ថា ប្រព័ន្ធអប់រំក្នុងរបបមុនធ្វើឲ្យខូចខួរក្បាលក្មេងៗ ហើយថាការអប់រំដែលល្អបំផុតនោះគឺការបញ្ចូលមនោគមន៍វិជ្ជានយោបាយនិងការរៀនសូត្រតាមរយៈ «ការតស៊ូ» លើផ្នែកសេដ្ឋកិច្ចដែលជាមាគ៌ាសំខាន់ ។ ដូច្នេះយោងតាមសុន្ទរកថាម៉ៅនិយម ខ្មែរក្រហមបានប្រកាសថា «ចបជីកជាប៊ិច វាលស្រែជាក្រដាស» ហើយប្រសិនបើចង់ «ប្រលងជាប់សញ្ញាប័ត្រអ្នកត្រូវកសាងទំនប់ជីកប្រឡាយ» ។

## ការបង្ហាត់បង្រៀនពីអំពើប្រល័យពូជសាសន៍អតីតកាល

ភាពវិនាសហិនហោចនៃអតីតកាលក៏ជាសញ្ញាណរូបសាស្ត្រ

នៃការខ្ទេចខ្ទាំសាលារៀននិងសម្ភារៈផ្សេងៗ ដែលជានិមិត្តរូបបញ្ជាក់ពីការបាត់បង់ដ៏ធំធេងរបស់កម្ពុជា (នៅក្រោមរបបខ្មែរក្រហម) ហើយនៅក្នុងករណីជាច្រើនតាមរយៈស្លាកស្នាមជញ្ជាំងដែលធ្លុះធ្លាយដោយសារគ្រាប់កាំភ្លើង (ដែលបង្ហាញពីនិមិត្តរូបនៃអំពើហិង្សាពីអតីតកាលនិងគ្រោះថ្នាក់នៃបច្ចុប្បន្ន) ។ ម្យ៉ាងវិញទៀត ការសិក្សាអប់រំបានបង្ហាញពីសមិទ្ធផលមួយក្នុងចំណោមសមិទ្ធផលធំៗជាច្រើនទៀតរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលបានស្តាបនាប្រព័ន្ធសាលារៀនយ៉ាងឆាប់រហ័ស ។ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៩ ក្នុងសុន្ទរកថាបុណ្យខួបរំឭកថ្ងៃនៃការផ្តើមឲ្យមានសាលារៀនសម្រាប់ឆ្នាំសិក្សា១៩៧៩ ដល់ឆ្នាំ១៩៨០ លោក ហេង សំរិន បានលើកពីប្រធានបទនានា ដោយសង្កត់ធ្ងន់ទៅលើអំពើប្រល័យពូជសាសន៍ដ៏ឃោរឃៅរបស់បន ប៉ុល ពត និង អៀង សារី ដែលហេដ្ឋារចនាសម្ព័ន្ធនៅក្នុងវិស័យអប់រំនិងការបង្ហាត់បង្រៀនត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង ជាពិសេសការសម្លាប់អ្នកដែលបានទទួលការអប់រំខ្ពង់ខ្ពស់ ក្នុងនោះមានសិស្ស និស្សិត និងគ្រូបង្រៀនជាដើម ។

នៅក្នុងសុន្ទរកថាខ្លីទាំងនេះត្រូវបានបញ្ចូលទៅក្នុងឯកសារបង្រៀន ដូចជានៅក្នុងសៀវភៅរៀនថ្នាក់ទីបួនដែលបោះពុម្ពដោយក្រសួងអប់រំក្នុងឆ្នាំ១៩៨៣ សៀវភៅនោះមានរួមបញ្ចូលកំណាព្យដែលមានចំណងជើងថា «ការឈឺចាប់របស់ប្រជាជនកម្ពុជានៅក្នុងអំឡុងពេលរបបប៉ុល ពត អៀង សារី» ដែលរចនាឡើងដោយមានគំនូរមួយបង្ហាញពីប្តីប្រពន្ធមួយគូត្រូវបានសម្លាប់នៅខណៈពេលដែលកុមារាម្នាក់បានឃើញភាពរន្ធត់ដែលបុរសម្នាក់កំពុងត្រូវបានព្យួរក ។ ដូចនៅក្នុងសៀវភៅអប់រំសីលធម៌ដែលបោះពុម្ពនៅក្នុងឆ្នាំ១៩៨៤ ក៏មានបញ្ចូលមេរៀនស្តីពីបដិវត្តន៍ថ្មីបានផ្តល់ភាពសុខសាន្តទៅឲ្យប្រជាជនដោយមានភ្ជាប់ជាមួយរូបគំនូរបង្ហាញពីភាពសប្បាយរីករាយរបស់ប្រជាជនក្នុងការអបអរសាទរចំពោះកងទ័ព និងបង្ហាញពីផែនការឧក្រិដ្ឋកម្មរបស់បន ប៉ុល ពត, អៀង សារី ក្នុងការបំបាត់ពូជសាសន៍ ក្នុងនោះមានភ្ជាប់រូបគំនូរប្រជាជនដែលត្រូវបានសម្លាប់នៅក្នុងរណ្តៅសាកសពដ៏ធំមួយ ដោយកម្មាភិបាលខ្មែរក្រហមដែលមានស្នាមប្រឡាក់ឈាមជាប់នឹងចបនិងព្រនង់ ។ បន្ទាប់ពីរៀបរាប់រួចមានសំណួរជាច្រើនត្រូវបានលើកឡើងមកពិភាក្សានៅក្នុងថ្នាក់ ។ សំណួរទាំងនោះគឺ

១) តើអំពើឧក្រិដ្ឋកម្មបែបណាដែលបន ប៉ុល ពត អៀង សារី ធ្វើមកលើប្រជាជនកម្ពុជា?

២) តើពួកវាបានសម្លាប់ខ្មែរតាមវិធីណាខ្លះ?

៣) តើគោលបំណងបែបណាដែលពួកបនទាំងនេះសម្លាប់ជនជាតិខ្មែរ?

ការបញ្ចូលមេរៀនទាំងអស់នេះនៅក្នុងកម្មវិធីសិក្សា បានផ្តល់នូវចម្លើយទៅឲ្យក្មេងអាយុ៥-៦ឆ្នាំ តាមរយៈការពិពណ៌នាពីអំពើសម្លាប់ដ៏សាហាវបំផុតរបស់ខ្មែរក្រហម ដូចជាការជីករណ្តៅធំៗ ប្រឡាយជ្រៅៗ ដើម្បីកប់ជនរងគ្រោះទាំងរស់ បន្ទាប់ពីអ្នកទាំងនោះបានទទួលរងទារុណកម្មយ៉ាងវេទនាដោយចប ដំបង និង ពូថៅ ។ សៀវភៅសិក្សាសរសេរថា ស្ត្រីនិងកុមារមិនត្រូវបានទុកជីវិត ដែលគោលបំណងរបស់ខ្មែរក្រហមគឺដើម្បីសម្លាប់និងបំផ្លាញប្រជាជនកម្ពុជាដើម្បីឲ្យជាតិសាសន៍រលាយសាបសូន្យ ។ សៀវភៅសិក្សាបែបនេះគូសបញ្ជាក់ខុសគ្នាអំពីបន ប៉ុល ពត, អៀង សារី ថា អ្នកទាំងពីរមិនមែនជាជនជាតិខ្មែរ គឺជាសត្រូវដ៏គ្រោះថ្នាក់ក្នុងការបំផ្លាញពូជសាសន៍កម្ពុជានិងជាពួកកុម្មុយនីស្ត


បុគ្គលិករបស់មជ្ឈមណ្ឌលកំពុងជួយបំពេញពាក្យបណ្តឹងអ្នកភូមិ នៅខេត្តព្រៃវែង

ប្រតិកិរិយា ។

តាមរយៈការអានសៀវភៅសិក្សាទាំងនេះ យើងអាចរកឃើញភាគច្រើនបំផុតអំពីការរៀបរាប់រឿងរ៉ាវដែលមានខ្លឹមសាររួមជាមួយរូបថតនិងផ្ទាំងគំនូរផ្សព្វផ្សាយ ដែលរូបភាពទាំងនេះផ្តោតសំខាន់អំពីការពិតនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដូចជា ការពិពណ៌នាដដែលៗអំពីភាពសាហាវយង់ឃ្នង និងអំពើឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយបនប៉ុលពត-អៀងសារី និងមហាសោកនាដកម្មរបស់ប្រជាជន និងការអះអាងថា បនប្រល័យពូជសាសន៍ទាំងនេះខ្វះលក្ខណៈជាខ្មែរ គឺសង្គមនិយមប្រតិកិរិយា និងការប្រកាសពីចំណងមិត្តភាពយូរអង្វែងកម្ពុជា-វៀតណាម ។ ការកោតសរសើរពីមហាជ័យជម្នះនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ និងដំណើរការជឿនលឿនរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាដែលបង្កើតបានសមិទ្ធផល ហើយនិងបង្ហាញយ៉ាងច្បាស់ពីសមិទ្ធផលរបស់កងទ័ពនិងយោធានៃសាធារណប្រជាមានិតកម្ពុជាដែលបានការពារប្រជាជនឲ្យរួចផុតពីការវិលត្រឡប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ អត្ថបទសម្រាប់ថ្នាក់ទី៤ បោះពុម្ពផ្សាយនៅក្នុងឆ្នាំ១៩៨៨ ដែលខ្ញុំបានជួបនោះ គឺផ្តោតសំខាន់ទៅលើប្រធានបទទាំងអស់នេះ និងភាគច្រើនទៀតទាក់ទងនឹងអត្ថបទតាមលំដាប់រៀងៗគ្នានៅទួលស្លែងគឺ «ការធ្វើទារុណកម្មនៅទួលស្លែង» ជាមួយនឹងរូបភាពអ្នកទោសស្លាប់ទាំងជាប់ខ្នោះដែកនៅក្នុងថ្កុកឈាមនិងឧបករណ៍ធ្វើទារុណកម្មផ្សេងទៀត ។

## ការចងចាំនូវរបបប្រល័យពូជសាសន៍អតីតកាល

ឥឡូវនេះយើងបានរកឃើញទំនាក់ទំនងមួយទៅនឹងផ្នែកផ្សេងទៀតនៃការពិតនិងការចងចាំរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ផ្ទុយគ្នានឹងការផ្តោតទៅលើការរៀបរាប់នៃសៀវភៅសិក្សារបស់សាលា ការចងចាំនៃរបបនេះ ដូចជានៅទួលស្លែង និងវាលពិឃាតជើងឯកបញ្ឆោក់ពីនិមិត្តរូបនេះ ។

សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងដែលត្រូវបានសម្ពោធនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨០ ស្ថាបនាឡើងដើម្បីបង្កើតនូវអារម្មណ៍យថាភាពដែលហាក់បីដូចជាយើងបានមើលឃើញពីទិដ្ឋភាពនោះមួយភ្លែត ក្រោយពេលដែលវាបានបញ្ឈប់ដំណើរការ ។ អារម្មណ៍នេះកើតឡើងភ្លាមៗនិងពោរពេញដោយកម្លាំងដែលបង្កប់អត្ថន័យសំខាន់លើអគារទី១ក្នុងចំណោមអគារទាំងបួន ដែលអ្នកទស្សនាបានជួបប្រទះ និងជាកន្លែងដែលអ្នកទស្សនាបានចូលទៅដល់ ហាក់ដូចជានៅក្នុងបន្ទប់សួរចម្លើយដែលអ្នកទោសចុងក្រោយត្រូវបានសម្លាប់យ៉ាងសាហាវនិងស្នាមឈាមប្រឡាក់ជាប់ឥដ្ឋដែលមើលឃើញយ៉ាងច្បាស់ ។ បន្ទប់នីមួយៗរួមមានរូបថតដ៏ធំរបស់អ្នកទោសដែលត្រូវបានសម្លាប់បន្ទាប់ពីខ្មែរក្រហមបានបោះបង់ចោលមន្ទីរសន្តិសុខនេះដោយគ្មានបន្សល់ទុកអ្វីទាំងអស់ ។ អគារទីពីររួមមានរូបថតអ្នកទោសព្យួរលើជញ្ជាំងបន្តគ្នាដែលបានថតនៅពេលអ្នកទោសទាំងនោះមកដល់ទួលស្លែង ។ ទឹកមុខនៅក្នុងរូបថតនីមួយៗបង្ហាញពីអារម្មណ៍ស្ទើរតែគ្រប់ប្រភេទ ប៉ុន្តែរូបថតទាំងអស់នេះមើលទៅគួរឲ្យភ័យខ្លាច ។ ក្នុងនាមជាអ្នកទស្សនាដែលបានមើលឃើញរួចមកហើយនៅក្នុងអគារទី១គឺដឹងយ៉ាងច្បាស់អំពីជោគវាសនារបស់អ្នកទាំងនោះ ។

នៅក្នុងអគារទីបី អ្នកទស្សនាបានរកឃើញបន្ទប់រៀនត្រូវបានបែងចែកទៅជាបន្ទប់ឥដ្ឋតូចៗដែលមានអ្នកទោសត្រូវបានដាក់ខ្នោះនិងមានកេសគ្រាប់សម្រាប់ឲ្យអ្នកទោសបន្ទោរបង់ដោយខ្លួនឯង ។ វិន័យសន្តិបាលរបស់ខ្មែរក្រហមចំពោះអ្នកទោសបានសរសេរបិទនៅលើជញ្ជាំងអគារថា «អ្នកទោសត្រូវតែសុំការអនុញ្ញាតមុននឹងធ្វើអ្វីមួយ» ។ អគារចុងក្រោយគឺធ្វើឲ្យយើងនឹកឃើញដល់សារមន្ទីរបុរាណមួយដែលមានឧបករណ៍នៅក្នុងទូកញ្ចក់សេសសល់ពីរបបខ្មែរក្រហម ដោយរៀបចំជាជួរចាប់ពីឧបករណ៍ធ្វើទារុណកម្មរហូតដល់រូបសំណាករបស់ ប៉ុល ពត ដែលត្រូវបានស្ថាបនាឡើងនៅក្នុងបរិវេណនេះ ។ អគារនេះមានអត្ថបទសរសេរច្រើនជាងអគារផ្សេងទៀត ប៉ុន្តែក៏នៅមានរូបគំនូរមួយចំនួនបង្ហាញយ៉ាងច្បាស់ពីឧបករណ៍ដែលនៅសេសសល់និងរូបគំនូររបស់ខ្មែរក្រហមដែលគូរដោយ វ៉ាន់ ណាត ជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខនេះ ។ ទោះបីជាមានការរៀបចំដូចខាងលើរួចហើយក្តីក៏រហូតមកដល់ពេលថ្មីនេះមានការតាំងពិព័រណ៍ដែលគួរឲ្យចាប់អារម្មណ៍ខ្លាំងបំផុតនៅក្នុងបន្ទប់ចុងក្រោយដែលមានផែនទីប្រទេសកម្ពុជាទំហំ១២ម៉ែត្រការ៉េតម្រៀបដោយលលាដ៍ក្បាលចំនួន៣០០ យកមកពីខេត្តនានានៅទូទាំងប្រទេសកម្ពុជាជាមួយផ្លូវទឹកដែលជាត់ពណ៌ក្រហម ។ ***(នៅមានត)*** **អាឡិច ហ៊ីនតុន**

# ពិធីរំឭកខួបកងទ័ពបដិវត្តន៍កម្ពុជា

## *សុន្ទរកថារបស់ នួន ជា នៅក្នុងពិធីរំឭកខួបកងទ័ព*

*អត្ថបទដកស្រង់ចេញពីសុន្ទរកថារបស់ នួន ជា ប្រធានសភាតំណាងប្រជាជន គណៈកម្មាធិការអចិន្ត្រៃយ៍ និងជានាយករដ្ឋមន្ត្រីក្នុងពិធីបុណ្យរំឭកខួបកងទ័ពបដិវត្តន៍កម្ពុជាដែលប្រារព្ធធ្វើឡើងនៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៧ ។*

*នៅក្នុងឱកាសនេះ និងនៅក្រោមកាលៈទេសៈបច្ចុប្បន្ន ខ្ញុំចង់ធ្វើការកត់សម្គាល់សំខាន់ពីរ ។ ទីមួយគឺពិធីបុណ្យរំឭកខួបកងទ័ពលើកទី៩ ដើម្បីធ្វើឲ្យយើងគ្រប់គ្នានឹកទៅដល់វីរភាពដ៏អង់អាចក្លាហានរបស់កងទ័ពបដិវត្តន៍យើង ។ នៅខណៈនេះ យើងមានអារម្មណ៍យ៉ាងជ្រាលជ្រៅនិងគិតទៅដល់ទឹកចិត្តរបស់ទ័ពបដិវត្តន៍ដែលរួមស្លាប់រស់ជាមួយគ្នា ការតស៊ូប្រយុទ្ធរបស់យុទ្ធមិត្តប្រុស-ស្រី និងកម្មាភិបាលកងទ័ពរបស់យើងដែលបានបូជាចំពោះបដិវត្តន៍ដ៏ពិបាក ស្មុគស្មាញ សាំញ៉ាំ ជាមួយនឹងការតស៊ូបដិវត្តន៍រហូតរំដោះប្រទេសកម្ពុជាទាំងស្រុង ផ្តល់សេរីភាពដល់ប្រជាជន កម្មករ និងកសិករ ព្រមទាំងនាំយកមកឲ្យពួកគេនូវភាពជាម្ចាស់ប្រទេស និងវាសនារបស់គេផ្ទាល់ ។*

*ចំណុចទីពីរ យើងគួរតែពិចារណាទៅលើឱកាសនេះ គឺថានៅពេលយើងគិតទៅដល់ទ័ពពីមុនដែលមានតែដៃទទេនិងស្ថានភាពបច្ចុប្បន្ន យើងគួរតែពេញចិត្តដោយនឹកស្មានមិនដល់ថា យើងនឹងមានកងទ័ពបដិវត្តន៍បច្ចុប្បន្នដែលមានចរិតលក្ខណៈជាកងទ័ពបដិវត្តន៍ដ៏ពិតប្រាកដ អង់អាចក្លាហាន មានសមត្ថភាព និងជាទ័ពដ៏អស្ចារ្យមានភាពស្មោះត្រង់ចំពោះអង្គការបដិវត្តន៍ មានប្រជាជនកម្មករ កសិករ អំណាចប្រទេស និងមាតុភូមិជាទីស្រឡាញ់របស់យើង ។ កងទ័ពបដិវត្តន៍របស់យើងត្រូវបានបង្កើត ពង្រឹង ពង្រីក និងប្រែក្លាយពីកងការពារសម្ងាត់ទៅជាកងឈ្លប កងតំបន់ និងកងប្រចាំការដែលអាចធ្វើសង្គ្រាមឈ្លប សង្គ្រាមជាទ្រង់ទ្រាយធំ សង្គ្រាមផ្ទៃក្នុង ហើយនិងសង្គ្រាមបដិវត្តន៍ប្រឆាំងនឹងចក្រពត្តិអាមេរិក និងបរិវារដើម្បីរំដោះជាតិ ប្រជាជន រហូតដល់ថ្ងៃដែលយើងទទួលបានមហាជោគជ័យនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។*

*យើងក៏បានពង្រឹងនិងអភិវឌ្ឍកងទ័ពនេះដោយបំពាក់ស្មារតីនយោបាយ មនោគមន៍វិជ្ជា និងការរៀបចំសមូហភាព ។ បច្ចុប្បន្ន កងទ័ពរបស់យើងមានចរិតលក្ខណៈជាកងទ័ពបដិវត្តន៍ពិតប្រាកដ មានការរៀបចំចាត់តាំងគ្រប់បែបយ៉ាង ទាំងជើងគោក ទាំងជើងទឹក ទាំងជើងអាកាសដែលការពារប្រទេសទាំងព្រំដែនគោក ទាំងព្រំដែនជើងទឹក ទាំងព្រំដែនអាកាសកម្ពុជាទាំងមូល ។ អស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ មិនដែលមានកងទ័ពណាអាចប្រៀបផ្ទឹមនឹងកងទ័ពនៅពេលបច្ចុប្បន្ននេះបានឡើយ ។ ជាក់ស្តែង យើងពិតជាមានមោទនភាពនិងសេចក្តីសោមនស្សរីករាយចំពោះប្រជាជនយើង កងទ័ពយើង និងអង្គការ បដិវត្តន៍យើងដែលបានធ្វើការតស៊ូយ៉ាងយូរ ដើម្បីកសាងកម្ពុជាប្រជាធិបតេយ្យសម្រាប់ប្រជាជនកម្ពុជា កម្មករ កសិករ កម្លាំងបដិវត្តន៍របស់ប្រទេស សេចក្តីក្លាហាន និងកងទ័ពបដិវត្តន៍ដែលមានសមត្ថភាព ។*



*យោធាខ្មែរក្រហម*

ដើម្បីតបស្នងសងគុណចំពោះកងទ័ព យើងទាំងអស់គ្នាមិនថានៅទីនេះឬនៅខាងក្រៅត្រូវតែសច្ចាចំពោះខ្លួនឯងថានឹងចងចាំនូវចលនាតស៊ូរបស់យើង និងដើម្បីឲ្យប្រជាជនយើងប្រកាន់យកនូវប្រពៃណីតស៊ូដ៏អង់អាចក្លាហានរបស់វីរជនដែលបានប្រយុទ្ធយ៉ាងប្តូរផ្តាច់ពីអតីតកាល ដោយបន្តអនុវត្តការងារបដិវត្តន៍របស់ពួកគេដ៏ត្រឹមត្រូវ និងខិតខំបំពេញការងារការពារប្រទេសនិងកសាងប្រទេសឲ្យល្អបំផុត ។ ប្រសិនបើយើងអាចបំពេញការងារនេះដោយមានការយកចិត្តទុកដាក់និងទទួលខុសត្រូវខ្ពស់មានន័យថា យើងទាំងអស់គ្នាកំពុងតបស្នងសងគុណចំពោះវីរជនយើងដោយសមរម្យនិងពេញលេញ ។ ការធ្វើបែបនេះ គឺជាការតាំងចិត្តរបស់យើង ។

នៅក្នុងឱកាសនេះ យើងក៏បានតាំងចិត្តពង្រឹងនិងពង្រីកការងារបដិវត្តន៍របស់យើង ។ នៅរាល់សកម្មភាពនិងការងារមិនថាតូចឬធំ យើងត្រូវតែមានទឹកចិត្តតស៊ូ ព្រមទាំងថែរក្សាឆន្ទៈដែលជាកិច្ចខំប្រឹងប្រែងរបស់យើង ។ យើងត្រូវតែប្រើប្រាស់ការសច្ចាចំពោះវីរជនយើងជាកិច្ចខំប្រឹងប្រែងដើម្បីបង្កើនសីលធម៌របស់យើង ។ យើងមានភាពរឹងមាំ ប៉ុន្តែកិច្ចខំប្រឹងប្រែងនេះរឹតតែធ្វើឲ្យយើងកាន់តែមានភាពរឹងមាំថែមទៀត ។



ហេតុអ្វីបានជាយើងបំពេញការងារបដិវត្តន៍នៅសម័យថ្មី? យើងធ្វើដើម្បីលុបបំបាត់ទាសករដែលមានជាច្រើនសតវត្សរ៍មកហើយ ។ យើងបានរំដោះប្រទេសឲ្យរួចផុតពីភាពជាទាសករនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយប្រជាជនយើងមានសេរីភាពចាប់ពីពេលនោះមក ។ ចុះហេតុអ្វីបានជាយើងគួរតែបន្តអនុវត្តការងាររបស់យើងឲ្យមានលក្ខណៈត្រឹមត្រូវទៀត? យើងធ្វើកិច្ចការនេះដើម្បីការពារកម្ពុជាប្រជាធិបតេយ្យ កម្មករ-កសិករកម្ពុជា សហករណ៍ នៅទសវត្សរ៍ក្រោយ សតវត្សរ៍ក្រោយ សហសវត្សរ៍ក្រោយ មួយម៉ឺនឆ្នាំក្រោយ និងជារៀងរហូត ។ យើងធ្វើដើម្បីកសាងកម្ពុជាប្រជាធិបតេយ្យមហាលោតផ្លោះមហាអស្ចារ្យ ។ នេះគឺជាហេតុផលដែលធ្វើយើងគួរអនុវត្តកិច្ចការនេះ ។

តើនេះគឺជាកិត្តិយសឬទេ? មែនហើយ វាគឺជាកិត្តិយសរបស់យើង ។ ជ័យជម្នះដ៏មហាអស្ចារ្យនៃថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បាននាំយកកិត្តិយសដ៏ធំធេងទៅឲ្យប្រទេសជាតិ ប្រជាជននិងកងទ័ពដែលយើងត្រូវតែការពារ ពង្រឹង ពង្រីក និងទប់ស្កាត់មិនឲ្យមានភាពខូចខាតឬបាត់បង់ ។ ដូច្នេះ ការបំពេញកិច្ចការងាររបស់យើង គោលបំណងទីមួយសំដៅលើការតបស្នងសងគុណដល់វីរជនតស៊ូប្រុស-ស្រី ព្រមទាំងកម្មាភិបាលដែលស្លាប់បាត់បង់ជីវិត ។ ទីពីរ សំដៅលើការការពារកិត្តិយសរបស់ប្រទេសជាតិនិងប្រជាជនជារៀងរហូត ។

ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ គឺជាថ្ងៃកំណើតរបស់កងទ័ពបដិវត្តន៍កម្ពុជា ។ នៅដើមឆ្នាំ១៩៦៧ ជនក្បត់ លន់ នល់ ធ្វើសង្គ្រាមផ្ទៃក្នុង ជិះជាន់ បាញ់ និងសម្លាប់ប្រជាជនស្លូតត្រង់ អ្នកស្នេហាជាតិកម្ពុជា និងអ្នកបដិវត្តន៍ជាច្រើននាក់ដែលមានចរិតសាហាវនិងជាប្រព័ន្ធ ។ ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ គឺជាថ្ងៃដែលកងការពារសម្ងាត់បដិវត្តន៍របស់យើងប្រែក្លាយទៅជាកងទ័ពដែលបានរៀបចំ បន្ទាប់មក កងទ័ពឈ្លបទាំងនោះត្រូវបានអង្គការបដិវត្តន៍របស់យើងបញ្ជាឲ្យវាយប្រហារទីតាំងសត្រូវនៅតាមប្រាំងស៊ីងសង្កែដែលមានចម្ងាយ១១គីឡូម៉ែត្រពីក្រុងបាត់ដំបងវាយកម្ទេចទីតាំងឃុំបាយដំរាំ ក្នុងស្រុកបាណន់បានទាំងស្រុង រឹប

អូសសព្វាវុធរបស់សត្រូវមកឲ្យកងទ័ពរបស់យើង ។ នេះគឺជាការវាយប្រហារដំបូងរបស់កងទ័ពយើង ។

ការចាប់ផ្តើមតស៊ូប្រដាប់អាវុធនៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ មិនមែនជាព្រឹត្តិការណ៍ចៃដន្យទេ ។ តាំងពីឆ្នាំ១៩៦០ អង្គការបដិវត្តន៍កម្ពុជារបស់យើងបានរៀបចំយុទ្ធសាស្ត្រនិងយុទ្ធវិធីដើម្បីបដិវត្តន៍ជាតិប្រជាធិបតេយ្យ ។ យើងដឹងថា ពួកចក្រពត្តិអាមេរិក បនបរិវារ និងគ្រប់វណ្ណៈជិះជាន់របស់ពួកគេបានប្រើប្រាស់អំណាចផ្តាច់ការ និងការបង្ខិតបង្ខំដើម្បីសម្លាប់និងបំភ័យប្រជាជនយើង ។ នេះគឺជាកិច្ចការដែលយើងបានរៀបចំយ៉ាងម៉ត់ចត់ព្រោះថា សកម្មភាពនយោបាយតែមួយមិនអាចកម្ទេចនិងទម្លាក់ពួកចក្រពត្តិអាមេរិក បនបរិវារ និងគ្រប់វណ្ណៈជិះជាន់របស់វាបានទេ ។ សត្រូវបានប្រើប្រាស់កម្លាំងទ័ព និង ឧបករណ៍នយោបាយដើម្បីគាបសង្កត់និងសម្លាប់ប្រជាជនយើង ។ បន្ទាប់ពីឆ្នាំ១៩៦០ អង្គការបដិវត្តន៍របស់យើងបានសម្រេចចិត្តថា ត្រូវតែប្រើប្រាស់សកម្មភាពនយោបាយនិងកងទ័ពដែលមោះមុតដើម្បីវាយដណ្តើមនិងកម្ទេចសត្រូវ ។ យើងត្រូវតែប្រែក្លាយកម្លាំងបដិវត្តន៍ឲ្យទៅជាកងទ័ពបដិវត្តន៍ ។ បន្ទាប់ពីឆ្នាំ១៩៦១ យើងបានចាប់ផ្តើមរៀបចំកងការពារសម្ងាត់របស់យើង ។

កងការពារសម្ងាត់ទាំងនេះបានលាក់ខ្លួននៅក្នុងភូមិ តាមមូលដ្ឋាននិងទីប្រជុំជននានា ។ ទ័ពទាំងនោះខ្លះប្រដាប់ដោយកាំភ្លើង ប៉ុន្តែភាគច្រើនប្រដាប់ដោយកាំបិត ដំបង និងដុំថ្ម ។ កងការពារសម្ងាត់ទាំងនេះមានតួនាទីការពារកម្មាភិបាលនិងប្រជាជនដែលវាយកម្ទេចភ្នាក់ងារខ្មាំងនិងកងកម្លាំងសត្រូវផ្សេងទៀតដែលបានបង្កបញ្ហាដល់ប្រជាជន ។

ទ័ពការពារសម្ងាត់មួយចំនួនបានបាត់បង់ជីវិត ហើយទ័ពខ្លះទៀតត្រូវបានសត្រូវចាប់ខ្លួន ។ ប៉ុន្តែអ្នកតស៊ូរបស់យើងនៅតែបន្តបំពេញតួនាទីជាអ្នកការពារសម្ងាត់ដើម្បីធានាសន្តិសុខដល់កម្មាភិបាល ការិយាល័យ និងកន្លែងជួបប្រជុំរបស់យើងព្រមទាំងបម្រើតួនាទីជានិរសារ ។ ការងារទាំងនេះគឺជាការងារគ្រោះថ្នាក់ ។ កម្មាភិបាលរបស់យើងត្រូវតែផ្លាស់ប្តូរពីភូមិមួយទៅភូមិមួយដើម្បីអនុវត្តការងារ ។ បើមិនមានអ្នកការពារសម្ងាត់កម្មាភិបាលរបស់យើងប្រហែលជាមិនមានជីវិតទេ យើងទាំងអស់គ្នាប្រហែលជាត្រូវសត្រូវសម្លាប់ចោលបាត់អស់ហើយ ។ កងការពារសម្ងាត់របស់យើងស៊ើបដំណឹងពីស្ថានភាពនៅក្នុងភូមិ-ឃុំ ទីបញ្ជាការសត្រូវនិងទីបញ្ជាការកងកម្លាំងប៉ូលីស ។ កងការពារសម្ងាត់របស់យើងក៏បានបម្រើតួនាទីជាអ្នកនាំផ្លូវ និងអនុវត្តការងារចាំបាច់របស់កងទ័ពយើង ។ កងការពារសម្ងាត់របស់យើងតែងតែស្ម័គ្រចិត្តតាមការពារកម្មាភិបាលរបស់យើងទៅគ្រប់ទីកន្លែង ។

ពីមួយឆ្នាំទៅមួយឆ្នាំ យើងបានពង្រីកកងការពារសម្ងាត់របស់យើង ។ តាំងពីឆ្នាំ១៩៦១ ដល់ឆ្នាំ១៩៦៦ អ្នកបដិវត្តន៍របស់យើងបានបោះទីតាំងនៅទូទាំងប្រទេស ហើយកងការពារសម្ងាត់របស់យើងមាននៅគ្រប់តំបន់ ។ កងនីមួយៗមានសមាជិកចំនួន៣នាក់ ហើយកងការពារសម្ងាត់ទាំងនេះគឺជាទ័ពសំខាន់របស់យើង ។

ថ្ងៃកំណើតនៃកងទ័ពបដិវត្តន៍របស់យើងនៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ មិនមែនកើតឡើងដោយចៃដន្យឬប្រឌិតទេ ។ ថ្ងៃនោះជាថ្ងៃចាប់ផ្តើមជ័យជម្នះនិងចលនាតស៊ូជាប្រព័ន្ធ ដោយមានយុទ្ធសាស្ត្រនិងយុទ្ធវិធី ។ បន្ទាប់ពីកងការពារសម្ងាត់បានចាប់កំណើតឡើង កងទាំងនេះត្រូវបានប្រែក្លាយទៅជាកងឈ្លបដែលចាប់ផ្តើមការប្រយុទ្ធជាលើកដំបូងនៅខេត្តបាត់ដំបង ហើយបើកការវាយលុកនិងធ្វើសង្គ្រាមឈ្លបនៅទូទាំងប្រទេស សត្រូវមិនមានលទ្ធភាពតស៊ូនឹងកងកម្លាំងរបស់យើងទេ ។ តើព្រឹត្តិការណ៍នេះពិតជាកើតឡើងដោយចៃដន្យ ឬក៏ជាការវាយប្រហារដោយមិនមានយុទ្ធសាស្ត្រនិងគម្រោងជាមុន? សត្រូវអាចនឹងកម្ទេចយើងយ៉ាងរហ័ស ប៉ុន្តែការពិតសត្រូវមិនអាចធ្វើបានទេ ពីព្រោះនៅឆ្នាំ១៩៦៨ ទោះបីជាយើងមិនបានរឹបអូសកាំភ្លើងពីសត្រូវក៏ដោយក៏កត្តាតាំងចិត្តដើម្បីវាយលុកសត្រូវដោយមិនមានអាវុធ និងការចូលរួមទាំងអស់គ្នានៅក្នុងការវាយលុកប្រឆាំងនឹងសត្រូវអាចធ្វើឲ្យយើងទទួលបានជ័យជម្នះ ។

ដូចដែលខ្ញុំទើបតែបាននិយាយមុននេះ នៅខែទីមួយយើងបានវាយប្រហារសត្រូវនៅទិសពាយ័ព្យ ហើយនៅខែទីពីរយើងបន្តទៅដល់ទីតាំងសត្រូវនៅទិសនិរតី ។ សត្រូវមិនអាចដឹងគ្នានៅទិសពាយ័ព្យបានទេ ពីព្រោះយើងក៏វាយប្រហារកងទ័ពនេះនៅ

ទិសនិរតីដែរ ។ នៅពេលដែលការតស៊ូប្រដាប់អាវុធចាប់ផ្តើមវាយប្រហារនៅទិសបូព៌ាសត្រូវត្រូវតែដកទ័ពខ្លះទៅការពារខ្សែប្រយុទ្ធនៅខាងចុងទិសបូព៌ាដែរ ហើយនៅពេលដែលយើងវាយលុកដល់ទិសឦសាន សត្រូវក៏នឹងដកទ័ពទៅការពារនៅទីនោះទៀតបន្ទាប់មកបន្តទៅទិសឧត្តរ ។

នៅខែមេសា ឆ្នាំ១៩៦៨ កងឈ្លបរបស់យើងកំពុងធ្វើសង្គ្រាមឈ្លបនៅ១៧ខេត្ត ក្នុងចំណោមខេត្តទាំង១៩របស់ប្រទេស ។ នៅក្រោមកាលៈទេសៈនេះ តើកងទ័ពសត្រូវអាចវាយប្រហារកងឈ្លបយើងនៅទូទាំងប្រទេសវិញបានឬទេ? ទេ សត្រូវពិតជាមិនអាចវាយប្រហារយើងទេ ។ មានតែកងកម្លាំងយើងទេដែលអាចធ្វើការវាយប្រហារ ។ ហេតុអ្វីបានជាសត្រូវមិនអាចកម្ទេចយើង? ពីព្រោះតែយើងមានអង្គការដែលបានរៀបចំជាប្រព័ន្ធ មានន័យថាកងទ័ពរបស់យើងមានយុទ្ធសាស្ត្រដែលបានគ្រោងទុកនិងមានយុទ្ធវិធីជាមូលដ្ឋាន ដូចជាការបង្កើតកងសម្ងាត់ជាដើម ។ ការងារនេះត្រូវបានអនុវត្តដោយជោគជ័យព្រមទាំងអភិវឌ្ឍប្រទេសបច្ចុប្បន្នផងដែរ ។

កងទ័ពដែលចូលរួមចលនាបដិវត្តន៍ទាំងនេះបច្ចុប្បន្នមានអំណាចខ្លាំងក្រៃលែង ។ ពីមុនយើងមិនមានអាវុធគ្រប់គ្រាន់ ហើយទ័ពរបស់យើងមានចំនួនតិចតួច ប៉ុន្តែការចូលរួមធ្វើសង្គ្រាមរបស់ប្រជាជនដែលបានរៀបចំឡើងដោយត្រឹមត្រូវធ្វើឲ្យយើងមានភាពរឹងមាំ ។ ប្រជាជនដែលបានដើរតាមមាគ៌ាដ៏ត្រឹមត្រូវរបស់អង្គការបានចូលរួមគ្រប់ដំណើរការរបស់កងសម្ងាត់ស្ម័គ្រចិត្តចូលរួមចលនាបដិវត្តន៍ បានយល់ដឹងពីយុទ្ធសាស្ត្រសង្គ្រាមឈ្លបរបស់អង្គការបដិវត្តន៍យើង ។ អ្នកទាំងនេះគឺជាមេដឹកនាំរបស់កងទ័ពនិងកងឈ្លបយើងនៅថ្ងៃអនាគត ហើយក៏ជាអ្នកសំខាន់សម្រាប់កងទ័ពយើងដែរ ។

កងទ័ពនេះមិនមែនមកពីកងយោធាដែលបានហ្វឹកហ្វឺនច្បាស់លាស់ទេ គឺចេញមកពីចលនាតស៊ូបដិវត្តន៍ដែលចាប់ផ្តើមដោយដៃទទេ ។ អ្នកទាំងអស់នេះបានចូលរួមជាមួយអង្គការ បដិវត្តន៍ ព្រមទាំងបានយល់ដឹងពីដំហររបស់អង្គការ ។ យើងវាយប្រហារសត្រូវដោយដៃទទេ រឹបអូសកាំភ្លើង ឬក៏កាំភ្លើងខ្លីដែលធ្វើនៅក្នុងស្រុក ។ នេះគឺជារបៀបដែលយើងចាប់ផ្តើមវាយសត្រូវ ។ កងទ័ពរបស់យើងមានភាពរឹងមាំ ។ កងទ័ពដែលវាយសត្រូវដោយប្រើកាំភ្លើងធំ និងគ្រឿងយុទ្ធភណ្ឌមិនមែនជាទ័ពខ្លាំងទេ ។

កងទ័ពដែលចាប់ផ្តើមដោយដៃទទេ ព្រមទាំងបានតស៊ូ បដិវត្តន៍ដោយជោគជ័យ និងអភិវឌ្ឍខ្លួនឯងបន្តិចម្តងៗ គឺជាទ័ពដែលមានអំណាចខ្លាំង ។ នេះគឺជាប្រវត្តិសាស្ត្ររបស់កងទ័ពយើង ។

យើងត្រូវតែយល់ដឹងពីធម្មជាតិពិតនិងលទ្ធផលនៃបដិវត្តន៍របស់យើង ។ នៅពេលដែលយើងទទួលបានជ័យជម្នះលើពួកចក្រពត្តិអាមេរិក យើងមិនមាននាវាឬក៏រថក្រោះអ្វីទេ ។ ចំពោះកាំភ្លើងធំវិញ យើងមានតែបន្តិចបន្តួចប៉ុណ្ណោះដែលបានរឹបអូសមកពីសត្រូវ ។ កងទ័ពនេះមិនមានយន្តហោះ រថក្រោះ ឬក៏កាំភ្លើងធំដែលជាអាវុធយុទ្ធភណ្ឌទេ ។ ប៉ុន្តែការប្រយុទ្ធរបស់យើងទទួលបានជ័យជម្នះដ៏អស្ចារ្យ ។ យើងត្រូវតែចងចាំពីភាពរឹងមាំរបស់កងទ័ពនេះ ។ ហេតុអ្វីបានជាកងទ័ពនេះមានភាពរឹងមាំ? វាគឺជាមនោគមន៍វិជ្ជា គោលនយោបាយ និងអង្គការរឹងមាំ ព្រមទាំងយុទ្ធសាស្ត្រប្រយុទ្ធត្រឹមត្រូវដែលធ្វើឲ្យទ័ពនេះមានភាពរឹងមាំ ។ យល់ដឹងពីប្រវត្តិសាស្ត្ររបស់កងទ័ពធ្វើឲ្យយើងដឹងពីឥទ្ធិពលនិងអំណាចរបស់ទ័ពបដិវត្តន៍យើង ។ ប្រសិនបើយើងពង្រឹងនិងពង្រីកកងទ័ពទៅតាមនិន្នាការនេះ ពិតជាគ្មានសត្រូវណាអាចយកជ័យជម្នះបានឡើយ ។ កងទ័ពរបស់យើងមិនបានប្រឆាំងឈ្លានពានទៅលើប្រទេសដទៃទេ ។ ប៉ុន្តែក្នុងករណីដែលមានការឈ្លានពានពីប្រទេសដទៃ ទ័ពនិងប្រជាជនរបស់យើងអាចធ្វើការតបតវិញដោយមិនកំណត់ថាប៉ុន្មានឆ្នាំទេ ហើយប្រកាន់ខ្ជាប់តាមមាគ៌ារបស់បក្ស ។ ប្រសិនបើយើងមានយន្តហោះ កប៉ាល់ រថក្រោះ ឬកាំភ្លើងធំ ប៉ុន្តែមិនមានការចូលរួមធ្វើសង្គ្រាមរបស់ប្រជាជននិងយុទ្ធសាស្ត្ររបស់កងទ័ពអង្គការបដិវត្តន៍ទេនោះ យើងនឹងមិនមានកងទ័ពរឹងមាំដូចដែលបានតស៊ូប្រឆាំងពួកចក្រពត្តិអាមេរិក ហើយមិនអាចរឹងមាំទេពេលដែលយើងមិនមានយន្តហោះ រថក្រោះនិងកប៉ាល់ ។ អាស្រ័យលើហេតុផលទាំងនេះ យើងត្រូវតែចងចាំការវាយប្រហាររបស់យើងប្រឆាំងនឹងពួកចក្រពត្តិអាមេរិក ។

តើនេះជាទីបញ្ចប់នៃតួនាទីរបស់កងទ័ពយើងឬទេ? តើកងទ័ពនេះគួរតែបន្តអនុវត្តការងារនេះឬទេ? គុណសម្បត្តិរបស់កងទ័ពយើងបានឈានមកដល់ដំណាក់កាលនេះ តើយើងគួរតែ

បញ្ឈប់នៅចំណុចនេះឬក៏បន្ត? យើងគួរតែមានមោទនភាពនិងពេញចិត្តចំពោះគុណសម្បត្តិរបស់កងទ័ពយើង ។ យើងត្រូវតែព្យាយាមកសាង ពង្រឹង ពង្រីក និងអភិវឌ្ឍទ័ពយើង ព្រមទាំងធ្វើឲ្យមានលទ្ធភាពការពារនិងកសាងប្រទេសថែមទៀត ។

បទពិសោធន៍ពីអតីតកាលបង្ហាញថា យើងបានប្រកាន់យកបដិវត្តន៍របស់យើង ការរំដោះជាតិ ការងារការពារ និងការកសាងប្រទេសត្រូវបានធ្វើឡើងដោយស្មារតីជឿទុកចិត្តខ្ពស់ ។ នៅអំឡុងពេលដែលមានសង្គ្រាមបំផ្លិចបំផ្លាញដោយពួកចក្រពត្តិអាមេរិកកាលពី៥ឆ្នាំមុន យើងមានលទ្ធភាពដោះស្រាយបញ្ហាសេដ្ឋកិច្ច ។ យើងមិនដែលនាំអង្ករចូលទេ ។ យើងអាចធានាឲ្យមានអាហារគ្រប់គ្រាន់ ។ បន្ទាប់ពីសង្គ្រាម យើងបានជួបប្រទះបញ្ហាលំបាកខ្លះ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ បញ្ហាទាំងនេះត្រូវបានដោះស្រាយទាំងអស់ ។ បន្ទាប់មក យើងមានបញ្ហាផ្សេងទៀត ។ តើយើងអាចដោះស្រាយបានទេ? តើយើងបានបំពេញគម្រោងនៅឆ្នាំ១៩៧៦ឬទេ? តើយើងមានលទ្ធភាពអនុវត្តតាមបញ្ញត្តិឲ្យចែករបបអាហាររបស់ប្រទេសបានឬទេ? ទីមួយ គឺចែកអង្ករ៣០គីឡូក្រាមទៅឲ្យប្រជាជនម្នាក់ក្នុងមួយខែ ទីពីរ គឺចែក២៥គីឡូក្រាម ទីបីចែកអង្ករ២០គីឡូក្រាម ។ យោងទៅតាមរបាយការណ៍ដែលមកពីគ្រប់តំបន់នៅដើមខែ និងការយល់ដឹងបន្ទាប់ពីចុះធ្វើទស្សនកិច្ចនៅតាមមូលដ្ឋាន យើងដឹងថា បញ្ញត្តិចែកអាហារនេះមានលក្ខណៈត្រឹមត្រូវ ។ និយាយជារួម ប្រជាជនកម្ពុជាម្នាក់ៗមានអង្ករ៣១២គីឡូក្រាមសម្រាប់ហូបរាល់ឆ្នាំដែលនេះជាចំនួនច្រើន ។ ស្ថានភាពរស់នៅរបស់ប្រជាជនយើងមានភាពរីកចម្រើនបន្តិចម្តងៗ ។ មានន័យថា ប្រជាជនយើងមានរបបអាហារគ្រប់គ្រាន់សម្រាប់ហូប ។ យើងបានបម្រុងទុកស្រូវពីរតោសម្រាប់ប្រជាជនម្នាក់ៗនៅឆ្នាំ១៩៧៧ ។ នៅពេលជាមួយគ្នានេះ យើងមានស្រូវ១៥ម៉ឺនតោនទៀតសម្រាប់នាំចេញ ។ នេះមានន័យថាយើងបានបំពេញគម្រោងនៅឆ្នាំ១៩៧៦បានដោយជោគជ័យ ។

ផលិតផលកៅស៊ូបានកើនឡើងយោងទៅតាមគម្រោងឆ្នាំ១៩៧៦ ផលិតផលគ្រាប់ពូជនិងដំណាំឧស្សាហកម្មផ្សេងទៀតក៏កើនឡើងដែរ ។ ទាំងអស់នេះជាសមិទ្ធផលរបស់ប្រជាជនដែលបានតស៊ូលំបាកជាច្រើនបណ្តាលមកពីការបំផ្លិចបំផ្លាញដោយសារសង្គ្រាម ។ យើងត្រូវតែការពារទំនៀមទម្លាប់និងមុខតំណែងនេះដោយធ្វើការពង្រឹងនិងពង្រីកការងារនេះដើម្បីកសាង និងការពារជាតិ ។ ទៅអនាគត នៅពេលដែលយើងប្រមូលបានបទពិសោធន៍ច្រើន នោះភាពរឹងមាំរបស់យើងនឹងកើនឡើងជាបន្តបន្ទាប់ ។

ស្ថានភាពបដិវត្តន៍របស់ប្រជាជនកម្ពុជាមានការរីកចម្រើនហើយកាន់តែមានភាពរឹងមាំឡើង ព្រមទាំងអភិវឌ្ឍទៅមុខលើគ្រប់វិស័យ ។ នេះជាស្ថានភាពបច្ចុប្បន្ន និងជោគជ័យរបស់បដិវត្តន៍ប្រជាជនកម្ពុជានៅឆ្នាំ១៩៧៧ ដែលមានលក្ខណៈល្អប្រសើរជាងឆ្នាំ១៩៧៦ ។ សូមឲ្យយុទ្ធមិត្តប្រុស-ស្រីដែលតស៊ូប្រយុទ្ធនៅតាមសមរភូមិនិងកម្មាភិបាលកងទ័ពបដិវត្តន៍មិនថានៅលើគោកឬលើទឹក មានសុខភាពល្អ និងទទួលបានជោគជ័យនូវរាល់ភារកិច្ចថ្មីៗរបស់បដិវត្តន៍យើង ដើម្បីការពារនិងកសាងកម្ពុជាប្រជាធិបតេយ្យ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ការចូលរួមរបស់ជនរងគ្រោះ

នៅអំឡុងឆ្នាំ២០០៨មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលបំណងចង់ឲ្យជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងតិច ១០,០០០នាក់ ចូលរួមបំពេញពាក្យបណ្តឹង (ជាឧក្រិដ្ឋកម្ម ឬជាដើមបណ្តឹងរដ្ឋប្បវេណី) មុនពេលចូលទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញពីសកម្មភាពនេះថាជាការជួយដល់ប្រជាជនសាមញ្ញកម្ពុជាឲ្យចូលរួមក្នុងដំណើរការនាំយកមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យទៅកាត់ទោសនៅមុខច្បាប់និងដំណើរការមួយទៀតនូវ «គណៈកម្មការស្វែងរកការពិត» ជាលក្ខណៈមិនសូវផ្លូវការដែលគណៈកម្មការនេះបានចាប់ផ្តើមតាំងពីអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៨០ម៉្លេះ ដោយការចុះហត្ថលេខាលើញត្តិរណសិរ្ស ។

សម្រាប់ព័ត៌មានលម្អិតសុំទំនាក់ទំនង លោក ជី ទេរិទ្ធិ តាមរយៈលេខទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។

# របាយការណ៍ពីខេត្តពោធិ៍សាត់ : គម្រោងចូលរួមរបស់ជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការខ្មែរក្រហម

## ១) ប្រវត្តិការស្រាវស្តីពីគម្រោងចូលរួមរបស់ជនរងគ្រោះ ក្នុងខេត្តពោធិ៍សាត់

ខេត្តពោធិ៍សាត់មានព្រំដែនខាងលិចជាប់ប្រទេសថៃ ខាងជើងឆៀងខាងលិចជាប់ខេត្តបាត់ដំបង ខាងកើតជាប់ខេត្តកំពង់ឆ្នាំង ខាងជើងជាប់បឹងទន្លេសាប និងខាងត្បូងជាប់ខេត្តកំពង់ស្ពឺ និងខេត្តកោះកុង មានផ្ទៃដីសរុប១២,៦៩២គីឡូម៉ែត្រការ៉េ ។ ខេត្តនេះមាន៦ស្រុក គឺស្រុកបាកាន កណ្តៀង ក្រគរ ភ្នំក្រវាញ សំពៅមាស និងវាលវែង មានចម្ងាយ១៨៧គីឡូម៉ែត្រនៅទិសពាយ័ព្យទីក្រុងភ្នំពេញ និងមានប្រជាជនសរុបចំនួន៣៦០,៤៤៥នាក់ ។

នៅឆ្នាំ១៩៧៦ ខេត្តពោធិ៍សាត់ស្ថិតនៅក្នុងភូមិភាគនិរតី ។ យោងទៅតាមរបាយការណ៍ ដោយផ្អែកលើញត្តិរណសិរ្ស ប្រជាជនស្លាប់ទាំងអស់នៅក្នុងខេត្តពោធិ៍សាត់មានចំនួន៩៤,៧៥២នាក់ ។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនជាច្រើនត្រូវបានជម្លៀសពីភូមិភាគបូព៌ាទៅកាន់ខេត្តពោធិ៍សាត់ (ពិសេសខេត្តស្វាយរៀង) ហើយប្រជាជនភាគច្រើនត្រូវបានសម្លាប់ ។ នៅខែកុម្ភៈ ឆ្នាំ២០០៨ គម្រោងគូសផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញទីតាំងសម្លាប់ចំនួន១៧កន្លែង (មានរណ្តៅជាង១.០០០កន្លែងនិងសាកសពប្រមាណ២១.០០០) គុក១១កន្លែង និងបូជនីយដ្ឋាន២កន្លែងនៅក្នុងខេត្តនេះ ។

ខេត្តពោធិ៍សាត់មានសារសំខាន់សម្រាប់ការងារគម្រោងចូលរួមរបស់ជនរងគ្រោះក្នុងការដាក់ពាក្យបណ្តឹង ។ ទីមួយ មានបញ្ជីឈ្មោះរបស់អ្នកភូមិជាច្រើននៅលើញត្តិរណសិរ្សពីឆ្នាំ១៩៨២ដល់១៩៨៣ ដែលរក្សាទុកនៅបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលដូច្នេះ វាអាចផ្តល់ព័ត៌មានដ៏សំខាន់អំពីបែបបទដុំវិញការចុះហត្ថលេខាលើញត្តិ ។ ដុយពីញត្តិដែលបានប្រមូលនៅក្នុងខេត្តកំពង់ធំ ញត្តិដែលទទួលបានពីខេត្តពោធិ៍សាត់មានហត្ថលេខាជាបុគ្គល


សកម្មភាពរបស់អ្នកភូមិកំពុងស្តាប់ការពន្យល់អំពីដំណើរការតុលាការ នៅខេត្តពោធិ៍សាត់

ដែលធ្វើឲ្យយើងយកចិត្តទុកដាក់ចំពោះអ្នកធ្វើញត្តិ ដូច្នេះ ធ្វើឲ្យយើងខិតខំប្រឹងប្រែងដើម្បីទាក់ទងជាមួយនឹងអ្នកធ្វើញត្តិដែលមានចំនួនច្រើនលើសលប់ក្នុងរយៈពេលបំពេញការងារ ។ ទីពីរ ខេត្តពោធិ៍សាត់ក៏មានសហគមន៍ខ្មែរកម្ពុជាក្រោមមួយចំនួនដែលជាសមាជិកអាចផ្តល់ព័ត៌មានដ៏មានប្រយោជន៍ដើម្បីគាំទ្រដល់ការកាត់ទោសអំពើប្រល័យពូជសាសន៍ ។

## ប្រវត្តិនៃញត្តិរណសិរ្សនៅខេត្តពោធិ៍សាត់

មជ្ឈមណ្ឌលរក្សាទុកនូវឯកសាររបស់ខ្លួនដែលហៅថា "ញត្តិរណសិរ្ស" នេះ ។ នៅអំឡុងឆ្នាំ១៩៨២-១៩៨៣ រដ្ឋាភិបាលក្រោយរបបខ្មែរក្រហមបានប្រមូលញត្តិចំនួន១.២៥០ ដែលរៀបរាប់លម្អិតពីឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលប្រព្រឹត្តលើប្រជាជនខ្មែរជាង១លាន១សែននាក់ ។ តាមគម្រោង យើងនឹងប្រើញត្តិទាំងនេះដើម្បីស្វែងរកអ្នកដាក់ពាក្យបណ្តឹងនិងដើមបណ្តឹងរដ្ឋប្បវេណីជាសំខាន់។ ធ្វើដូច្នេះ គម្រោងនឹងបង្កើតឡើងវិញនូវគណៈកម្មការស្វែងរកការពិតមិនផ្លូវការមួយដែលចាប់ផ្តើមបង្កើតដោយរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ យើងបានបង្ហាញដល់អ្នកធ្វើញត្តិថា ចម្លើយជាសក្ខីភាពមុនមិនត្រូវបានបំភ្លេចទេ គម្រោងនេះនឹងរួមចំណែកក្នុងដំណើរការផ្សះផ្សាជាតិ ។ ទោះបីជាគម្រោងផ្តោតសំខាន់ទៅលើការស្វែងរកនិងជួយដល់អ្នកធ្វើញត្តិក៏ដោយ ក៏ក្រុមនេះមានបំណងជួយដល់អ្នកនៅរស់ឲ្យចាប់អារម្មណ៍ក្នុងការបំពេញទម្រង់បែបបទព័ត៌មានជនរងគ្រោះរបស់តុលាការដែរ ។

មជ្ឈមណ្ឌលមានញត្តិចំនួន៨៤០មកពីខេត្តពោធិ៍សាត់ ដែលបានចុះហត្ថលេខាឬក៏ផ្តិតមេដៃដោយបុគ្គលម្នាក់ៗ សរុបទាំងអស់៩៨.០០០នាក់ ។ ជាធម្មតា អ្នកតំណាងម្នាក់ឬពីរនាក់បានសរសេរញត្តិមួយតំណាងឲ្យក្រុមធំមួយដែលមានមនុស្សពី១០០ទៅ៣០០នាក់ ហើយបុគ្គលម្នាក់ៗបានចុះហត្ថលេខាឬផ្តិតមេដៃទៅលើញត្តិ (ក្នុងករណីខ្លះមានមុខរបរហើយនិងការអធិប្បាយផងដែរ) ។ ដូច្នេះ មិនដូចជានៅខេត្តកំពង់ធំទេ ញត្តិមកពីខេត្តពោធិ៍សាត់ មានឈ្មោះ ហត្ថលេខា ឬក៏ស្នាមមេដៃរបស់បុគ្គលម្នាក់ៗជាតំណាង ។

## ២) ការងាររបស់គម្រោងចាប់ពីថ្ងៃទី២២-២៩ ខែឧសភា

### ក) គោលបំណង

គោលបំណងនៃគម្រោងនេះ គឺដើម្បីផ្តល់ព័ត៌មានដល់អ្នកនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យអំពីសិទ្ធិចូលរួមរបស់ពួកគាត់ក្នុងដំណើរការក្តីនៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជួយពួកគាត់ក្នុងការបំពេញទម្រង់បែបបទ បើសិនជាគាត់មានបំណងចង់ចូលរួម ។ គម្រោងនេះបានស្វែងរក និងជួបប្រជាជននៅក្នុងខេត្តដែលបានធ្វើញត្តិរណសិរ្សនៅក្នុងឆ្នាំ១៩៨២-១៩៨៣ ។ ជាងនេះទៅទៀត គម្រោងចង់ស្វែងរកសមាជិកនៃសហគមន៍កម្ពុជាក្រោមដើម្បីប្រមូលព័ត៌មានដែលអាចជួយគាំទ្រដល់ការដាក់បន្ទុកទៅលើអំពើប្រល័យពូជសាសន៍ ។ គោលបំណងមួយទៀត គម្រោងបានគិតទៅដល់វគ្គបណ្តុះបណ្តាលរបស់ខ្លួននាពេលថ្មីៗ (ពិសេសទាក់ទងនឹងការកែប្រែទម្រង់បែបបទឲ្យកាន់តែប្រសើរឡើង) ដើម្បីយកមកអនុវត្ត ។

### ១) ការរៀបចំសម្រាប់ការចុះទៅតាមខេត្ត

ចាប់តាំងពី៣សប្តាហ៍មុនចុះទៅខេត្តកំពង់ធំ គម្រោងបានផ្តល់ការបណ្តុះបណ្តាលដល់សមាជិកក្រុមជាបន្តបន្ទាប់ ។ រយៈពេលនៃវគ្គបណ្តុះបណ្តាលនេះ គឺផ្តោតសំខាន់ទៅលើចំណុចខ្វះខាតមួយចំនួនដែលគម្រោងធ្លាប់ជួបប្រទះនៅខេត្តកំពង់ធំកន្លងមក និងការណែនាំពីអង្គភាពជនរងគ្រោះនៃតុលាការខ្មែរក្រហម ។ នៅក្នុងខែមេសា ឆ្នាំ២០០៨ គម្រោងនេះបានទទួលព័ត៌មានពីអង្គភាពដែលទាក់ទងនឹងការកែប្រែទម្រង់បែបបទព័ត៌មានជនរងគ្រោះ ។ ចំណុចដែលគួរឲ្យចាប់អារម្មណ៍ គឺការដាក់បញ្ចូលសំណួរទាក់ទងទៅនឹងវិធានការការពារខ្លួន និងតំណាងស្របច្បាប់ដែលមិនបានដាក់បញ្ចូលពីមុនមក ។ ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់ដល់សមាជិកក្រុម លោក ជី ទេរិទ្ធិ (អ្នកដឹកនាំក្រុម) និង សារ៉ា ថូម៉ាស់ (សហការីច្បាប់) ក៏បានដឹកនាំវគ្គបណ្តុះបណ្តាលនេះ ។

នៅថ្ងៃទី១៩-២០ ខែឧសភា តាមរយៈគម្រោងឯកសាររស់បាននាំយកអ្នកដាក់ពាក្យបណ្តឹងមកទីក្រុងភ្នំពេញ ដើម្បីចូលរួមសវនាការបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី២១ ។ អ្នកដាក់ពាក្យបណ្តឹងទាំងនោះមកពីខេត្តកំពង់ធំ ខេត្តកំពង់ចាម និងខេត្តព្រះវិហារ ។ រយៈពេល២ថ្ងៃនៃសវនាការ គម្រោងប្រមូលបានពាក្យបណ្តឹងចំនួន២៣ ។

នេះជាឱកាសដ៏មានសារប្រយោជន៍សម្រាប់សមាជិកក្រុមធ្វើការពន្យល់ដល់ពួកគាត់អំពីសិទ្ធិដើម្បីស្នើសុំវិធានការការពារខ្លួន និងតំណាងស្របច្បាប់មុនពេលគាត់ត្រឡប់ទៅពោធិ៍សាត់វិញ ។

### គ) ដំណើរការនាពេលថ្មីៗ

មុនពេលចេញដំណើរ គម្រោងបានជួបប្រជុំជាច្រើនលើកជាមួយអង្គភាពជនរងគ្រោះដែលធ្វើកិច្ចការនេះ ។ នៅថ្ងៃទី៩ ខែឧសភា អ្នកស្រី ក្រូស អិនគ្រា (គម្រោងចុះផ្សព្វផ្សាយ) បានប្រជុំជាមួយអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការងារលើគម្រោងចូលរួមរបស់ជនរងគ្រោះស្តីពីការបង្កើតឲ្យមានសេវាជួយដល់អ្នកដែលនៅរស់ ។ គោលបំណងនៃការបង្កើតនេះ គឺដើម្បីផ្តល់ព័ត៌មានដល់អ្នកដែលនៅរស់ពីសិទ្ធិចូលរួមដំណើរការនីតិវិធី និងណែនាំពួកគាត់ឲ្យទាក់ទងជាមួយអង្គការក្នុងតំបន់ដែលអាចជួយគាត់បាន ។ ជាពិសេស អ្នកស្រី ក្រូស មានគម្រោងថតផ្សាយតាមវិទ្យុជា «ឈុតខ្លីៗ» ដើម្បីផ្សព្វផ្សាយគម្រោងដែលផ្តោតទៅលើអ្នកដែលនៅរស់ពីគុកទួលស្លែង និងសមាជិកគ្រួសារដែលជាប់គុកនៅទីនោះ ។ លោកស្រីក៏បានស្នើសុំឲ្យអង្គការក្រៅរដ្ឋាភិបាលផ្សព្វផ្សាយពី «ឈុតខ្លីៗ» នៅក្នុងកម្មវិធីវិទ្យុរបស់គេដែរ ។ ទោះបីជាមានការសហការបែបនេះក្តី គម្រោងនេះនៅតែមិនទាន់បានភ្ជាប់ការខិតខំប្រឹងប្រែងចូលរួមរបស់ជនរងគ្រោះជាមួយនឹងកម្មវិធីវិទ្យុរបស់មជ្ឈមណ្ឌលនៅឡើយទេ ។

នៅថ្ងៃទី១២ និងថ្ងៃទី២១ ក្រុមគម្រោងបានជួបជាមួយអង្គភាពជនរងគ្រោះដើម្បីពិភាក្សាអំពីរយៈពេលសម្រាប់បញ្ជូនចម្លើយទៅដល់អ្នកដាក់ពាក្យបណ្តឹង ដើមបណ្តឹងរដ្ឋប្បវេណី និងនីតិវិធីសម្រាប់បំពេញទម្រង់បែបបទដែលមិនទាន់បំពេញចប់ដាក់ទៅអង្គភាពជនរងគ្រោះ ។ គាត បូផល (ប្រធាន) និង ហ្គាប្រៀឡា ហ្គូនសាឡេស រីវ៉ាស់ (អនុប្រធាន) បានថ្លែងថា ប្រព័ន្ធសម្រាប់ឆ្លើយតបត្រូវបានដាក់ឲ្យប្រើប្រាស់ក្នុងពេលឆាប់ៗ ហើយអង្គភាពនឹងផ្តល់ឲ្យក្រុមគម្រោងនូវក្រដាសព័ត៌មានថតចម្លងដែលមិនទាន់បំពេញចប់ និងរាល់ចំណុចព័ត៌មានដែលខ្វះខាត ។

### ឃ) សេចក្តីលម្អិតនៃការរៀបចំនិងបុគ្គលិក

ក្រុមគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងបានស្នាក់នៅក្នុងផ្ទះសំណាក់មួយក្នុងទីរួមខេត្តពោធិ៍សាត់នៅអំឡុងពេលបំពេញការងារ ។ ដំណើរការនេះមានរយៈពេល៨ថ្ងៃ ចាប់ផ្តើមពីថ្ងៃទី២២ ដល់ថ្ងៃទី២៩ ខែឧសភា ។ បុគ្គលិក១៦នាក់ រួមទាំងបុគ្គលិក៤នាក់ខាងថតខ្សែភាពយន្តបានចូលរួមបំពេញកិច្ចការនេះ ។

មុនពេលបំពេញការងារ បុគ្គលិកគម្រោងបានជ្រើសរើសយកភូមិដែលមាន ១) ញត្តិរណសិរ្ស ឬ ២) សហគមន៍កម្ពុជាក្រោម ។

## លទ្ធផលការងារ

### ក) លទ្ធផលការងារនៅក្នុងឆមាស

នៅអំឡុងពេលបំពេញការងារ ក្រុមគម្រោងបានចុះទៅស្រុកចំនួន៤ក្នុងចំណោមស្រុកទាំង៦ នៅក្នុងខេត្តពោធិ៍សាត់ ។ ក្រុមគម្រោងបានរៀបចំកិច្ចប្រជុំក្នុងភូមិចំនួន១៥ នៃឃុំ៧ផ្សេងគ្នា ជាពិសេសបានផ្តល់ព័ត៌មានដល់អ្នកនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យស្តីពីសិទ្ធិចូលរួមរបស់គាត់ និងបានជួយបំពេញទម្រង់បែបបទព័ត៌មានជនរងគ្រោះដល់អ្នកដែលនៅរស់ចំនួន១៥៨នាក់ ។

### ១) ភាពជោគជ័យរបស់ក្រុមគម្រោងជួបអ្នកធ្វើញត្តិ

ពាក្យបណ្តឹងដ៏ច្រើនសន្ធឹកសន្ធាប់ដែលប្រមូលបាន ត្រូវបំពេញដោយអ្នកធ្វើញត្តិរណសិរ្ស ហើយពាក្យបណ្តឹងចំនួន១១៦ ក្នុងចំណោម១៥៨ធ្វើឡើងដោយអ្នកធ្វើញត្តិ ។ ក្រុមគម្រោងបានរកឃើញថា អ្នកធ្វើញត្តិភាគច្រើនមិនបានចងចាំហត្ថលេខាដែលមាននៅលើញត្តិទេ ។ នៅក្នុងករណីជាច្រើន បន្ទាប់ពីបង្ហាញញត្តិនិងហត្ថលេខា គាត់នៅចងចាំ ហើយខ្លះទៀតក៏មិនបានចាំពីការចុះហត្ថលេខានោះដែរ ។ ករណីនេះបានបង្ហាញថា ញត្តិទាំងអស់ត្រូវបានចុះហត្ថលេខាបន្ទាប់ពីមានការប្រជុំឬក៏ធ្វើនៅតាមផ្ទះពេលដែលមេភូមិឬក៏មេឃុំចុះស្រង់ឈ្មោះ ។ ក្រុមបានរកឃើញថា អ្នកធ្វើញត្តិមិនបានចងចាំពីស្ថានភាពពេលប្រជុំឬក៏ផលប៉ះពាល់នៃឥទ្ធិពលនយោបាយលើញត្តិទាំងនោះទេ ។

### ក) ការខិតខំប្រឹងប្រែងរបស់ក្រុមគម្រោងជួបនឹងសហគមន៍កម្ពុជាក្រោម

ក្រុមគម្រោងបានធ្វើការនៅក្នុងភូមិ២ នៅក្នុងស្រុកបាកានដែលជាស្រុកកំណើតរបស់សមាជិកសហគមន៍កម្ពុជាក្រោម ។ ប្រជាជនកម្ពុជាក្រោម (ជាធម្មតាហៅថាខ្មែរក្រោម) គឺជាជន

ជាតិខ្មែរភាគតិចដែលរស់នៅភាគខាងត្បូងប្រទេសវៀតណាម ជាពិសេសនៅតាមដីសណ្តទន្លេមេគង្គ ។ ប្រជាជនកម្ពុជាក្រោមបានកាន់កាប់តំបន់នៃភាគខាងត្បូងប្រទេសវៀតណាមនៅមុនរយៈពេលនៃការមកដល់របស់ជនជាតិវៀតណាមទៅទៀត ។ នៅរជ្ជកាលស្តេច មុនីវង្ស ១៩២៧-១៩៤១ ប្រជាជនកម្ពុជាក្រោមមួយចំនួនបានផ្លាស់ទៅស្រុកបាកាន ខេត្តពោធិ៍សាត់ ដើម្បីកាប់ឆ្ការព្រៃនិងសាងសង់លំនៅដ្ឋាននៅទីនោះ ។ បន្ទាប់មក ដោយសារដីមានជីជាតិនិងអាចប្រកបរបរដាំដុះបាន ប្រជាជនកម្ពុជាក្រោមបានមករស់នៅពោធិ៍សាត់ ដោយបង្កើតជាភូមិកម្ពុជាក្រោមកាន់តែច្រើនថែមទៀត ។

ក្រុមគម្រោងបានរកឃើញសមាជិកនៃសហគមន៍កម្ពុជាក្រោមនៅក្នុងស្រុកបាកានដែលបានរងទុក្ខវេទនានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងដើម្បីចែករំលែកអំពីប្រវត្តិរឿងរ៉ាវដែលគាត់បានឆ្លងកាត់សម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ។ ជាការពិតរឿងរ៉ាវរបស់គាត់បានរៀបរាប់ពីទុក្ខវេទនាផ្សេងៗគ្នាដែលសហគមន៍គាត់ទទួលរង និងបានអះអាងថា ជាទូទៅខ្មែរក្រហមមានបំណងធ្វើទុកបុកម្នេញនិងសម្លាប់ ពីព្រោះខ្មែរក្រហមចាត់ទុកពួកគាត់ជាជនជាតិវៀតណាម ។ ដើម្បីគាំទ្រនូវការអះអាងរបស់គាត់ពីផែនការបំផ្លាញប្រជាជនកម្ពុជាក្រោម អ្នកភូមិជាច្រើនបានបកស្រាយប្រាប់សមាជិកក្រុមថា ខ្មែរក្រហមបានព្យាយាមសម្លាប់កូនចៅទាំងអស់ដែលមានឈាមជ័រជាកម្ពុជាក្រោម ប៉ុន្តែសម្លាប់តែកូនចៅដែលមានសាច់ញាតិខ្មែរពាក់កណ្តាល កម្ពុជាក្រោមពាក់កណ្តាល ប្រសិនបើម្តាយជាកម្ពុជាក្រោម ។

អ្នកដាក់ពាក្យបណ្តឹងដែលជាស្ត្រីកម្ពុជាក្រោមបានប្រាប់សមាជិកក្រុមគម្រោងថា ដោយសារតែដឹងថាគាត់ប្រហែលជាត្រូវគេយកទៅសម្លាប់ ម្តាយរបស់គាត់បានប្រាប់គាត់ឲ្យលាក់ប្រវត្តិរូប ហើយកុហកថាគាត់ត្រូវបានគេយកមកចិញ្ចឹម ហេតុនេះហើយបានជាគាត់នៅរស់ ។ ចំណែក សមាជិកគ្រួសាររបស់គាត់ដទៃទៀតមិនមានសំណាងល្អទេ ។ ជាការគួរឲ្យរន្ធត់ គាត់បានឃើញបងប្អូនជីដូនមួយស្រីរបស់គាត់ម្នាក់ត្រូវបានវាយនឹងដំបងរហូតដល់ស្លាប់និងវះពោះយកថ្លើម ។ ភ្លាមនោះ គាត់បានឃើញបងស្រីគាត់កំពុងជីករណ្តៅនៅក្នុងវាលស្រែ ហើយក្រោយពេលដែលគាត់ត្រឡប់មកវិញ គាត់មិនឃើញបងស្រីរបស់គាត់ទេ គឺឃើញតែឈាមនៅជុំវិញរណ្តៅប៉ុណ្ណោះ ។

## ឃ) ភាពជោគជ័យនៃការជម្លៀសប្រជាជនចេញពីភូមិភាគបូព៌ាទៅកាន់ខេត្តពោធិ៍សាត់

រយៈពេលបំពេញការងារនៅភូមិដូនដោក ខេត្តព្រៃវែង នៅខែមេសា ឆ្នាំ២០០៨ គម្រោងបានរកឃើញថា អ្នកដែលនៅរស់សព្វថ្ងៃភាគច្រើនបានអះអាងនៅក្នុងពាក្យបណ្តឹង និងដើមបណ្តឹងរដ្ឋប្បវេណីថា ខ្មែរក្រហមបានជម្លៀសអ្នកស្រុកជាច្រើនពីភូមិភាគបូព៌ាទៅកាន់ខេត្តពោធិ៍សាត់ ។ ដោយយោងតាមសារណារបស់អ្នកភូមិផ្ញើទៅឲ្យអង្គភាពជនរងគ្រោះនៅថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ១៩៧៨ ទាហានបានវាយលុកចូលក្នុងភូមិរបស់គាត់ រួចសម្លាប់ប្រជាជនអស់ជាច្រើន ហើយបង្ខំឲ្យអ្នកដែលនៅរស់ទាំងអស់ជម្លៀសទៅតំបន់ដែលហៅថា «ដីខ្លាញ់» ស្ថិតនៅតាមបណ្តាខេត្តនៃភូមិភាគបស្ចិម ។

នៅក្នុងសៀវភៅ «ប្រទេសកម្ពុជា: ការសម្លាប់រង្គាលនៅភូមិភាគខាងកើត» របស់ ប៊ិន ឃៀរនិន បានបញ្ជាក់ថា នៅ


អ្នកភូមិកំពុងអានទស្សនាវដ្តីស្វែងរកការពិត

ពាក់កណ្តាលទី២ នៃឆ្នាំ១៩៧៨ ខាងមជ្ឈិម "បានដាក់ផែនការបោសសម្អាតប្រជាជននៅភូមិភាគបូព៌ា តាមរយៈការជម្លៀសប្រជាជនចេញឬក៏សម្លាប់" ។ យោងតាមកិច្ចសម្ភាសន៍របស់គម្រោងជំរុញឲ្យមានការទទួលខុសត្រូវដែលជួបសម្ភាសន៍ជាមួយនឹងអតីតកម្មាភិបាលបានឲ្យដឹងថា ខ្មែរក្រហមបានជម្លៀសអ្នកស្រុកនៅភូមិភាគបូព៌ាជាច្រើនគ្រួសារទៅកាន់ភូមិភាគបស្ចិម រួមមានខេត្តកំពង់ធំ ពោធិ៍សាត់ និងបាត់ដំបង ព្រោះខ្លាចអ្នកស្រុករត់ទៅប្រទេសវៀតណាម ។

ពាក្យបណ្តឹងនិងបណ្តឹងរដ្ឋប្បវេណីដែលប្រមូលបាននៅក្នុងខេត្តពោធិ៍សាត់ បានបញ្ជាក់បន្ថែមទៅលើរឿងរ៉ាវនៅតំបន់ភូមិភាគបូព៌ាដែលបង្ខំឲ្យប្រជាជនជម្លៀសទៅភាគខាងបស្ចិម ។ លើសពីនេះទៅទៀត ព័ត៌មានដែលប្រមូលបានមកនេះក៏បានបង្ហាញផងដែរពីជោគវាសនានៃអ្នកដែលបានជម្លៀសទៅកាន់ខេត្តពោធិ៍សាត់ ។ អ្នកស្រុកបានអះអាងថា មួយភាគធំនៃប្រជាជនដែលបានជម្លៀសនៅភូមិបូព៌ាត្រូវបានខ្មែរក្រហមសម្លាប់ខណៈពេលដែលអ្នកទាំងនោះមកដល់ភ្លាម ។

## ផលវិជ្ជមាន

◆ ការប្រជុំរបស់ក្រុមគម្រោងបានផ្តល់ឱកាសដ៏ល្អដល់អ្នកដែលនៅរស់ ដើម្បីឲ្យគាត់អាចនិយាយរឿងប្រាប់ដល់ក្រុមដែលចាប់អារម្មណ៍ ដូច្នេះគាត់អាចមានការធូរស្រាលក្នុងចិត្ត ។

◆ ជាឱកាសដើម្បីបំពេញទម្រង់បែបបទព័ត៌មានជនរងគ្រោះនិងការជួយបង្កើតកំណត់ត្រាប្រវត្តិសាស្ត្រ ដែលធ្វើឡើងដោយអ្នកនៅរស់ដែលបារម្ភថា ក្មេងជំនាន់ក្រោយមិនជឿពីអំពើឃោរឃៅនៅសម័យខ្មែរក្រហមឡើយ ។

◆ ការប្រជុំរបស់ក្រុមគម្រោងក៏បានផ្តល់ឱកាសដ៏មានសារសំខាន់ដើម្បីជម្រាបដល់អតីតកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមថា តុលាការនឹងកាត់ទោសតែមេដឹកនាំជាន់ខ្ពស់និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតប៉ុណ្ណោះ ដូច្នេះ វាអាចធ្វើឲ្យគាត់ស្ងប់ចិត្តនិងបង្កើនការសហការជាមួយតុលាការ ។

◆ ដោយយោងទៅលើអ្នកដាក់ញត្តិមួយចំនួនធំដែលបានទាក់ទងនៅក្នុងខេត្តពោធិ៍សាត់ ក្រុមគម្រោងបានទទួលបានព័ត៌មានបន្ថែមទៀតអំពីការចុះហត្ថលេខានៅលើញត្តិនៅក្នុងទសវត្សរ៍ឆ្នាំ៨០ ច្រើនជាងអ្វីដែលទទួលបាននៅខេត្តកំពង់ធំ ។ ទោះបីជាព័ត៌មានជាច្រើនទៀតត្រូវបានប្រមូលផ្តុំយ៉ាងណាក៏ដោយ ក៏កម្រមានអ្នកធ្វើញត្តិចង់ចាំនូវហត្ថលេខារបស់គាត់ណាស់ ។

◆ ក្រុមបានរកឃើញថា ប្រធានភូមិនៅក្នុងខេត្តពោធិ៍សាត់បានរៀបចំយ៉ាងល្អ ហើយគាត់ក៏អបអរសាទរជាមួយគោលបំណងនៃគម្រោងនេះ ។ បន្ទាប់មកក្រុមគម្រោងបានផ្តល់តារាងឈ្មោះអ្នកដាក់ធ្វើញត្តិដល់មេភូមិ គាត់ក៏បានលើកទឹកចិត្តដល់អ្នកដែលនៅរស់ដើម្បីចូលរួមផងដែរ ។

◆ ក្រុមបានរកឃើញថា អ្នកនៅរស់ជាច្រើនហាក់ដូចជាមិនព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ឡើយ ដូចជាមនុស្សមួយចំនួនតូចដែលសំណូមពរឲ្យមានវិធានការការពារជាដើម ។

◆ ដើម្បីផ្តល់បទពិសោធន៍បន្ថែមនៅក្នុងការបំពេញទម្រង់នេះ បុគ្គលិកគម្រោងបានបង្ហាញការលំបាកនៅក្នុងការបង្កើតសំណួរមួយដើម្បីទាញយកព័ត៌មានដែលសំខាន់ទាំងអស់ ជាពិសេសនៅពេលឆ្លើយនូវសំណួរផ្នែក-ខ ដែលទាក់ទងទៅនឹងការពិពណ៌នាអំពីឧក្រិដ្ឋកម្ម ។

◆ ក្រុមបានរកឃើញថា អ្នកភូមិដែលមកចូលរួមប្រជុំគឺចង់បំពេញពាក្យបណ្តឹង និងបង្ហាញពីបទពិសោធន៍របស់គាត់ផ្ទាល់ ។ ការមិនគាំទ្រគោលដៅរបស់គម្រោង គឺមិនមានការភ្ញាក់ផ្អើលទេ ពេលដែលប្រធានភូមិត្រូវបានណែនាំដើម្បីឲ្យអញ្ជើញអ្នកធ្វើញត្តិមកចូលរួមប្រជុំ គឺមានតែអ្នកដែលបាននិយាយពីអំពើសាហាវឃោរឃៅរបស់ខ្មែរក្រហមប៉ុណ្ណោះដែលបានអញ្ជើញមក ។

## បទពិសោធន៍និងដំណោះស្រាយ

### ១) ការយល់ច្រឡំទៅលើអំណោយ

មានតែភូមិមួយប៉ុណ្ណោះដែលអ្នកនៅរស់មួយចំនួនបានចូលរួមក្នុងកិច្ចប្រជុំរបស់គម្រោងយល់ច្រឡំថា គាត់នឹងបានទទួលអំណោយត្រឡប់ទៅវិញសម្រាប់ការមកចូលរួមរបស់គាត់ និងជាពិសេសសម្រាប់ការបំពេញពាក្យបណ្តឹង ។ ទាំងនេះបានបង្ហាញពីស្ថានភាពដ៏សំខាន់ដែលក្រុមគម្រោងត្រូវកែលម្អនៅក្នុងខេត្តកំពង់ធំ ព្រោះមានអ្នកនៅរស់នៅក្នុងភូមិជាច្រើនទៀតសង្ឃឹមថានឹងបានទទួលអំណោយត្រឡប់ទៅវិញសម្រាប់ការចូលរួមរបស់គាត់ ។

**អនុសាសន៍** ៖ គោលការណ៍សំខាន់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺមិនផ្តល់ជាអំណោយឬក៏លុយសម្រាប់ការអញ្ជើញមកចូលរួមរបស់អ្នកដែលនៅរស់ឡើយ ។

### ២) ខ្លាចមានការសងសឹក

អ្នកនៅរស់មួយចំនួនមិនព្រមបំពេញទម្រង់ទេ ព្រោះគាត់ខ្លាចមានការសងសឹក ជាពិសេសពីសមាជិកអតីតខ្មែរក្រហមនៅក្នុងភូមិរបស់គាត់ ។ ឧទាហរណ៍ៈ ទោះបីជាស្ត្រីម្នាក់ដែលមុនដំបូងនិយាយថា គាត់មិនបានភ័យខ្លាចពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ក៏ដោយ ប៉ុន្តែនៅពេលសួរពីវិធានការការពារខ្លួន គាត់មិនព្រមប្តឹងទេបន្ទាប់ពីបំពេញពាក្យបណ្តឹងរួចហើយ គឺគាត់ចាប់ផ្តើមភ័យខ្លាច ។

**អនុសាសន៍** ៖ លើកឡើងនៅពេលប្រជុំថា តុលាការនឹងកាត់ទោសតែមេដឹកនាំជាន់ខ្ពស់និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតប៉ុណ្ណោះ ដូច្នេះ អតីតខ្មែរក្រហមថ្នាក់ក្រោមមិនគួរមានការភ័យខ្លាចពីការកាត់ទោស និងមិនបណ្តាលឲ្យមានការសងសឹកទេ ប្រសិនបើដាក់ឈ្មោះ ។

### ៣) ភាពលំបាកនៃអ្នកដែលនៅរស់ដើម្បីលើកឡើងពីសំណងជំងឺចិត្តសម្រាប់ជនរងគ្រោះ

ដូចជានៅក្នុងខេត្តកំពង់ធំដែរ អ្នកនៅរស់ដ៏ច្រើនសន្ធឹកសន្ធាប់បានព្យាយាមស្នើសុំឲ្យមានសំណងដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់លាក់របស់ជនរងគ្រោះដោយសាររបបនោះ ។ ជាធម្មតា សំណូមពររបស់គាត់គឺត្រូវបានកំណត់ដោយភ្ជាប់ទៅនឹងតម្រូវការដែលទាក់ទងជាមួយការអភិវឌ្ឍ ដូចជាសាងសង់សាលារៀន ផ្លូវថ្នល់ និងមន្ទីរពេទ្យជាដើម ។ ផលប្រយោជន៍នេះមិនត្រឹមតែបានដល់ជនរងគ្រោះទាំងនោះទេ ថែមទាំងដល់អ្នកដែលមិនមែនជាជនរងគ្រោះក៏ដូចជាជនដៃដល់ផងដែរ ។ ទាំងនេះជាការលំបាកចំពោះអ្នកដែលនៅរស់ដើម្បីលើកឡើងពីសំណងជំងឺចិត្តដែលអាចជួយសម្រួលដល់ជីវភាពរបស់គាត់ ហើយម្យ៉ាងបុគ្គលិកគម្រោងក៏មិនសូវយល់ដឹងពីសារសំខាន់នៃសំណងសម្រាប់ជនរងគ្រោះដែរ ។

**អនុសាសន៍** ៖ ដឹកនាំការបណ្តុះបណ្តាលសមាជិកក្រុមមកលើសារសំខាន់នៃសំណងសម្រាប់ជនរងគ្រោះនិងលើកទឹកចិត្តអ្នកនៅរស់ឲ្យគិតពីគម្រោងសំណងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះ ។

### ៤) ការកំណត់បុគ្គលិកដែលជួយដើម្បីប្រមូលទម្រង់

នៅក្នុងកិច្ចប្រជុំជាច្រើន ចំនួនអ្នកនៅរស់ដែលចូលរួមតែងតែលើសពីការរំពឹងទុករបស់ក្រុម ដែលនាំឲ្យមិនមានបុគ្គលិកគ្រប់ចំនួនសម្រាប់ជួយពន្យល់ ។ ខណៈពេលដែលក្រុមមិនអាចជួយអ្នកនៅរស់ទាំងអស់ដែលចង់បំពេញទម្រង់នៅពេលតែមួយបាន អ្នកទាំងនោះត្រូវរង់ចាំបុគ្គលិកបញ្ចប់ការជួយដល់អ្នកដទៃសិនមុននឹងគេមានឱកាសបំពេញទម្រង់ ។ ខណៈពេលដែលការបំពេញទម្រង់ចំណាយពេលប្រហែលពី៦០ទៅ៩០នាទី អ្នកភូមិជាច្រើនក៏បានសម្រេចចិត្តចាកចេញមុនពេលដែលគេអាចបំពេញទម្រង់មួយដោយសារតែគាត់ចាំយូរពេក ។

**អនុសាសន៍** ៖ ជ្រើសរើសបុគ្គលិកបន្ថែមសម្រាប់គម្រោងឬក៏បង្រៀនមេភូមិនិងមេឃុំដើម្បីអញ្ជើញអ្នកដែលនៅរស់មួយចំនួនទៀត ។

### សេចក្តីសន្និដ្ឋាន

ការផ្សាយខេត្តពោធិ៍សាត់បានបង្ហាញពីភាពជោគជ័យដ៏ធំ នៅពេលដែលក្រុមប្រមូលបានពាក្យបណ្តឹងរបស់ជនរងគ្រោះចំនួនជាង១៥៨ ដើម្បីប្រគល់ទៅឲ្យអង្គភាពជនរងគ្រោះនៅក្នុងរយៈពេលតែ៨ថ្ងៃប៉ុណ្ណោះ ។ នេះបង្ហាញពីតួលេខខ្ពស់ដែលប្រមូលបានក្នុងរយៈពេល១ថ្ងៃ ហើយតួលេខនេះនឹងកើនឡើងថែមទៀតនៅក្នុងខេត្តកំពង់ធំ ។ តួលេខដែលប្រមូលបាននេះអាចសន្និដ្ឋានថាជាការរៀបចំយ៉ាងល្អនិងដោយការយកចិត្តទុកដាក់របស់ប្រធានភូមិ ។

ក្រុមការផ្សាយសង្ឃឹមថា ព័ត៌មានដែលមាននៅក្នុងពាក្យបណ្តឹងនេះ (ជាពិសេសពាក្យបណ្តឹងប្រមូលមកពីសមាជិកសហគមន៍កម្ពុជាក្រោម) នឹងមានប្រយោជន៍ដល់ការងាររបស់តុលាការ ។ យើងមានការសប្បាយចិត្តណាស់ចំពោះពាក្យបណ្តឹងដែលប្រមូលបាន រួមមានចម្លើយដែលឆ្លើយទៅនឹងសំណួរដែលយើងបានរំពឹងទុកថានឹងមានការសើរើទម្រង់បែបបទព័ត៌មានជនរងគ្រោះជាថ្មីឡើងវិញដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អង្គភាពជនរងគ្រោះ ។ **សារ៉ា ថូម៉ាស់ និង ឌី ឆេរិទ្ធិ**

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីសង្ខេបលើកិច្ចប្រជុំជាមួយនឹងក្រុមបណ្តារដ្ឋចាប់អារម្មណ៍ នៅឯបុរីញូយ៉ក កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨

## បង្ហាញដោយ ប្រធាននិងអនុការិយាល័យរដ្ឋបាល ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨

**លោក លោកស្រី ជាអ្នកសារព័ត៌មានជាទីរាប់អាន**

ខ្ញុំមានក្តីរីករាយយ៉ាងពន់ពេកក្នុងការបង្ហាញជូនលោក លោកស្រី នូវសេចក្តីសង្ខេបនៃកិច្ចប្រជុំនានាដែលបានប្រព្រឹត្តនៅឯបុរីញូយ៉កកាលពីសប្តាហ៍មុន។ កិច្ចប្រជុំដែលមានឈ្មោះថាគណៈ កម្មាធិការដឹកនាំបានប្រព្រឹត្តធ្វើឡើងនៅទីស្នាក់ការបេសកកម្មអចិន្ត្រៃយ៍របស់ជប៉ុនកាលពីថ្ងៃទី១៦ ខែមិថុនា និងកិច្ចប្រជុំពេញអង្គនៃក្រុមបណ្តារដ្ឋចាប់អារម្មណ៍នាថ្ងៃសុក្រ ទី២០ ខែមិថុនា នៅឯទីស្នាក់ការអង្គការសហប្រជាជាតិ ដើម្បីពិភាក្សាទៅលើគំរោងថវិការបស់ អ.វ.ត.កដែលបានកែប្រែថ្មី។

អ.វ.ត.ក បានបញ្ជូនគណៈប្រតិភូមួយដែលមាន៤រូបរួមមានប្រធានការិយាល័យរដ្ឋបាល អនុប្រធានការិយាល័យរដ្ឋបាល ប្រធានផ្នែកកិច្ចការសាធារណៈ និងប្រធានផ្នែកថវិកានិងហិរញ្ញវត្ថុខាងភាគីកម្ពុជា។ ចំណែកឯខាងអគ្គលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិដែលបានចូលរួម រួមមាន តំណាងមកពីផ្នែកគ្រប់គ្រងថវិកានិងហិរញ្ញវត្ថុ គឺលោក Warren Sach និង លោកស្រី Marie Oveissi និងលោក David Tolbert  តំណាងមកពីការិយាល័យកិច្ចការច្បាប់ និងជាអ្នកឯកទេសពិសេសរបស់អគ្គលេខាធិការអ.ស.ប សំរាប់ការកាត់សេចក្តីខ្មែរក្រហម។

**ការវិវត្តន៍ថ្មីៗ**

យើងបានរាយការណ៍ជូនដល់ក្រុមបណ្តារដ្ឋចាប់អារម្មណ៍ថា ចាប់តាំងពីគណៈប្រតិភូមរបស់យើងបានជួបជាមួយក្រុមបណ្តាប្រទេសចាប់អារម្មណ៍កាលពីខែមីនាកន្លងមក អ.វ.ត.កបានបន្តការងារធ្វើឲ្យមានការវិវត្តន៍ដូចខាងក្រោម៖

ក្នុងផ្នែកតុលាការ ជនសង្ស័យទាំង ៥ រូបបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នបណ្តឹងឧទ្ធរណ៍ចំនួន ៤ ត្រូវបានបើកសវនាការរួចហើយ (សវនាការមួយត្រូវបានពន្យាពេល) ហើយសវនាការរបស់បណ្តឹងទី៥ នឹងត្រូវធ្វើឡើងនាថ្ងៃទី៣០ ខែមិថុនានេះ។ សហចៅក្រមស៊ើបអង្កេតបានប្រកាសកាលពីថ្ងៃទី១៥ ខែឧសភា ថាពួកគេបានធ្វសេចក្តីសន្និដ្ឋានលើកិច្ចស៊ើបសួរលើសំណុំរឿងទី១ហើយពួកគេសង្ឃឹមថានឹងអាចចេញដីកាដំណោះស្រាយក្នុងខែកក្កដា។ យើងកំពុងត្រៀមខ្លួនរួចជាស្រេចសំរាប់សវនាការជំនុំជម្រះដែលអាចនឹងចាប់ផ្តើមក្នុងខែកញ្ញាខាងមុខនេះ។

ការជួសជុលកែលំអសាលសវនាការឥឡូវនេះបានបញ្ចប់ ហើយយើងនឹងប្រើសាលសវនាការនេះសំរាប់សវនាការលើបណ្តឹងឧទ្ធរណ៍ដែលនឹងប្រព្រឹត្តនាថ្ងៃទី៣០ ខែមិថុនា ខាងមុខនេះ។

អង្គភាពជនរងគ្រោះបានបន្តដំណើរទៅមុខដោយកំពុងធ្វើកិច្ចការជាមួយពាក្យបណ្តឹងចំនួន១៣០០ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយរហូតមកដល់ពេលនេះមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន១១ហើយបានបញ្ចូលទៅក្នុងសំណុំរឿងទី១ និងទី២។ លក្ខណៈបំបែកនៃបែបបទរបស់អ.វ.ត.កក្នុងការបញ្ចូលជនរងគ្រោះឲ្យក្លាយទៅជាដើមបណ្តឹងរដ្ឋប្បវេណី បានទាក់ ទាញចំណាប់អារម្មណ៍និងការគាំទ្រជាច្រើន ជាក់ស្តែងដូចមានចុះក្នុងអត្ថបទមួយរបស់ Seth Mydans ដែលមានចំណងជើងថា “The Khmer Rouge Trial, Victims will not stand idly by” ផ្សាយក្នុងសារព័ត៌មាន *New York Times* កាលពីថ្ងៃទី១៧ ខែមិថុនា។

មានការបោះពុម្ពថ្មីៗជាច្រើនធ្វើឡើងដោយផ្នែកកិច្ចការសាធារណៈ ដែលក្នុងនោះរួមមាន របាយការណ៍តុលាការចេញប្រចាំខែចំនួនពីរច្បាប់ត្រូវបានផលិត កូនសៀវភៅណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមត្រូវបានបោះពុម្ពជាលើកទី៣ ដែលក្នុងពេលនេះយើងមានបោះពុម្ពលើកទី១ ជាភាសាបារាំង រួមនិងភាសាអង់គ្លេសនិងភាសាខ្មែរ។ ជាមួយគ្នានោះផងដែរ ផ្ទាំងរូបភាពព័ត៌មានដែលមានប្រជាប្រិយរបស់អ.វ.ត.ក ក៏បានបោះពុម្ពសារជាថ្មីផងដែរ(ក្រោយជំនួយ ឧបត្ថម្ភពីប្រទេសអូស្ត្រាលី ប្រទេសណរវេស៍ និងស្ថានទូតបារាំង)។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមទាញចំណាប់អារម្មណ៍របស់លោក លោកស្រី មកពិនិត្យមើលលើ របាយការណ៍តុលាការសំរាប់មិថុនា ដែលក្នុងនោះមានចំនុចមួយបង្ហាញពីលទ្ធផលនៃការអង្កេតស្ទាបស្ទង់ថ្មីៗធ្វើឡើងដោយវិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិលើប្រជាពលរដ្ឋកម្ពុជាចំនួន២០០០នាក់ បង្ហាញថាពួកគេមានចំណេះដឹងយ៉ាងទូលាយដែលរួមមានចំណេះដឹងអំពី អ.វ.ត.ក ផងដែរ។ យើងមានក្តីរីករាយដោយមើលឃើញថាសាធារណៈនៅតែបន្តការគាំទ្រយ៉ាងខ្លាំងចំពោះគំនិតក្នុងការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ដែលតាមរយៈការអង្កេតនោះគឺមាន

តួលេខ ដល់ទៅ ៨៩ ភាគរយ។ អ្វីដែលសំខាន់ជាងនេះសំរាប់យើងនោះគឺថាជាលើកទីមួយហើយដែលចំណេះដឹងអំពីអ.វ.ត.ក បានជ្រាបចូលយ៉ាងជ្រៅក្នុងស្រទាប់សាធារណៈ។ តួលេខចំនួន ៧១ ភាគរយ បានទទួលបានចំណេះដឹងអំពីការងារផ្សព្វផ្សាយដ៏មានប្រសិទ្ធិភាពនិងវិជ្ជមានដែលធ្វើ ឡើងដោយអ.វ.ត.ក ក៏ដូចជាបណ្តាអង្គការក្រៅរដ្ឋាភិបាលនិងបណ្តាញសារព័ត៌មានផ្សេងៗ។

## តំរូវការផ្នែកថវិកា

ពេលនេះយើងស្ថិតនៅក្នុងបរិបទវិជ្ជមានមួយបន្ទាប់ពីដំណើរទៅកាន់បុរីញូយ៉កដើម្បីប្រជុំជាមួយក្រុមបណ្តារដ្ឋចាប់អារម្មណ៍ពិភាក្សាអំពីតំរូវការថវិការបស់យើងនិងបង្ហាញពីសេចក្តីសង្ខេបនៃគំរោងថវិកាដែលបានកែប្រែរួមជាមួយនឹងការពិនិត្យឡើងវិញក្នុងរយៈពេលប៉ុន្មានខែកន្លងមក។ សូមអនុញ្ញាតឲ្យខ្ញុំ លើកឡើងនូវតួលេខសំខាន់និងចំនុចផ្លាស់ប្តូរខ្លះៗបើប្រៀបធៀបជាមួយនឹងគំរោងថវិកាដែលបានបង្ហាញជូនក្រុមបណ្តាប្រទេសចាប់អារម្មណ៍កាលពីខែមករា ឆ្នាំ២០០៨។

តាមបទពិសោធន៍ជាក់ស្តែងរបស់អ.វ.ត.ក និងមេរៀនទាំងឡាយពីតុលាការផ្សេងៗ (ជាពិសេស តុលាការនៅបូស្នីនិងហេហ្គោវីណា) យើងបានធ្វើគំរោងថវិកាសំរាប់បង្ហាញដែលផ្តោតសំខាន់ទៅ លើសកម្មភាពបន្ថែមផ្សេងៗតាមតំរូវការរបស់វិធានផ្ទៃក្នុងរបស់អ.វ.ត.ក និងការសំរេចនានាធ្វើ ឡើងដោយសហព្រះរាជអាជ្ញានិងចៅក្រមជាតិនិងអន្តរជាតិក្នុងពេលកិច្ចប្រជុំពេញអង្គ និងអនុសាសន៍ផ្សេងៗផ្តល់ដោយអ្នកឯកទេសតុលាការទៅលើភាពស្រេចបាច់របស់តុលាការ។

គំរោងថវិកាដែលបានកែប្រែត្រូវបានបង្ហាញជា៣ផ្នែកផ្សេងៗគឺ

- ផ្នែកទី១៖ ប្រតិបត្តិការរបស់តុលាការហូតដល់ខែធ្នូ ឆ្នាំ២០០៩
- ផ្នែកទី២ក៖ ក្នុងករណីពង្រីកសំណុំរឿងទី២ ប្រតិបត្តិការរបស់តុលាការនឹងរហូតទៅដល់ខែតុលា ឆ្នាំ២០១០
- ផ្នែកទី២ខ៖ ក្នុងករណីបើមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរជាលើកទី២របស់ការិយាល័យសហព្រះរាជអាជ្ញា ប្រតិបត្តិការរបស់តុលាការនឹងរហូតដល់ខែធ្នូ ឆ្នាំ២០១០

ក្នុងពេលបច្ចុប្បន្ននេះ យើងកំពុងអំពាវនាវស្វែងរកជំនួយសំរាប់ផ្នែកទី១ រហូតដល់ខែធ្នូ ឆ្នាំ២០០៩។ ខ្ញុំសូមឲ្យលោក លោកស្រី មើលទៅលើតារាង “**ស្ថានភាពនៃតំរូវការថវិកានិងវិភាគទានពីឆ្នាំ ២០០៥ ដល់២០០៩**” ដែលមាន

បង្ហាញច្បាស់លាស់អំពីគមរោងថវិកាដើម វិភាគទានដែលទទួលបានរហូតដល់ពេលនេះ និងតំរូវការបច្ចុប្បន្ន សំរាប់ផ្នែកទី១។

យើងមានក្តីរីករាយនឹងជំរាបជូនលោក លោកស្រីថាយើងបានទទួលខ្លះហើយនូវជំនួយដែលម្ចាស់ជំនួយបានសន្យាឲ្យ ហើយយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះជំនួយនោះ។ រាជរដ្ឋាភិបាលជប៉ុនបានប្រកាសផ្តល់ជំនួយជំនួយជិត ៣ លានដុល្លាដល់កម្ពុជាដើម្បីរួមជាមួយនឹងគំរោងថវិកា។ រាជរដ្ឋាភិបាលកម្ពុជាក៏បានយល់ព្រមផងដែរថានឹងផ្តល់វិភាគទានចំនួន $992,622 ដុល្លា ថែមទៀត ឬក៏ចំនួន ១០ ភាគរយនៃថវិកាដែលត្រូវការសំរាប់ភាគីកម្ពុជា។ នេះគឺ ជាការប្តេជ្ញាចិត្តបន្ថែមទៀតសំរាប់ជួយដល់គំរោងថវិកាបន្ថែម។

យោងតាមការសន្យាថាផ្តល់ជំនួយដល់ អ.វ.ត.ក រហូតមកដល់ពេលនេះ (រួមទាំងជំនួយផ្តល់ដោយអូស្ត្រាលី និងបារាំង) ភាគីកម្ពុជានៃអ.វ.ត.ក ត្រូវការថវិកាចំនួនប្រមាណ ៦.១ លានដុល្លា បន្ថែមទៀតសំរាប់បន្តការងាររហូតដល់ចុងឆ្នាំ២០០៩ ក្នុងខណៈពេលដែលភាគីអន្តរជាតិនៅត្រូវការចំនួន៣៧.៧ លានដុល្លា

ដើម្បីឲ្យច្បាស់ជាងនេះទៀត សូមលោក លោកស្រី មើលក្នុងឧបសម្ព័ន្ធ១ ដែលមានបង្ហាញជូនជាទំរង់តារាងនៃតំរូវការផ្សេងៗលើគ្រប់ផ្នែកនៃគំរោងថវិកា។ បើសិនជាមានការពង្រីកបន្ថែមលើ សំណុំរឿងទី២និងបើអាចមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរជាលើកទី២របស់សហព្រះរាជអាជ្ញា ថវិកាសរុបរបស់ អ.វ.ត.ក ត្រូវការសំរាប់ប្រតិបត្តិការពីឆ្នាំ២០០៥ ដល់ ២០១០ គឺមាន ចំនួន ១៤៣.៦ លានដុល្លា (១០៥.៧ លានសំរាប់ខាងភាគីអន្តរជាតិ និង ២៥.៧ លានដុល្លាសំរាប់ខាង ភាគីកម្ពុជា រួមនឹងទឹកប្រាក់ចំនួន ១១.២ លានដុល្លា ស្មើនឹង ១៥% សំរាប់ថវិកាបំរុងទុក)។

គួរកត់សំគាល់ផងដែរថា គំរោងថវិកាដែលបានបង្ហាញដល់ក្រុមបណ្តារដ្ឋចាប់អារម្មណ៍គឺមានរួមបញ្ចូលចំនួន ១៥ ភាគរយសំរាប់ថវិកាបំរុងទុកសំរាប់ចំណាយបន្ថែមផ្សេងៗលើអ្វីដែលមិនបានគិតទុកជាមុន។ ម្ចាស់ជំនួយខ្លះបានសំនូមពរឲ្យដកចំនុចនេះចេញពីគំរោងថវិកាដោយចង់ឲ្យអ.វ.ត.ក លើកសំណើផ្សេងទៀងក្នុងពេលដែលត្រូវការ។ ក្រុមបណ្តាប្រទេសចាប់អារម្មណ៍និងអគ្គលេខាធិការដ្ឋានអ.ស.ប កំពុងពិភាក្សាពីបញ្ហានេះនៅឯញូយ៉ក។

សូមថ្លែងអំណរគុណសំរាប់ការយកចិត្តទុកដាក់ស្តាប់។ ខ្ញុំសូមបង្វែរវេទិកានេះជូនទៅលោក ដែលជួបលោក លោកស្រីជាលើកទី១ ចាប់តាំងពីលោកចូលកាន់ដំណែងជាអនុប្រធានការិយាល័យរដ្ឋបាលនាថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៨៕

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៨

ថ្ងៃនេះសហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពរក្នុងករណីសំណុំរឿងរបស់កាំង ហ្គិចអ៊ាវ ហៅឌុច។ ដីកាសន្និដ្ឋានស្ថាពរនេះមានជិត២០០ទំព័រជាភាសាអង់គ្លេសនិងជាង៣៥០ទំព័រជាភាសាខ្មែរទាក់ទងអង្គហេតុនិងទឡ្ហីករណ៍ច្បាប់ដែលជួយដល់សហចៅក្រមស៊ើបអង្កេតក្នុងការធ្វើសេចក្តីព្រាងដីកាដំណោះស្រាយរបស់ខ្លួនដែលនឹងក្លាយជាដីកាបញ្ជូនសំណុំរឿងរបស់ ឌុច ទៅជម្រះនៅមុខអង្គជំនុំជម្រះ។

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០៧ សហព្រះរាជអាជ្ញាបានចេញដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឲ្យស៊ើបសួរ ដោយស្នើឲ្យបើកកិច្ចស៊ើបសួរទៅលើទីតាំងឧក្រិដ្ឋកម្មចំនួន២៥កន្លែង ព្រមទាំងស្នើឲ្យនាំនិង ឃុំខ្លួនជនសង្ស័យចំនួន៥នាក់ពីបទឧក្រិដ្ឋនានាដូចជាបទមនុស្សឃាត និង បទប្រល័យពូជសាសន៍ជាដើម។ ទីតាំងទួលស្លែងស្ថិតនៅក្នុងទីក្រុងភ្នំពេញ ដែលជាទីតាំងមន្ទីរសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ និង ប្រធានមន្ទីរនេះក៏បានដាក់បញ្ចូលក្នុងដីកានោះផងដែរ។ នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ ឌុច ត្រូវបានចាប់ខ្លួន និងឃុំខ្លួនតាមរយៈដីការបស់ចៅក្រមស៊ើបអង្កេត ហើយដីកានេះត្រូវបានតម្កល់ទុកជាបានការដោយសេចក្តីសម្រេចលើកដំបូងរបស់អង្គបុរេជំនុំជម្រះ។

នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០០៧ ចៅក្រមស៊ើបអង្កេតបានបំបែកសំណុំរឿងទាក់ទង ស២១ និង ឌុច ០ចេញពីសំណុំរឿងជនត្រូវចោទ ៤នាក់ផ្សេងទៀត។ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតប្រកាសថាកិច្ចស៊ើបសួរក្នុងសំណុំរឿង ឌុច បានបញ្ចប់ហើយ ដោយបង្វិលសំណុំរឿងនេះនៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៨ មកសហព្រះរាជអាជ្ញាដើម្បីធ្វើដីកាសន្និដ្ឋានស្ថាពរ។ តាមវិធានផ្ទៃក្នុងនៃអ.វ.ត.ក ថ្ងៃកំណត់ចុងក្រោយនៃការដាក់ជូនឯកសារនេះ គឺត្រូវនឹងថ្ងៃទី៧ខែសីហា ឆ្នាំ២០០៨។ ដោយយល់ឃើញថាពេលវេលាមានសារៈសំខាន់ការិយាល័យសហព្រះរាជអាជ្ញាបានប្រមូលផ្តុំធនធានមានកម្រិតរបស់ខ្លួន ដើម្បីដាក់ដីកាសន្និដ្ឋានស្ថាពរស្ទើរតែ៣ សប្តាហ៍មុនពេលកំណត់។

ដោយយោងលើភស្តុតាងចំនួនជិត៩០០ដែលផ្តុំចូលគ្នា និង ដោយស្រង់យកករណីយុត្តិសាស្ត្រផ្នែកច្បាប់ជាតិនិងអន្តរជាតិនោះដីកាសន្និដ្ឋានស្ថាពរនេះបង្ហាញជូននូវការយល់ឃើញដ៏ទូលំទូលាយមួយនូវអ្វីដែលសហព្រះរាជអាជ្ញាចាត់ទុកថាជាភស្តុតាងដែលពាក់ព័ន្ធមាននៅក្នុងសំណុំរឿង។ សហព្រះរាជអាជ្ញាលើកឡើងនូវទឡ្ហីករណ៍ច្បាប់គាំទ្រដល់ការចោទប្រកាន់អំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និង បទឧក្រិដ្ឋផ្សេងៗទៀតដូចជាអំពីទារុណកម្ម និង មនុស្សឃាតក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលក្នុងនោះសហព្រះរាជអាជ្ញាដាក់ជូនថា ឌុច គួរតែត្រូវបានបញ្ជូនទៅជំនុំជម្រះ។ អនុលោមតាមច្បាប់ សហចៅក្រមស៊ើបអង្កេតពុំស្ថិតនៅក្រោមអំណាចចាប់បង្ខំនៃដីកាសន្និដ្ឋានស្ថាពរនេះឡើយ។ ដោយពិចារណាដល់ករណីនេះសហព្រះរាជអាជ្ញាគឺជាអ្នកត្រូវបង្ហាញភស្តុតាងឲ្យហួសពីវិមតិសង្ស័យ។ជាការពិតណាស់សំណុំរឿងនេះនឹងត្រូវបញ្ជូនទៅជំនុំជម្រះនៅអង្គជំនុំជម្រះក្នុងនោះសហព្រះរាជអាជ្ញាបានដាក់ជូននូវអ្វីដែលខ្លួនគិតថានឹងជាឯកសារដែលផ្តល់ជាជំនួយ និង ប្រកបដោយភាពជឿជាក់បាន។

ឌុច និង បុគ្គលិកក្រោមបង្គាប់នៅស-២១ បានធ្វើឯកសារយ៉ាងល្អិតល្អន់ទាក់ទងនឹងឧក្រិដ្ឋកម្មរបស់ខ្លួន។ ឯកសារដើមរាប់សែនទំព័របានបន្សល់ទុកនៅពេលដែលខ្មែរក្រហមត្រូវបានបណ្តេញចេញពីអំណាចនៅថ្ងៃទី ៧ ខែមករា ឆ្នាំ ១៩៧៩។ ឯកសារដែលមិនទាន់បាត់បង់ត្រូវរក្សាទុកដោយសារៈមន្ទីរទួលស្លែង និង មជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារមួយចំនួននៃឯកសារដើមទាំងនេះបង្កើតបានជាសំណុំរឿងនេះឡើង។ ជាងនេះទៅទៀត ចាប់តាំងពីការចាប់ខ្លួនមក ឌុច បានទទួលយកការសួរយកចម្លើយចំនួន២៧លើកដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ហើយបានចូលរួមក្នុងការស៊ើបអង្កេតដល់កន្លែងកើតហេតុដែលនៅកន្លែងនោះ ឌុច ត្រូវបានដាក់ឲ្យពិភាក្សាតទល់គ្នាជាមួយជនរងគ្រោះ និង អតីតបុគ្គលិកមន្ទីរស-២១។ ឌុច បានផ្តល់ នូវចម្លើយជាលាយលក្ខណ៍អក្សរមួយចំនួន និង ឆ្លើយសំនួរផ្សេងៗដែលលើកឡើងដោយ សហព្រះរាជអាជ្ញា និង ដើមបណ្តឹងរដ្ឋប្បវេណី។

ជាការសំខាន់ សាក្សីជាង៦៣នាក់ត្រូវបានសម្ភាសន៍ដោយសហចៅក្រមស៊ើបអង្កេតក្នុងនោះរួមមានជនរងគ្រោះដែលរស់រានមានជីវិត អតីតកងការពារ និង សាក្សីដែលពាក់ព័ន្ធ។ អ្នកទាំងនេះបានផ្តល់នូវការរៀបរាប់ដ៏រន្ធត់អំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅមន្ទីរស-២១។

ភស្តុតាងដែលដាក់ជូននៅក្នុងដំណាក់កាលជំនុំជម្រះនឹងក្លាយជាសក្ខីកម្មសាធារណៈ និង អចិន្ត្រៃយ៍ទាក់ទងនឹងភាពឃោរឃៅនៃរបបនោះនិងឧក្រិដ្ឋភាពរបស់អ្នកដែលមានតួនាទីនៅក្នុងស្ថាប័ននោះ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## សេចក្តីប្រកាសព័ត៌មាន

ដោយសារតែបញ្ហាសុខភាពដែលធ្វើឲ្យគាត់បារម្ភថា គាត់មិនអាចធ្វើការការពារក្តីឲ្យលោក ខៀវ សំផន រហូតដល់ការកាត់ក្តីបានចប់រួចរាល់នោះ លោកបណ្ឌិត សាយ បូរី បានលាលែងពីមុខតំណែងជាសហមេធាវីខ្មែរការពារក្តីឲ្យលោក ខៀវ សំផន ។ រឿងនេះត្រូវបានសម្រេចថា គឺជាការសមហេតុផលដែល អង្គភាពគាំពារការការពារក្តី (DSS) ត្រូវស្វែងរកមេធាវីខ្មែរថ្មីម្នាក់ តាំងពីពេលឥឡូវនេះទៅដើម្បីឲ្យមេធាវីរូបនោះមានពេលវេលាគ្រប់គ្រាន់ ដើម្បីនឹងរៀបចំការការពារក្តី។

អង្គភាពគាំពារការការពារក្តី (DSS) និង លោកបណ្ឌិត សាយ បូរី បានជួបលោក ខៀវ សំផន ដើម្បីពិភាក្សាគ្នាអំពីការការពារក្តីរបស់គាត់ ហើយសហមេធាវីខ្មែរថ្មីនឹងត្រូវធ្វើការជ្រើសរើសក្នុងពេលឆាប់ៗនេះ។

លោកបណ្ឌិត សាយ បូរី នឹងបន្តធ្វើជាតំណាងឲ្យលោក ខៀវ សំផន នៅក្នុងរយៈពេលនៃការផ្ទេររឿងក្តី ទៅឲ្យសហមេធាវីខ្មែរថ្មី។

## ការតែងតាំងសហមេធាវីកម្ពុជាថ្មីសម្រាប់លោក ខៀវ សំផន

នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ អង្គភាពគាំពារការការពារក្តី (DSS) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) បានតែងតាំងលោកបណ្ឌិត ស សូវាន ជាសហមេធាវីកម្ពុជាថ្មីសម្រាប់លោក ខៀវ សំផន ដើម្បីជំនួសលោកបណ្ឌិត សាយ បូរី ដែលត្រូវបានបង្ខំចិត្តលាឈប់ពីរឿងក្តី ដោយសារបញ្ហាសុខភាព។

លោកបណ្ឌិត ស សូវាន ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីឆ្នាំ២០០១មក ហើយលោកក៏ជាសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវីផងដែរ។ លោកបានទទួលសញ្ញាប័ត្រថ្នាក់បណ្ឌិត ពីសាកលវិទ្យាល័យច្បាប់ប៉ារីស II នៅឆ្នាំ១៩៧២។ មុនចូលជាសមាជិកគណៈមេធាវីកម្ពុជា លោក ស សូវាន បានកាន់កាប់តួនាទីជាច្រើន ជាអាទិ៍ជាអ្នកជំនាញច្បាប់ជាន់ខ្ពស់នៃរដ្ឋសភាកម្ពុជា ជាសាស្ត្រាចារ្យផ្នែកច្បាប់ស៊ីវិល និងជាអ្នកជំនាញនៅក្រសួងយុត្តិធម៌។ គាត់បានធ្វើការនៅក្នុងផ្នែកអប់រំច្បាប់អស់រយៈពេលជាច្រើនឆ្នាំ ហើយបានបោះពុម្ពផ្សាយជាភាសាបារាំង និងភាសាខ្មែរ នូវសៀវភៅទាក់ទងនឹងបញ្ហាច្បាប់ជាច្រើន រួមមាននីតិវិធីព្រហ្មទណ្ឌ ច្បាប់អន្តរជាតិ និងច្បាប់ពាណិជ្ជកម្ម។

# បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន

កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនាការដើម្បីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ អៀង ធីរិទ្ធ សុំទាមទារឲ្យមានការដោះលែងឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ដែលបានចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ។ អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រព្រឹត្តកាលពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ខែមករា ឆ្នាំ១៩៧៩ ដែលជាសមាជិកម្នាក់រួមចំណែកក្នុងការប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងប្រទេសកម្ពុជា ។ ពិសេសជាងនេះទៅទៀត អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ពីបទចូលរួមពាក់ព័ន្ធក្នុងអំពើឧក្រិដ្ឋកម្មក្នុងដែនសមត្ថកិច្ចរបស់គាត់ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ បើសិនកំហុសត្រូវបានរកឃើញ អៀង ធីរិទ្ធ ត្រូវប្រឈមមុខនឹងកាត់ទោសឲ្យជាប់ពន្ធនាគារចាប់ពីរយៈពេលប្រាំឆ្នាំដល់ដាក់គុកមួយជីវិត ។ ការប្តឹងឧទ្ធរណ៍នេះ គឺជាការសុំទាមទារឲ្យនៅក្រៅឃុំរបស់ អៀង ធីរិទ្ធ ពីការឃុំខ្លួនបណ្តោះអាសន្ន ប៉ុន្តែអង្គបុរេជំនុំជម្រះសម្រេចឲ្យជនជាប់ចោទនេះបង្ហាញវត្តមានជាចាំបាច់ ។ ភាគីចុងចោទបានធ្វើសំណើសំខាន់ពីរក្នុងការទាមទារឲ្យមានការដោះលែង ។ ទីមួយ ការរកឃើញរបស់សហចៅក្រមស៊ើបអង្កេតអំពីអ្វីដែលចោទថា អៀង ធីរិទ្ធ បានប្រព្រឹត្តខុសគឺគ្មានមូលដ្ឋាននិងបានរំលោភទៅលើភាពគ្មានទោសរបស់ជនត្រូវចោទ ព្រោះ អៀង ធីរិទ្ធ មិនទាន់ត្រូវបានរកឃើញថាមានទោសនៅឡើយ និងទីពីរ សហចៅក្រមស៊ើបអង្កេតគ្មានភស្តុតាងច្បាស់លាស់ ហើយការឃុំខ្លួនជនជាប់ចោទជាការមិនចាំបាច់ ។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះត្រូវបានរំពឹងថានឹងប្រកាសនៅចុងខែមិថុនានេះ ។


អៀង ធីរិទ្ធ នៅក្នុងអង្គសវនាការជំនុំជម្រះ

### ច្បាប់អង្គជំនុំជម្រះវិសាមញ្ញទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន

វិធាន៦៣(៣) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពន្យល់អំពីលក្ខខណ្ឌដែលសហចៅក្រមស៊ើបអង្កេតកំណត់ឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន ។ ចំណុចរង(ក) សហចៅក្រមស៊ើបអង្កេតកំណត់ថា «មានហេតុផលច្បាស់លាស់ដែលអាចជឿ» ថាជនត្រូវចោទ «បានប្រព្រឹត្តបទល្មើស» ដូចដែលបានចោទដោយព្រះរាជអាជ្ញាដែលដាក់ជូនទៅតុលាការ ។ ចំណុចរង(ខ) សហព្រះរាជអាជ្ញាប្រាកដច្បាស់ថា ការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នគឺជាការចាំបាច់ដើម្បី ១) ការពារជនត្រូវចោទពីលទ្ធភាពទៅបំភិតបំភ័យនិងធ្វើឲ្យមានការប៉ះពាល់ដល់សាក្សី ឬទៅឃុបឃិតជាមួយជនត្រូវចោទដទៃទៀត ២) ការពារនិងថែរក្សាភស្តុតាងពីការបំផ្លិចបំផ្លាញ ៣) ធានាថាជនត្រូវចោទមានវត្តមានក្នុងពេលសវនាការ ៤) ការពារសុវត្ថិភាពជនត្រូវចោទ ឬ ៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ ។

### ដីកាឃុំខ្លួនបណ្តោះអាសន្នកាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧

ក្នុងដីកាឃុំខ្លួនបណ្តោះអាសន្ន សហចៅក្រមស៊ើបអង្កេតសន្និដ្ឋានថា «មានហេតុផលច្បាស់លាស់ដែលអាចជឿ» ថា អៀង ធីរិទ្ធ ពិតជាមានការជាប់ពាក់ព័ន្ធពីបទឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ។ លើសពីនេះទៅទៀត សហចៅក្រមស៊ើបអង្កេតបានរកឃើញថា បទឧក្រិដ្ឋដែលបានចោទប្រកាន់គឺមានលក្ខណៈធ្ងន់ធ្ងរគ្រាន់ថា រយៈពេលសាមសិបឆ្នាំបន្ទាប់ពីរបបខ្មែរក្រហមបានបញ្ចប់

ជនជាប់ចោទនៅតែអាចបង្កឲ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់សាធារណជន ដូច្នេះ ការដោះលែង អៀង ធីរិទ្ធ ឲ្យនៅក្រៅឃុំ អាចនាំឲ្យមានការប្រឆាំងបះបោរពីសំណាក់សាធារណជន ហើយអាចនាំទៅរកអំពើហិង្សា ព្រមទាំងប៉ះពាល់ដល់សុវត្ថិភាពរបស់ អៀង ធីរិទ្ធ ។ សហចៅក្រមស៊ើបអង្កេតអះអាងថា បើដោះលែង អៀង ធីរិទ្ធ ឲ្យនៅក្រៅឃុំ គាត់ «អាចព្យាយាមនិងមានតួនាទីរៀបចំ» ដើម្បីដាក់សម្ពាធទៅលើសាក្សីនិងជនរងគ្រោះ ពិសេសដោយហេតុថា អៀង ធីរិទ្ធ មានលទ្ធភាពពេញលេញក្នុងការ «កត់សម្គាល់សាក្សីនិងជនរងគ្រោះដែលពាក់ព័ន្ធនឹងដំណើរការកាត់ទោស» ។ សហចៅក្រមស៊ើបអង្កេតបានចាត់ទុកការបំភិតបំភ័យទៅលើជនរងគ្រោះនិងសាក្សីជាក្តីបារម្ភយ៉ាងខ្លាំង ដោយហេតុថា អៀង ធីរិទ្ធ មានគ្រួសារនិងសាច់ញាតិជាច្រើននៅក្នុងប្រទេសកម្ពុជា ដែលមួយចំនួនគឺជាមនុស្សមានមុខតំណែងដ៏មានឥទ្ធិពល និងខ្លះទៀតស្ថិតក្នុងជួរកងប្រដាប់អាវុធផង ។ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញផងដែរថា អៀង ធីរិទ្ធ អាចមានមធ្យោបាយក្នុងការហោះហើរទៅកាន់ប្រទេសផ្សេងទៀត និងអាចគេចខ្លួនដោយសារតែបទពិសោធន៍ក្នុងបន្ទប់ឃុំឃាំង និងការចោទប្រកាន់ចំពោះគាត់ ។ ជាទីបញ្ចប់ សហចៅក្រមស៊ើបអង្កេតបានកំណត់ថា គ្មានឯកសាររបស់ភាគីចុងចោទណាបង្ហាញអំពីស្ថានភាពសុខភាពរបស់ អៀង ធីរិទ្ធ គឺ «មិនអាចទទួលនូវការឃុំឃាំង» បានទេ ។

**អំណះអំណាងទាក់ទងនឹងបទដ្ឋានច្បាប់ដែលអាចអនុវត្តបាន**

នៅក្នុងបណ្តឹងឧទ្ធរណ៍ចំពោះសវនាការដំបូង ភាគីចុងចោទបានបង្ហាញនូវការ «សន្មតទុកជាមុនថាមានសេរីភាព» ដែលអាចបង្ហាញនូវជំហរដ៏មុតមាំនិងហេតុផលចាំបាច់ក្នុងការឃុំឃាំងចុងចោទ ។ ព្រះរាជអាជ្ញាបានឆ្លើយតបដោយសម្អាងទៅលើតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ថាការដោះលែងឲ្យនៅក្រៅឃុំរបស់ចុងចោទនៅសវនាការដំបូងគឺគ្រាន់តែជាករណីយោគយល់ប៉ុណ្ណោះ មិនមែនមានច្បាប់ចែងទេ ។ លើសពីនេះទៅទៀត ព្រះរាជអាជ្ញាបានបញ្ជាក់ថា ដីកាឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេតគឺផ្អែកទៅលើ «មានហេតុផលច្បាស់លាស់ដែលអាចជឿ» ថា ការឃុំខ្លួន អៀង ធីរិទ្ធ គឺមានលក្ខណៈសមរម្យ ។

នៅក្នុងសេចក្តីសម្រេចចិត្តឃុំខ្លួនបណ្តោះអាសន្នកាលពីលើកមុនៗ អង្គបុរេជំនុំជម្រះមិនបានអះអាងថាតើភាគីមួយណាបានដាក់បន្ទុកទៅលើលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្នមានភាពគ្រប់គ្រាន់ឬក៏អត់ទេ ។ ក្រុមការពារក្តីរបស់ អៀង ធីរិទ្ធ បានតវ៉ាឲ្យមានការបើកសវនាការម្តងទៀត ហើយបានអះអាងថា ក្រោមច្បាប់កម្ពុជា សហព្រះរាជអាជ្ញាត្រូវបង្ហាញភស្តុតាងឲ្យច្បាស់អំពីមូលហេតុត្រូវឃុំខ្លួនបណ្តោះអាសន្ន ។

សហព្រះរាជអាជ្ញាឆ្លើយតបដោយអះអាងថា កម្រិតនៃបណ្តឹងសាទុក្ខគឺជាកំហុសអង្គហេតុ និងរំលោភទៅលើបទដ្ឋានឆន្ទានុសិទ្ធិ ។ បទដ្ឋាននេះផ្តល់នូវការគោរពទៅលើសហចៅក្រមស៊ើបអង្កេត ហើយធ្វើឲ្យមានការលំបាកក្នុងការសើរើដីកាឡើងវិញ ។ សហព្រះរាជអាជ្ញាបានកត់សម្គាល់ពីមុខងារស្រដៀងគ្នារវាងសហចៅក្រមស៊ើបអង្កេតនិងអង្គបុរេជំនុំជម្រះក្នុងតុលាការដែលមានលក្ខណៈអន្តរជាតិ ហើយបានអះអាងទៀតថា ដោយសារតែបទដ្ឋានធូររលុងនេះស៊ីគ្នាទៅនឹងអ្វីដែលបានអនុវត្តដោយបណ្តឹងឧទ្ធរណ៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនក្នុងការឆ្លុះបញ្ចាំងពីសេចក្តីសម្រេចចិត្តដ៏ធូររលុងដោយអង្គជំនុំជម្រះរបស់តុលាការអន្តរជាតិទាំងពីរនេះ ។ ហើយជាការសមស្របស្រដៀងគ្នាទៅនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ដែលមានលក្ខណៈមិនតឹងរ៉ឹងរបស់ដីកាឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេតក្រោមវិធាន៦៣(៣) ។

ភាគីចុងចោទបានតវ៉ាទៅលើជម្រើសដែលថា ទោះបីជាអង្គបុរេជំនុំជម្រះបានអនុវត្តនូវបទដ្ឋានកំហុសនៃការពិតនិងការរំលោភលើបទដ្ឋានឆន្ទានុសិទ្ធិក៏ដោយ ក៏តុលាការគួរតែបន្តការស្រាវជ្រាវក្នុងនាមជាជនត្រូវចោទដូចដែលសហចៅក្រមស៊ើបអង្កេតបានបរិយាយក្នុងការវិភាគពីការពិតដែលពាក់ពន្ធ័ឬការរំលោភលើសេចក្តីសម្រេចដែលបកស្រាយអំពីការឃុំខ្លួន អៀង ធីរិទ្ធ បណ្តោះអាសន្ន ។

**ការតវ៉ាប្រឆាំងនឹងការរកឃើញរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបង្គាប់ឲ្យមានការឃុំខ្លួនបណ្តោះអាសន្នកាលពីខែវិច្ឆិកា**

*១) កង្វះខាតនូវភ័ស្តុតាងទាក់ទងនឹងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម*

ភាគីចុងចោទដាក់សំណើចំនួនបីជូនតុលាការ ដើម្បីវាយប្រហារដល់សហចៅក្រមស៊ើបអង្កេតដែលបានអះអាងថាមាន «ហេតុផលច្បាស់លាស់» ដែលអាចជឿថា អៀង ធីរិទ្ធ បានប្រព្រឹត្តនូវអ្វីដែលបានចោទប្រកាន់មែន ។ ទីមួយ ភាគីចុងចោទបញ្ជាក់ថា ករណីរបស់ អៀង ធីរិទ្ធ គឺមានលក្ខណៈផ្សេងពីករណីរបស់ជនជាប់ចោទដទៃទៀតមុនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ទីពី នៅមានកង្វះភ័ស្តុតាងដែលភ្ជាប់ អៀង ធីរិទ្ធ ទៅនឹងអំពើឧក្រិដ្ឋកម្ម ។ ទីបី មិនមានភ័ស្តុតាងដែលបង្ហាញថា អៀង ធីរិទ្ធ អាចប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់ទោះផ្ទាល់ឬមិនផ្ទាល់ក្តី ។ ដោយសារតែការបញ្ជាក់ទាំងនេះពឹងផ្អែកទៅលើភ័ស្តុតាងដែលរកឃើញរបស់សហចៅក្រមស៊ើបអង្កេត ការប្រឆាំងតវ៉ាទាំងនេះគឺមិនត្រូវបានយកមកពិភាក្សាក្នុងសវនាការជាសាធារណៈទេ ។

*២) ការរំលោភទៅលើការសន្មតទុកជាមុនថាគ្មានទោស*

ក្រុមប្រឹក្សាភាគីចុងចោទបានបញ្ជាក់ផងដែរក្នុងការដែលរកឃើញថា «មានហេតុផលច្បាស់ដែលគួរឲ្យជឿជាក់ថា ភាគីចុងចោទពិតជាបានប្រព្រឹត្តអំពើឧក្រិដ្ឋដូចដែលបានចោទប្រកាន់មែន» ដែលសហចៅក្រមស៊ើបអង្កេតបានរំលោភលើសិទ្ធិរបស់ អៀង ធីរិទ្ធ ដែលត្រូវបានសន្មតថាគ្មានទោសដូចដែលត្រូវបានធានាចំពោះជនត្រូវចោទប្រកាន់ក្រោមច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ បើតាមភាគីចុងចោទ ភាពបរាជ័យរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចាត់ទុកការសន្មតទុកជាមុនថាគ្មានទោស អាចនឹងធ្វើឲ្យមានការប៉ះពាល់ដល់សមត្ថភាពរបស់សហចៅក្រមស៊ើបអង្កេតក្នុងការធ្វើការឲ្យចំគោលដៅថាតើលក្ខខណ្ឌសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នត្រូវទទួលយកបាន ។

ការតវ៉ារបស់ភាគីចុងចោទនៅមានលក្ខណៈស្រពេចស្រពិល ។ ទម្រង់និងបែបបទនៃការតវ៉ារបស់ភាគីចុងចោទស្នើថា អាចនឹងមានការប៉ះពាល់ដល់ភាពស្របច្បាប់នៃដំណាក់កាលដែលជាតម្រូវការរបស់វិធាន៦៣(៣) ទោះបីជាភាគីចុងចោទមិនដែលបញ្ជាក់ជាសាធារណៈថា តម្រូវការនៃវិធានទី៦៣(៣) គឺសម្រេចឡើងដោយបុគ្គលដែលប្រឆាំងទៅនឹងការសន្មតទុកជាមុនថាគ្មានទោសក៏ដោយ ។ ព្រះរាជអាជ្ញាបានឆ្លើយតបនឹងការតវ៉ាក៏ដូចជាផលវិបាកនៃការប្រើប្រាស់ពាក្យនៅក្នុងដីកាឃុំខ្លួនបណ្តោះអាសន្នដោយសហចៅក្រមស៊ើបអង្កេតដែលបកប្រែជាភាសាអង់គ្លេស ។ ការបកប្រែជាភាសាអង់គ្លេសពាក្យថា «អាចមាន» មិនត្រូវបានយកមកប្រើប្រាស់ទេ ហើយបានអះអាងថា «មានហេតុផលដែលអាចជឿជាក់បានថា អៀង ធីរិទ្ធ ពិតជាបានប្រព្រឹត្តបទឧក្រិដ្ឋ» ។ តាមរយៈលោក វិនសេន ដឺវ៉ាល ជាអ្នកជំនួយការជាន់ខ្ពស់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបាននិយាយថា សេចក្តីព្រាងដំបូងរបស់ដីកាត្រូវបានសសេរដោយចៅក្រមខ្មែរនិងបារាំង ហើយឯកសារទាំងពីរប្រភេទនេះមានពាក្យថា «អាចមាន» ។

*៣) កង្វះខាតនៃមូលដ្ឋានពិតដើម្បីរកឲ្យឃើញពីភាពចាំបាច់នៃការឃុំឃាំង*

ជាទីបញ្ចប់ ភាគីចុងចោទបានលើកឡើងពីភាពគ្មានមូលដ្ឋានពិតក្នុងការរកឃើញពីភាពចាំបាច់ក្នុងការឃុំខ្លួនបណ្តោះអាសន្នដូចដែលបានចែងក្នុងវិធាន៦៣(៣) ។

**ដីកាសាធារណៈនិងសុវត្ថិភាពផ្ទាល់ខ្លួន**

ភាគីចុងចោទបន្តអះអាងថា វាមិនមែនជាការពិតទេដែលសហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា ការដោះលែង អៀង ធីរិទ្ធ បណ្តោះអាសន្នអាច «ជំរុញឲ្យមានការតវ៉ាប្រឆាំងពីសាធារណជនដែលអាចឈានទៅរកអំពើហិង្សា ហើយអាចប៉ះពាល់ដល់សុវត្ថិភាពរបស់ជនត្រូវចោទ» ។ ភាគីចុងចោទបានបញ្ជាក់ថា ជនត្រូវចោទបានរស់នៅយ៉ាងមានសេរីភាពក្នុងទីក្រុងប៉ៃលិននិងភ្នំពេញតាំងពីឆ្នាំ១៩៧៩មក ដោយមិនមានបង្កឲ្យមានការគំរាមកំហែងអ្វីឡើយ ។ លើសពីនេះទៅទៀត អៀង ធីរិទ្ធ ត្រូវសាធារណជនដឹងជាទូទៅថា គាត់មានមុខតំណែងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចក្នុងរបបកម្ពុជាប្រជាធិតេយ្យ ។ កន្លងមកមិនដែលឃើញមានការប្រឆាំងតវ៉ាពីសំណាក់សាធារណជនឡើយ ។

មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបបញ្ជាក់ថា សាធារណជនដែលរស់នៅជុំវិញអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលា

ការកម្ពុជា និងស្ថានភាពប្រទេសមុនការបោះឆ្នោតក្នុងខែកក្កដា ការដោះលែង អៀង ធីរិទ្ធ ឲ្យនៅក្រៅឃុំអាចធ្វើឲ្យសាធារណជនមានកំហឹងនិងអាចឈានទៅរកការប្រព្រឹត្តអំពើមិនគប្បី ។

## ការជ្រៀតជ្រែកដល់សាក្សីនិងជនរងគ្រោះដោយជនត្រូវចោទនិងអ្នកគាំទ្ររបស់ជនត្រូវចោទ

ភាគីចុងចោទអះអាងថា ការរកឃើញរបស់សហចៅក្រមស៊ើបអង្កេតដែលចោទប្រកាន់ជនត្រូវចោទថា «អាចមានបំណង» ដើម្បីធ្វើការគាបសង្កត់ទៅលើសាក្សីគឺជាការស្មានជាជាងសម្អាងទៅលើការពិត ។ ភាគីចុងចោទតវ៉ាថា គ្មានភស្តុងតាងណាដែលបញ្ជាក់ថាជនត្រូវចោទ គ្រួសារ និងអ្នកគាំទ្ររបស់គាត់បំភ្លៃយុត្តិធម៌ ហើយទៅបំភិតបំភ័យដល់សាក្សីទេ ។ ឆ្លើយតបនឹងការតវ៉ាទាំងនេះ ព្រះរាជអាជ្ញាបានផ្តល់ជូនតុលាការនូវភស្តុតាងជាឧទាហរណ៍ចំនួនពីរពេលដែល អៀង ធីរិទ្ធ ធ្វើការរិះគន់ដល់បុគ្គលជាសាធារណៈ ។ ឧទាហរណ៍ទីមួយ មន្ត្រីរដ្ឋាភិបាលម្នាក់មិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងបន្ទប់សវនាការតាមការស្នើរបស់ អៀង ធីរិទ្ធ បន្ទាប់ពីការចាប់ខ្លួនរបស់ អៀង សារី ដែលជាប្តីរបស់គាត់ ។ ឧទាហរណ៍ទីពីរគឺទាក់ទងទៅនឹងការបញ្ចេញយោបល់តាមរយៈសារព័ត៌មានដែល អៀង ធីរិទ្ធ បានចោទប្រកាន់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាថា «ជាជនកុហកដែលគិតតែពីលុយ» ។ បន្ថែមលើសពីអ្វីដែលបានធ្វើបំភិតបំភ័យដល់សាក្សី ព្រះរាជអាជ្ញាបានបញ្ជាក់ថា ឥទ្ធិពលក្នុងជួរនយោបាយរបស់គ្រួសារ អៀង ធីរិទ្ធ ជាពិសេសនៅក្នុងទីក្រុងប៉ៃលិន អាចធ្វើឲ្យមានការបំភិតបំភ័យដល់សាក្សីបើសិនជាជនត្រូវចោទត្រូវបានដោះលែង ។

## ការមិនបានចូលខ្លួនក្នុងសវនាការឬភាពប្រថុយក្នុងការហោះហើរទៅក្រៅប្រទេស

បើតាមភាគីចុងចោទ អៀង ធីរិទ្ធ ត្រូវប្រឈមមុខនឹងការកាត់ទោសដែលបញ្ជាក់ថាគាត់មិនអាចហោះហើរទៅក្រៅប្រទេសបានទេ ។ ទោះបីជាជនត្រូវចោទត្រូវទទួលទោសធ្ងន់ធ្ងរ ឬរយៈពេលយូរប៉ុណ្ណាក៏ដោយ ក៏ អៀង ធីរិទ្ធ នឹងមិនគេចខ្លួនទេ ហើយទៅរស់នៅដោយប្រើឈ្មោះក្លែងក្លាយ នៅពេលដឹងថាគាត់ត្រូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវកោះហៅជាចាំបាច់នោះ ។ ភាគីចុងចោទបានបញ្ជាក់ថា ជនត្រូវចោទត្រូវទទួលនូវការពិនិត្យសុខភាពក្នុងប្រទេសថៃជាចាំបាច់ ហើយជនត្រូវចោទតែងធ្វើដំណើរចេញចូលប្រទេសថៃជាញឹកញាប់ ។ បើទោះជាជនត្រូវចោទស្ថិតនៅក្នុងប្រទេសថៃក៏ដោយ គាត់ក៏ត្រូវបញ្ជូនមកប្រទេសកម្ពុជាវិញបានដែរ ។

ព្រះរាជអាជ្ញាបានប្រឆាំងដោយបញ្ជាក់ថា ការដាក់ពាក្យសុំទិដ្ឋាការទៅកាន់ប្រទេសថៃមុនគាត់ត្រូវបានចាប់ខ្លួនគឺជារឿងអាចធ្វើបានធម្មតា មានន័យថាបើគាត់ស្នើទិដ្ឋាការមុនគាត់ត្រូវចាប់ខ្លួន ហើយគាត់អាចធ្វើដំណើរទៅបានបើសិនជាគាត់ត្រូវដោះលែង ។ ព្រះរាជអាជ្ញាបានបន្ថែមទៀតថា ជនត្រូវចោទនៅមានលិខិតឆ្លងដែនដែលមានសុពលភាពនៅឡើយ ហើយដោយសារតែសាច់សាលោហិតរបស់គាត់នៅមានឥទ្ធិពល ជនត្រូវចោទអាចរៀបចំដើម្បីគេចខ្លួនទៅរស់នៅប្រទេសដទៃទៀតដែលមិនមានសន្ធិសញ្ញាបត្យាប័នជាមួយប្រទេសកម្ពុជា ។ លើសពីនេះទៅទៀត អៀង ធីរិទ្ធ នៅមានធនធានហិរញ្ញវត្ថុជាច្រើនទោះបីជាគាត់បានផ្ទេរថវិកាទៅឲ្យកូនរបស់គាត់ក៏ដោយ ។ ហេតុដូច្នេះ ព្រះរាជអាជ្ញាបានបញ្ជាក់ច្បាស់ថា ការដែលអះអាងថាជនត្រូវចោទក្រីក្រខាងផ្នែកហិរញ្ញវត្ថុគឺជារឿងខុសស្រឡះ ។

## ការតវ៉ាអំពីបញ្ហាសុខភាព

ភាគីចុងចោទអះអាងដោយតវ៉ាថា ខ្លួនបានបញ្ជូនឯកសារនិងសេចក្តីបញ្ជាក់ពីបញ្ហាសុខភាពជាច្រើនប្រភេទដែលបង្ហាញថា អៀង ធីរិទ្ធ ទទួលរងនូវបញ្ហាទាំងផ្លូវកាយនិងផ្លូវចិត្តដែលទាមទារឲ្យមានការព្យាបាលជាចាំបាច់និងជាប្រចាំ ។ សហព្រះរាជអាជ្ញាបានតបមកវិញថា ឯកសារដែលបញ្ជូនដោយភាគីចុងចោទគឺមិនសំខាន់ ហើយឯកសារទាំងនោះគ្រាន់តែបញ្ជាក់ពីស្ថានភាពជំងឺដែលជារឿងធម្មតារបស់ស្ត្រីមានវ័យចំណាស់នេះ ។ លើសពីនេះទៅទៀត ព្រះរាជអាជ្ញាបានបន្ថែមទៀតថា សេវាសុខភាពដែលផ្តល់ជូនដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺលើសពីគ្រប់គ្រាន់ទៅទៀត ។ ព្រះរាជអាជ្ញាបានបិទសំណុំរឿងបែបបទដោយបញ្ជាក់ថា អ្វីដែលបានផ្តល់ជូន អៀង ធីរិទ្ធ គឺលើសអ្វីដែលប្រជាជនកម្ពុជាទូទៅទទួលបានទៅទៀត ។

**រ៉េនដល ជីហ្វាល់ក្វ និង ចារ៉េត ខ៉ាត់ឃីន**

# ការកាត់ទោសពីការបង្អត់អាហារដោយច្បាប់នៃអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា

គោលបំណងចម្បងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺរកយុត្តិធម៌ឲ្យជនរងគ្រោះក្នុងរបបខ្មែរក្រហម ។ ការដែលធ្វើបែបនេះបាន យើងត្រូវតែកាត់ទោសឧក្រិដ្ឋកម្មដែលសំខាន់ជាងគេចំពោះជនរងគ្រោះ ។ ដូចដែលខ្ញុំបានសរសេរនៅក្នុងទស្សនាវដ្តីស្វែងរកការពិតលេខ៩៧ (ខែមករា ឆ្នាំ២០០៨) អំពីការស្វែងយល់រឿងរ៉ាវរបស់ជនរងគ្រោះឃើញថាមានលេចឡើងនូវរឿងរ៉ាវដូចៗគ្នាជាច្រើន ។ ជនរងគ្រោះច្រើននិយាយពីការខ្វះខាតអាហារជាជាងការការសម្លាប់និងការធ្វើទណ្ឌកម្ម ។ សម្រាប់ប្រជាជនជាច្រើន អារម្មណ៍អត់ឃ្លានគឺជាការចងចាំដ៏ខ្លាំងបំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ទោះបីជាមានប្រជាជនរាប់សែននាក់ស្លាប់ដោយសារភាពអត់ឃ្លានក្នុងរបបខ្មែរក្រហមក៏ដោយ ក៏ការកាត់ទោសមេដឹកនាំខ្មែរក្រហមមិនមែនជាការងាយស្រួលដែរ ។ យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានព្រំដែន ហើយអាចកាត់ទោសចុងចោទពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទល្មើសផ្សេងៗមួយចំនួនទៀត ។ ជាងនេះទៅទៀត អង្គជំនុំជម្រះមានយុត្តាធិការកាត់ទោសតែមេដឹកនាំជាន់ខ្ពស់និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនៅសម័យនោះប៉ុណ្ណោះ ។ ពិចារណាដល់បញ្ហានេះ អត្ថបទនេះនឹងពិភាក្សាថាតើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងកាត់ទោសការបង្អត់អាហារដោយរបៀបណា ។

រដ្ឋាភិបាលមួយចំនួននៅក្នុងប្រវត្តិសាស្ត្រសម័យទំនើបបានដាក់កម្រិតផលិតកម្មនិងការផ្តល់អាហារជាមធ្យោបាយនៃការគ្រប់គ្រងនយោបាយ ។ ទោះបីជាការបង្អត់អាហាររបស់រដ្ឋាភិបាលបានធ្វើឲ្យប្រជាជនរាប់លាននាក់ស្លាប់ក៏ដោយ ក៏គេមិនអាចចាត់ទុកការបំពាននេះជាអំពើឃោរឃៅដែលមានតែការអះអាងពីជនរងគ្រោះតែមួយផ្នែកនោះបានទេ ។ ហេតុផលមួយដែលរដ្ឋាភិបាលអាចបង្អត់អាហារដោយមិនទទួលទោស គឺរដ្ឋាភិបាលមានសិទ្ធិស្តីបន្ទោសទៅលើការខ្វះខាតអាហារថាមកពីស្ថានភាពនៅឆ្នាំនោះមិនល្អ ដូចជាអាកាសធាតុមិនអំណោយផលឬការប្រមូលផលមិនគ្រប់គ្រាន់ ។ វាមានការពិបាកណាស់ក្នុងការបង្ហាញថា ការបង្អត់អាហារជាសកម្មភាពឧក្រិដ្ឋកម្មដែលបានប៉ុនប៉ងទុកជាមុនមិនមែនជាផលវិបាកនៃផែនការមិនល្អឬការមិនបានរំពឹងទុកទេ ។ ដូច្នេះ រហូតមកដល់សព្វថ្ងៃនេះ គ្មានតុលាការអន្តរជាតិណាធ្លាប់បានកាត់ទោសអ្នកដឹកនាំរដ្ឋាភិបាលពីបទបង្អត់អាហារប្រជាជនឡើយ ។

## ការកាត់ទោសពីការបង្អត់អាហារជាឧក្រិដ្ឋកម្មសង្គ្រាម

មានវិធានច្បាប់ដ៏វែងជាច្រើនត្រូវបានបង្កើតឡើងដើម្បីរកខុសត្រូវជូនប្រជាជនសាមញ្ញនៅសម័យសង្គ្រាម ។ ជាប្រវត្តិសាស្ត្រ ការបង្អត់អាហារជាមធ្យោបាយដឹកនាំប្រទេសមិនល្អដែលនេះអាចចាត់ទុកថាជាយុត្តិសាស្ត្រអាចទទួលយកបាន ។ ទោះបីជាក្រោយមកមានការបង្កើតវិធានច្បាប់សង្គ្រាមដែលមានការទទួលស្គាល់ក៏ដោយ ក៏ការបង្អត់អាហារនិងការឡោមព័ទ្ធទីក្រុងដើម្បីបណ្តេញប្រជាជនមិនអាចចាត់ទុកថាជាអំពើខុសច្បាប់បានឡើយ ។ ជាឧទាហរណ៍ នៅពេលកាត់ទោសអ្នកដឹកនាំជាន់ខ្ពស់របបណាហ្ស៊ីក្រោយសង្គ្រាមលោកលើកទីពីរ (វន់ លីប សហរដ្ឋអាមេរិក) តុលាការយោធាអាមេរិកមិនបានដាក់ទោសការឡោមព័ទ្ធទីក្រុងឡេនីនក្រាត ដែលធ្វើឲ្យប្រជាជនរុស្សីជាងមួយលាននាក់ស្លាប់ទេ ដោយនិយាយថា «យើងប្រហែលជាចង់ឲ្យច្បាប់ខុសពីនេះ ប៉ុន្តែយើងត្រូវតែអនុវត្តទៅតាមអ្វីដែលយើងបានបង្កើតឡើង» ។ តុលាការបានបញ្ជាក់ថាៈ

មេបញ្ជាការសង្គ្រាមប្រហែលជាមានសិទ្ធិត្រឹមត្រូវតាមច្បាប់ដើម្បីឡោមព័ទ្ធកន្លែងមួយដែលស្ថិតក្រោមការគ្រប់គ្រងរបស់សត្រូវ ហើយក៏អាចបំបែកប្រជាជនពីបងប្អូនសាច់ញាតិបានដែរ ។ ធ្វើបែបនេះ ការធ្វើឲ្យមានការបង្អត់អាហារមិនមែនជា

បញ្ហាទេ ។ ដូច្នេះ រាល់ការកាត់បន្ថយអាហារគឺស្របច្បាប់ ។

នៅក្នុងកិច្ចព្រមព្រៀងអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ ចែងថា ច្បាប់មនុស្សធម៌មិនទទួលស្គាល់សិទ្ធិរបស់កងទ័ពដែលមិនផ្ដល់អាហារឲ្យប្រជាជនដើម្បីបង្កើនផលប្រយោជន៍របស់យោធាទេ ។ ទោះជាយ៉ាងណាក៏ដោយ ការហាមឃាត់នេះមិនសូវជាមានភាពទូលំទូលាយទេ ។ តាមមាត្រា២៣ នៃអនុសញ្ញាលើកទី៤ បានអះអាងថា យោធាម្នាក់ត្រូវតែទទួលបានការអនុញ្ញាតឲ្យផ្ដល់អាហារដែលមានជីវជាតិទៅឲ្យ «ក្មេងក្រោមអាយុ១៥ឆ្នាំ ស្ត្រីមានផ្ទៃពោះ និង ស្ត្រីដែលទើបតែសម្រាលកូន» ។ ជាងនេះទៅទៀត ការហាមឃាត់នេះគឺយោងទៅតាមស្ថានភាពសង្គ្រាម ហើយគ្មាន «ហេតុផលចាំបាច់សម្រាប់ឲ្យកងទ័ពបង្កើតភាពភ័យខ្លាចទេ» ហើយម្យ៉ាងទៀត សត្រូវប្រហែលជាអាចបង្កើនផលប្រយោជន៍របស់ខ្លួនប្រសិនបើយើងមិនធ្វើដូច្នោះ ។ អាស្រ័យហេតុនេះ មិនត្រឹមតែសិទ្ធិផ្ទាល់ខ្លួនរបស់ប្រជាជនមានព្រំដែនទេ ពេលខ្លះក៏មានការបំបិទសិទ្ធិផ្សេងៗទៀតដែរ ។ ទើបតែមានកិច្ចព្រមព្រៀងអនុសញ្ញាបន្ថែមនៅឆ្នាំ១៩៧៧ ចែងថា «ការបង្អត់អាហារប្រជាជនគឺជាយុត្តិសាស្ត្រធ្វើសង្គ្រាមឬក៏ការតស៊ូ» ការធ្វើបែបនេះត្រូវបានហាមឃាត់ជាកំហិត ។

ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើឲ្យអង្គជំនុំជម្រះមានលទ្ធភាពកាត់ទោសការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ ប៉ុន្តែមិនមែនការរំលោភទៅលើអនុសញ្ញាដែលមានការព្រមព្រៀងបន្ទាប់មកទេ ។ ដើម្បីកាត់ទោសនរណាម្នាក់ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ត្រូវតែមានការបង្ហាញពីទំនាក់ទំនងរវាងច្បាប់ឧក្រិដ្ឋកម្មនិងចម្បាំងប្រដាប់អាវុធអន្តរជាតិ ។ ព្រះរាជអាជ្ញានៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រហែលជាព្យាយាមជជែកថា ប្រទេសកម្ពុជាធ្លាប់មានសង្គ្រាមជាមួយវៀតណាមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ។ ប្រសិនបើការជជែកនេះមានប្រសិទ្ធភាព ព្រះរាជាអាជ្ញាទំនងជាតម្រូវឲ្យបង្ហាញថា ការអត់ឃ្លានរបស់ប្រជាជនកម្ពុជាគឺទាក់ទងនឹងសង្គ្រាមជាមួយវៀតណាម ។

កាន់តែមានបញ្ហាច្រើនទាក់ទងនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាលើកទី៤ គឺថាច្បាប់ដែលបញ្ជាក់ដោយអនុសញ្ញាហាក់ដូចជាបង្កើនការទទួលខុសត្រូវជាបុគ្គលទៅលើឧក្រិដ្ឋកម្ម ការទទួលខុសត្រូវនេះមិនរាប់បញ្ចូលការមិនអនុញ្ញាតឲ្យផ្ដល់អាហារទេ ។ ដោយសារតែច្បាប់អង្គជំនុំជម្រះបានកំណត់យុត្តាធិការរបស់តុលាការចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ វាមិនទំនងថា ចៅក្រមនឹងអនុញ្ញាតឲ្យមានការកាត់ទោសឧក្រិដ្ឋកម្មសង្គ្រាមដោយច្បាប់អនុសញ្ញាទេ ។ ដូច្នេះ ការបង្អត់អាហារនឹងមិនទំនងជាត្រូវបានកាត់ទោសដោយឧក្រិដ្ឋកម្មសង្គ្រាមក្នុងអង្គជំនុំជម្រះទេ ។

## ការកាត់ទោសពីការបង្អត់អាហារជាអំពើប្រល័យពូជសាសន៍

បញ្ហាចម្រូងចម្រាសមួយដែលព្រះរាជអាជ្ញានិងចៅក្រមនៅអង្គជំនុំជម្រះត្រូវប្រឈមមុខ គឺថាគួរតែចោទប្រកាន់មេដឹកនាំខ្មែរក្រហមដោយអំពើប្រល័យពូជសាសន៍ឬក៏អត់ ។ ច្បាប់អង្គជំនុំជម្រះដែលឆ្លុះបញ្ចាំងអនុសញ្ញាអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ ឲ្យនិយមន័យអំពើប្រល័យពូជសាសន៍ថា «សកម្មភាពទាំងឡាយណាដែលប្រព្រឹត្តឡើងក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុងឬមួយផ្នែក ឬទៅលើប្រជាជាតិ ជាតិពន្ធុ ពូជសាសន៍ឬក្រុមសាសនាណាមួយ» ។ សកម្មភាពនេះរួមបញ្ចូលទាំង «ការបង្ករបួសស្នាមដោយចេតនាទៅលើក្រុមណាមួយដែលនឹងនាំមកនូវការបំផ្លាញដល់រូបកាយទាំងមូលឬមួយផ្នែក» ។ អាស្រ័យហេតុនេះ ការបង្អត់អាហារអាចត្រូវបានកាត់ទោសជាប្រភេទមួយនៃការប្រព្រឹត្តអំពើប្រល័យពូជសាសន៍» ។

យ៉ាងណាមិញ ដើម្បីកាត់ទោសអំពើប្រល័យពូជសាសន៍ ប្រជាជនទាំងនោះត្រូវតែជាប្រជាជាតិ ជាតិពន្ធុ ជាតិសាសន៍ ឬក្រុមសាសនា ។ យោងទៅតាមអត្ថន័យនេះ ក្រុមសង្គមនិងនយោបាយមិនអាចជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍បានទេ ។ ប្រជាជនកម្ពុជាជាងមួយភាគប្រាំបានស្លាប់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយជនរងគ្រោះភាគច្រើនជាជនជាតិខ្មែរ ។ ទោះបីជាការពិភាក្សាមួយអាចធ្វើឡើងថា ខ្មែរក្រហមធ្វើមិនស្មើភាពគ្នាទៅលើក្រុមមួយចំនួន ដូចជា ចាម មូស្លីម និង វៀតណាម ប៉ុន្តែ ប្រជាជនខ្មែរក៏មិនបានទទួលអាហារគ្រប់គ្រាន់ដែរ ដូច្នេះ វាមានការពិបាកណាស់ក្នុងការបង្ហាញថា គោលនយោបាយបង្អត់

អាហាររបស់រដ្ឋាភិបាលគឺដើម្បីលុបបំបាត់ក្រុមដែលត្រូវការពារនេះ ។ ដូច្នេះ ព្រះរាជអាជ្ញាមិនទំនងជាចោទប្រកាន់ការបង្អត់អាហារដោយឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេ ។

## ការកាត់ទោសពីការបង្អត់អាហារដោយឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់បំផុតពូជ

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចាត់ទុកថាស្រដៀងគ្នានឹងអំពើព្រៃផ្សៃនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ជាទូទៅឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់បំផុតពូជមិនត្រឹមតែស្រដៀងគ្នានឹងអំពើព្រៃផ្សៃនោះទេ តែថែមទាំងស្រដៀងគ្នានឹងអំពើប្រល័យពូជសាសន៍ដែលសម្លាប់មនុស្សជាច្រើនដោយខុសច្បាប់ ។ ច្បាប់អង្គជំនុំជម្រះវិសាមញ្ញឲ្យអត្ថន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថា «រាល់សកម្មភាពដែលធ្វើឡើងជាសាកលឬជាប្រព័ន្ធក្នុងគោលបំណងធ្វើបាបដោយផ្ទាល់ទៅលើប្រជាជនសាមញ្ញ ជនជាតិ នយោបាយ ជាតិពន្ធ ពូជសាសន៍ ឬសាសនា» ។

ដូច្នេះ ដើម្បីកាត់ទោសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រះរាជអាជ្ញាត្រូវតែបំភ្លឺថាមានការធ្វើបាបជាសាកលឬជាប្រព័ន្ធទៅលើប្រជាជន នយោបាយ ជាតិពន្ធ ពូជសាសន៍ ឬសាសនា ។ យុត្តិសាស្ត្រអន្តរជាតិមានលក្ខណៈទូលំទូលាយក្នុងការកំណត់ថាអ្វីបង្កើតឲ្យមានការវាយប្រហារ ។ ជាឧទាហរណ៍ ការវាយប្រហារមិនទាន់ឈានទៅដល់ការធ្វើសង្គ្រាមប្រដាប់អាវុធទេ ។ ដូចគ្នានេះដែរ តុលាការធ្លាប់មានយុត្តិធម៌ក្នុងការកំណត់អ្វីដែលបង្កើតឲ្យមានការប៉ុនប៉ងវាយប្រហារលើការរើសអើងពូជសាសន៍ ។ ដូច្នេះវាមិនមានការលំបាកក្នុងការបង្ហាញថាមានការវាយប្រហារទៅលើប្រជាជនកម្ពុជាខណៈពេលដែលមានការបង្អត់អាហារ ។

នៅពេលដែលច្បាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានបង្កើតឡើង ត្រូវតែមានការអះអាងបញ្ជាក់ថា មានសកម្មភាពឧក្រិដ្ឋកម្ម ។ ក្នុងករណីឧក្រិដ្ឋកម្មសម្លាប់ផ្តាច់ពូជ ត្រូវតែមានការបំភ្លឺថាមានការសម្លាប់ដោយបានប៉ុនប៉ងទុកជាមុន ។ តុលាការព្រហ្មទណ្ឌអន្តរជាតិនៅប្រទេសរ៉្វាន់ដាដែលកំណត់អត្ថន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្រដៀងគ្នានឹងអង្គជំនុំជម្រះ គឺថាការសម្លាប់បំផុតពូជអាចកើតឡើងតាមរយៈ «សម្លាប់ជីវិតអ្នកដទៃដើម្បីស្ពានភាពរស់នៅរបស់ខ្លួនឯង តាមរយៈ...សកម្មភាពឬការ



សកម្មភាពរបស់អ្នកភូមិកំពុងបំពេញពាក្យបណ្តឹងនៅខេត្តកំពង់ឆ្នាំង

លុបបំបាត់ចោល» ដូចជា «ការបំបាត់តម្រូវការចាំបាច់សម្រាប់ជីវិត» ។ នេះអាចសន្មតថាជាការបង្អត់អាហារ ។ លើសពីនេះទៅទៀត ច្បាប់រ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិចែងយ៉ាងច្បាស់ថា ការសម្លាប់បំផុតពូជរួមបញ្ចូលទាំង «ការបង្អត់អាហារ...អាចនាំឲ្យមានវិនាសកម្មដល់ប្រជាជនមួយផ្នែក» ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទទួលយកអត្ថន័យស្រដៀងគ្នានៃការសម្លាប់បំផុតពូជនេះ ព្រះរាជអាជ្ញាត្រូវតែអះអាងថា ការបង្អត់អាហារគឺធ្វើឡើងដោយចេតនាជាជាងកើតឡើងដោយគាប់ជួន គឺថាការបង្អត់អាហារគួរតែត្រូវបានបង្ការទុក ។ ជាងនេះទៅទៀត ត្រូវតែមានការបង្ហាញថាមានសកម្មភាពប្រព្រឹត្តឡើងដែលពាក់ព័ន្ធនឹងការវាយប្រហារប្រជាជនស៊ីវិល ។ បន្ថែមទៅលើការប៉ុនប៉ងបង្អត់អាហារ ចុងចោទត្រូវតែបានដឹងថាឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តជាផ្នែកមួយនៃការវាយប្រហារដ៏ធ្ងន់ធ្ងរ ។

គោលនយោបាយចម្បងមួយនៃរបបកម្ពុជាប្រជាធិបតេយ្យគឺដើម្បីលុបបំបាត់ទ្រព្យសម្បត្តិឯកជន ។ នេះមានន័យថា អ្វីទាំងអស់នៅក្នុងសហករណ៍ជាកម្មសិទ្ធិរបស់រដ្ឋាភិបាលមជ្ឈិម ហើយការចែកចាយអាហារត្រូវបានត្រួតពិនិត្យដោយប្រធានសហករណ៍ ។ រាល់សហករណ៍ត្រូវតែប្រគល់ទិន្នផលមួយផ្នែកទៅឲ្យរដ្ឋាភិបាលមជ្ឈិមទុកជាពន្ធ ។ រដ្ឋាភិបាលយល់ឃើញថា ពន្ធនេះមានសារសំខាន់សម្រាប់បង្កើនចំណូល ។ ដោយហេតុនេះ សហករណ៍នីមួយៗធ្វើគ្រប់បែបយ៉ាងដោយមិនខ្លាចក្រែង ហើយព្យាយាមបំពេញចិត្តរដ្ឋាភិបាលមជ្ឈិម ដែលជាទូទៅចាត់ទុកការធ្វើឲ្យគ្រប់ពន្ធមានសារសំខាន់ជាងផ្តល់អាហារទៅឲ្យប្រជាជន ។ អ្នកដែលនៅរស់ពីរបបខ្មែរក្រហមផ្តល់របាយការណ៍ថា ឃើញអង្ករជាច្រើនដឹកចេញតាមរថយន្ត ខណៈពេលដែលប្រជាជនក្នុងសហករណ៍កំពុងតែស្រេកឃ្លាន ។ គោលនយោបាយមួយទៀតដែលធ្វើឲ្យមានភាពអត់ឃ្លាន គឺការហាមឃាត់មិនឲ្យប្រជាជនដើរស្វែងរកអាហារដោយគ្មានការអនុញ្ញាត ។ ប្រសិនប្រធានសហករណ៍ចាប់បានលើសពីមួយលើក ប្រជាជននោះនឹងត្រូវបានចាប់ខ្លួនឬយកទៅសម្លាប់ ។

ជនត្រូវចោទទំនងជាអះអាងថា សកម្មភាពទាំងអស់នេះមិនមែនកើតឡើងដោយគោលនយោបាយរបស់រដ្ឋាភិបាលមជ្ឈិមនោះទេ ប៉ុន្តែគឺជាការសម្រេចចិត្តដោយឯករាជរបស់មន្ត្រីថ្នាក់ទាប ។ ដើម្បីអះអាងជុយពីនេះ ព្រះរាជអាជ្ញាត្រូវតែបំភ្លឺថា មានទំនាក់ទំនងដោយផ្ទាល់រវាងមន្ត្រីរាជការជាន់ខ្ពស់និងអ្នកអនុវត្តដែលធ្វើឲ្យមានភាពអត់ឃ្លាន ឬក៏ផ្តល់ភ័ស្តុតាងថាមានការធ្វើបែបនេះនៅតំបន់ផ្សេងនៅក្នុងប្រទេសដើម្បីបញ្ជាក់ថាបញ្ជានេះចេញមកពីរដ្ឋាភិបាលមជ្ឈិម ។

ប្រសិនបើទំនាក់ទំនងរវាងគោលនយោបាយរបស់រដ្ឋាភិបាលមជ្ឈិមនិងការបង្អត់អាហារត្រូវបានរកឃើញ ព្រះរាជអាជ្ញាត្រូវតែតម្រូវឲ្យស្រាយបំភ្លឺថា មេដឹកនាំបានប្រព្រឹត្តឧក្រិដ្ឋកម្មដោយមានការប៉ុនប៉ង ដូចជាយល់ស្របឬបង្គាប់ឲ្យអ្នកក្រោមបង្គាប់អនុវត្តតាមគោលនយោបាយទាំងនេះ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានកំណត់អត្ថន័យការប៉ុនប៉ងធ្វើឧក្រិដ្ឋកម្មនៃការសម្លាប់បំផុតពូជថា «ជាការប៉ុនប៉ងសម្លាប់ការធ្វេសប្រហែស ឬក៏ភាពឃ្លើឃ្លាមិនទទួលខុសត្រូវរបស់ថ្នាក់លើដែលអាចធ្វើឲ្យមានការសម្លាប់» ។ ដូច្នេះ ព្រះរាជអាជ្ញាយ៉ាងហោចណាស់ត្រូវតែអះអាងថា មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមានភាពឃ្លើឃ្លាដែលនាំឲ្យប្រជាជនរាប់ពាន់នាក់ស្លាប់ដោយអត់ឃ្លាន ។

ដោយសារតែមានការលំបាកក្នុងការបញ្ជាក់ភ័ស្តុតាងនៃការសម្រេចចិត្តរបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលបណ្តាលឲ្យមានការបង្អត់អាហារ ព្រះរាជអាជ្ញាអាចបំភ្លឺថា មេដឹកនាំក៏បានចូលរួមក្នុងគម្រោងឧក្រិដ្ឋកម្មនេះដែរ ព្រោះការអត់ឃ្លានគឺជាលទ្ធផលមួយដែលអាចដឹងមុន ។ ជាពិសេស ព្រះរាជអាជ្ញាអាចព្យាយាមអះអាងថា មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមរួមគំនិតដើម្បីជម្លៀសដាក់គុក និងប្រើប្រជាជនកម្ពុជាដូចជាទាសករ ។ វាអាចឲ្យដឹងមុនថា សកម្មភាពទាំងនេះអាចនាំឲ្យមានភាពអត់ឃ្លានយ៉ាងធ្ងន់ធ្ងរ ហើយអ្នកដឹកនាំដឹងពីការប្រថុយនេះថានឹងនាំឲ្យមានភាពអត់ឃ្លានកើតឡើង ។

បន្ទាប់ពីខ្មែរក្រហមចូលមកដល់ភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនត្រូវបង្ខំឲ្យចាកចេញដោយមិនគិតទៅដល់បញ្ហារូបរាងកាយនោះទេ ។ មនុស្សចាស់ កូនក្មេង និងអ្នកជំងឺត្រូវបានជម្លៀសទៅជាមួយគ្នា ហើយប្រាប់ថាឲ្យទៅស្រុក

ស្រែ ។ ប្រជាជនមិនបានទទួលអាហារសម្រាប់ធ្វើដំណើរដែលមានរយៈពេលលើសពីបីសប្តាហ៍ ។ ជាលទ្ធផល ប្រជាជនជាច្រើនអត់អាហាររហូតដល់ជិតស្លាប់ ហើយព្យាយាមត្រឡប់មកភូមិដែលខ្លួនស្គាល់វិញ ។ ភ័ស្តុតាងមួយបញ្ជាក់ថា មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមានគម្រោងរយៈពេលវែងក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងក៏ដូចជារដ្ឋធានី ។ គម្រោងនេះត្រូវបានអនុវត្តទោះបីជាមានការប្រថុយប្រថានយ៉ាងខ្លាំងថា អ្នកដែលត្រូវគេជម្លៀសជាច្រើនអាចឃ្លានរហូតដល់ស្លាប់ ។

យោងទៅតាមរបាយការណ៍ភាគច្រើនបានឲ្យដឹងថា ចលនាបង្ខំប្រជាជនជាបន្តបន្ទាប់ឲ្យទៅភូមិភាគពាយ័ព្យមានការលំបាកជាងការជម្លៀសនៅភ្នំពេញ ។ ចាប់ផ្តើមតាំងពីឆ្នាំ១៩៧៥ ប្រជាជន៨សែននាក់ដែលភាគច្រើនជាអតីតអ្នករស់នៅភ្នំពេញត្រូវបានបង្ខំឲ្យចេញពីភូមិភាគនិរតី និងខាងកើតទៅកាន់ភូមិភាគពាយ័ព្យដោយផ្តល់អាហារមិនគ្រប់គ្រាន់ ។ ចាប់ផ្តើមដំបូង ប្រជាជនស្លាប់ដោយអត់ឃ្លានព្រោះតែខ្វះខាតអាហារ ។ មេដឹកនាំគួរតែបានដឹងថាមានការជម្លៀសប្រជាជនដែលធ្វើប្រជាជនភូមិភាគពាយ័ព្យកើនឡើងជិតពីរដង ការជម្លៀសនេះអាចនាំទៅរកភាពវិនាស ។ ជាងនេះទៅទៀត មានភ័ស្តុតាងបញ្ជាក់ថា មេដឹកនាំភូមិភាគពាយ័ព្យបានប្រាប់ដំណឹងដល់រដ្ឋាភិបាលមជ្ឈិមថា ការជម្លៀសប្រជាជនចំនួនច្រើនទៅកាន់ភូមិភាគពាយ័ព្យបែបនេះ អាចនាំឲ្យមានភាពអត់ឃ្លានកាន់តែខ្លាំង ។ ទោះបីជាដឹងបញ្ហានេះក៏ដោយ មេដឹកនាំខ្មែរក្រហមនៅតែសម្រេចចិត្តថា ការជម្លៀសមានសារសំខាន់ដែលអាចធ្វើឲ្យគោលដៅផលិតផលកសិកម្មរបស់រដ្ឋាភិបាលសម្រេចបានជោគជ័យ ។ ខ្មែរក្រហមចង់ឲ្យប្រទេសកម្ពុជាក្លាយជាគំរូបដិវត្តន៍របស់ជនកុម្មុយនីស្ត ។ ដូច្នេះ ខ្មែរក្រហមបានបង្កើតជាផលិតកម្មដែលមិនគួរឲ្យជឿមួយនិងនាំចេញគ្រប់តម្រូវការ ។ ដើម្បីសម្រេចទិសដៅនេះ រដ្ឋាភិបាលបានផ្តោតទៅលើការបង្កើនផលិតកម្មនៅភូមិភាគពាយ័ព្យដែលជំរុញឲ្យមានការធ្វើអង្ករឲ្យបានច្រើននៅទូទាំងប្រទេស ។ នៅឆ្នាំ១៩៧៥ រដ្ឋាភិបាលគិតថា ភូមិភាគពាយ័ព្យខ្វះប្រជាជន ដូច្នេះ ត្រូវការអ្នកធ្វើការ៥សែននាក់បន្ថែមទៀតដើម្បីទទួលបានសមិទ្ធផលច្រើនបំផុតនិងសម្រេចបានតាមទិសដៅផលិតកម្ម ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមិនអាចផ្តល់អាហារដល់ប្រជាជនបន្ថែមទេ ។

## សេចក្តីសន្និដ្ឋាន

បទពិសោធន៍រួមមួយដែលប្រជាជនស្ទើតែទាំងអស់បានឆ្លងកាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺការខ្វះខាតអាហារ ។ ការបង្អត់អាហារគឺជាឧក្រិដ្ឋកម្មដែលកើតមាននៅគ្រប់ទីកន្លែង ។ ការកាត់ទោសឧក្រិដ្ឋកម្មនេះ មិនត្រឹមតែអាចផ្តល់យុត្តិធម៌ដល់ជនរងគ្រោះរាប់សែននាក់នោះទេ ថែមទាំងអាចទុកជាប្រវត្តិសាស្ត្រសម្រាប់ដល់កូនចៅជំនាន់ក្រោយដឹងថា សហគមន៍អន្តរជាតិនឹងមិនអត់ឱនឲ្យរដ្ឋាភិបាលដែលបានរំលោភបំពានទៅលើប្រជាជនដោយប្រើអាហារជាមធ្យោបាយដើម្បីបង្កើនអំណាចទេ ។

តាមការពិត ការកាត់ទោសពីការបង្អត់អាហារគឺជាបញ្ហាស្មុគស្មាញ ។ ចុងចោទទំនងជាអះអាងថា គេមិនបានដឹងពីរឿងហេតុដែលកើតឡើងនៅតាមតំបន់នោះទេ ហើយអាចជំទាស់យ៉ាងមានប្រសិទ្ធភាពចំពោះការបង្អត់អាហារ ព្រោះនៅតាមតំបន់មានប្រជាជនស្លាប់បន្តិចម្តងៗនិងដោយប្រយោល ។ ទោះជាយ៉ាងណាក៏ដោយ ការអត់ឃ្លានកើតមានឡើងដោយសារការជម្លៀសនៅភ្នំពេញ ចលនាបង្ខំប្រជាជនឲ្យធ្វើដំណើរទៅភូមិភាគពាយ័ព្យនិងទិសដៅផលិតកម្មមិនគួរឲ្យជឿរបស់រដ្ឋាភិបាលដែលបានដឹងច្បាស់ពីផលវិបាកនៃទិសដៅនេះ ។ បន្ថែមទៅលើនេះទៀត មានភ័ស្តុតាងនៅក្នុងសុន្ទរកថា របាយការណ៍ និងការជួបប្រជុំរបស់គណៈកម្មាធិការដែលថាមេដឹកនាំជាន់ខ្ពស់ដឹងថាមានការបង្អត់អាហារ ។ មេដឹកនាំមិនត្រឹមតែមិនបានធ្វើសកម្មភាពទប់ស្កាត់ការខ្វះខាតអាហារប៉ុណ្ណោះទេ ថែមទាំងនៅតែបន្តជំរុញគោលនយោបាយនេះឲ្យដើរទៅមុខដែលធ្វើឲ្យស្ថានភាពកាន់តែមានភាពលំបាក ។ ដូច្នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគួរតែកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងការសម្លាប់បំផុតពូជសម្រាប់ភាពអត់ឃ្លានដែលបង្កឡើងដោយគោលនយោបាយសង្គមកិច្ចនិងសេដ្ឋកិច្ចរបស់ខ្លួន ។ សហគមន៍អន្តរជាតិធ្លាប់បានធ្វើឲ្យប្រជាជនកម្ពុជាខកចិត្តម្តងហើយ ដូច្នេះសហគមន៍គួរតែយកចិត្តទុកដាក់ចំពោះរឿងនេះដើម្បីកុំឲ្យមានការខកចិត្តម្តងទៀត ។

**រេជ. សុទ្ធម៉ិន បាស៊ី**

# ការព្យាយាមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងការព្រួយបារម្ភ របស់ជនរងគ្រោះនៅមុនពេលមានសវនាការនៅអង្គជំនុំជម្រះ

សវនាការនៅអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នកាលពីថ្ងៃទី៣០ ដល់ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨ ធ្វើឲ្យមានយុត្តិវិធីគួរឲ្យព្រួយបារម្ភពីរចំពោះការចូលរួមដោយផ្ទាល់របស់ជនរងគ្រោះនៅក្នុងដំណើរការនីតិវិធីមុនពេលសវនាការអង្គជំនុំជម្រះ ។ នៅថ្ងៃទី១ ខែកក្កដា ចៅក្រមនៃសវនាការនៅអង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចមួយថា ដើមបណ្តឹងរដ្ឋប្បវេណីដែលតំណាងដោយមេធាវីមិនមានសិទ្ធិនិយាយដោយខ្លួនឯងនៅអំឡុងពេលបណ្តឹងឧទ្ធរណ៍នៅអង្គបុរេជំនុំជម្រះទេ គឺមានតែអ្នកតំណាងច្បាប់របស់គេប៉ុណ្ណោះដែលមានសិទ្ធិនិយាយ ។ ប៉ុន្តែ នៅថ្ងៃទី២ ខែកក្កដា ចៅក្រមដដែលបានបំបិទសិទ្ធិរបស់ជនរងគ្រោះមិនឲ្យចូលរួមដោយផ្ទាល់ ដោយថាភាគីដែលមិនមានអ្នកតំណាងមិនអាចធ្វើសារណាផ្ទាល់មាត់នៅអំឡុងពេលបណ្តឹងឧទ្ធរណ៍នៅអង្គបុរេជំនុំជម្រះបានទេ ។ ចំពោះមេធាវីការពារសិទ្ធិរបស់ជនរងគ្រោះ សេចក្តីសម្រេចនៅសប្តាហ៍នេះបានធ្វើឲ្យមានការភ្ញាក់ផ្អើលជាខ្លាំង ។

សេចក្តីសម្រេចនេះមានលក្ខណៈផ្ទុយពីសេចក្តីសម្រេចរបស់តុលាការពីមុននិងវិធាននៃដំណើរការនីតិវិធី ។ ក្នុងសវនាការនៅអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ នួន ជា ដើមបណ្តឹងរដ្ឋប្បវេណីដែលតំណាងដោយមេធាវីត្រូវបានអនុញ្ញាតឲ្យនិយាយនៅអំឡុងពេលដំណើរការនីតិវិធី ។ ជាងនេះទៅទៀត យោងទៅតាមគោលការណ៍សីលធម៌ទូទៅឃើញថា វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះមិនតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានមេធាវីតំណាងទេ ហើយវិធានផ្ទៃក្នុងនេះបានបង្កើតសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួម ដោយអាចមានឬមិនមានជំនួយពីមេធាវី អាស្រ័យហេតុនេះទើបដើមបណ្តឹងរដ្ឋប្បវេណីព្យាយាមនិយាយទៅកាន់អង្គចៅក្រម ។ តាមវិធាន ២៣(៧) ចែងថា «រាល់ជនរងគ្រោះដែលចូលរួមក្នុងដំណើរការនីតិវិធីមុនពេលសវនាការនៅអង្គជំនុំជម្រះ អាចតំណាងដោយមេធាវីជាតិឬមេធាវីបរទេស ដើម្បីធ្វើសហប្រតិបត្តិការជាមួយមេធាវីជាតិ...» ។

រហូតមកដល់សប្តាហ៍នេះ សវនាការនៅអង្គបុរេជំនុំជម្រះនៅតែគាំទ្រការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការនីតិវិធី ។ នៅក្នុងសេចក្តីសម្រេចកាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ អង្គចៅក្រមបានអនុម័តការបកស្រាយយ៉ាងទូលំទូលាយទៅលើសិទ្ធិចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដោយអះអាងថា នៅក្នុងវិធានផ្ទៃក្នុង «បានចែងយ៉ាងច្បាស់លាស់ថាដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមនៅក្នុងរាល់ដំណើរការនីតិវិធីព្រហ្មទណ្ឌ...» ហើយ «ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងដំណើរការនីតិវិធីចាប់ពីដំណាក់កាលស៊ើបអង្កេត» (កថាខណ្ឌ៣៦) ។ ក្នុងការប្រកាន់ខ្ជាប់ថាដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមបានបដិសេធនឹងការអះអាងរបស់សហមេធាវីថា ដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមតែនៅក្នុងដំណើរការនីតិវិធីដែលតម្រូវឲ្យចូលរួម មិនមែននៅក្នុងបណ្តឹងឧទ្ធរណ៍នៅអង្គបុរេជំនុំជម្រះទេ ។

អ្នកគាំទ្រសិទ្ធិរបស់ជនរងគ្រោះបានស្វាគមន៍សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនិងបង្ហាញពីទស្សនៈសុទិដ្ឋិនិយមថានឹងមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីនៅថ្ងៃអនាគត ។ ជាឧទាហរណ៍ សម្ព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្សបានចាត់ទុកសេចក្តីសម្រេចនេះថាជា «សេចក្តីសម្រេចគួរឲ្យកត់សម្គាល់នៅក្នុងច្បាប់យុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិនិងជាសមិទ្ធផលសំខាន់សម្រាប់ជនរងគ្រោះដែលធ្លាប់ទទួលរងការរំលោភបំពាន

ទៅលើសិទ្ធិមនុស្ស ដែលការសម្រេចនេះមិនដែលពុជាយូរមកហើយ» ។ ជាពិសេសមានការបង្កើតអង្គភាពជនរងគ្រោះនិងការដឹកនាំដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក (រួមបញ្ចូលទាំងមជ្ឈមណ្ឌលឯកសារកម្ពុជា) ដើម្បីប្រមូលពាក្យបណ្តឹងនិងបែបបទពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីពីអ្នកនៅរស់ ។ ដូច្នេះ សេចក្តីសម្រេចរបស់សវនាការកាលពីថ្ងៃទី១និងទី២ បានដាក់កំហិតចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានលក្ខណៈត្រឹមត្រូវជាជាងការមិនបានរំពឹងទុក ។

យើងឃើញថា ការប្រែប្រួលដ៏ធំធេងនៃឥរិយាបថរបស់អង្គចៅក្រមចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដោយសារ ក) ការព្យាយាមជាច្រើនលើកច្រើនសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីសម្អាងពីការប្រើប្រាស់សិទ្ធិចូលរួមដែលមាននៅក្នុងវិធានផ្ទៃក្នុង ។ ខ) ការគ្រប់គ្រងដ៏ទន់ខ្សោយរបស់អង្គជំនុំជម្រះចំពោះសារណាផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ការព្យាយាមជាច្រើនលើកច្រើនសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីសម្អាងអំពីសិទ្ធិចូលរួមដែលមាននៅក្នុងវិធានផ្ទៃក្នុងនៅពេលសវនាការនៅអង្គបុរេជំនុំជម្រះ ហាក់ដូចជាធ្វើឲ្យចៅក្រមមានការធុញទ្រាន់ចំពោះដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យនិយាយនៅពេលសវនាការប្រឆាំងនឹងដីកាឃុំខ្លួនរបស់ នួន ជា ។ នៅពេលនោះ សេង ធារី បានប្រើឱកាសនោះនិយាយពីបញ្ហាផ្សេងៗនិងផ្សព្វផ្សាយពីសៀវភៅដែលអង្គការរបស់នាងបានបោះពុម្ពជាជាងនិយាយពីបញ្ហាដែលទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន ។ ដូច្នេះ នៅពេលធ្វើសេចក្តីសម្រេច សវនាការនៅអង្គបុរេជំនុំជម្រះបានចាត់ទុកសារណារបស់នាងថាជា «សេចក្តីបន្ថែមទៅលើរបាយការណ៍របស់ជនរងគ្រោះ» ហើយចៅក្រមមិនបានយកសារណារបស់នាងមកពិចារណានៅក្នុងបណ្តឹងឧទ្ធរណ៍ទេ ។

សវនាការនៅអង្គបុរេជំនុំជម្រះនៅថ្ងៃទី៣០ ខែមិថុនា នៅក្នុងសប្តាហ៍នេះ ដើមបណ្តឹងរដ្ឋប្បវេណីដែលតំណាងដោយមេធាវីស្នើសុំនិយាយម្តងទៀត ។ ដោយមិនរង់ចាំស្តាប់ថាតើការស្នើរបស់នាងត្រូវបានអនុញ្ញាតឬក៏អត់ សេង ធារី បន្តនិយាយទៅកាន់អង្គចៅក្រម ។ ដោយមិនពេញចិត្តនឹងនាងដែលមិនបានរង់ចាំការសម្រេច ចៅក្រមក៏បានបញ្ឈប់ការនិយាយរបស់នាង ហើយបដិសេធមិនឲ្យនិយាយរហូតទាល់តែអង្គចៅក្រមធ្វើសេចក្តីសម្រេច ។ នៅថ្ងៃទី១ ខែកក្កដា ដោយសារអង្គចៅក្រមបានបដិសេធនឹងការស្នើសុំនិយាយដោយផ្ទាល់របស់ សេង ធារី ដូច្នេះ នាងក៏ប្រានបោលមេធាវីរបស់នាង ហើយស្នើថា នាងមានសិទ្ធិនិយាយដោយសម្អាងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយមិនមានអ្នកតំណាង ។ ចៅក្រមនៅតែបដិសេធនឹងការស្នើសុំរបស់នាង ហើយហាក់ដូចជាមានភាពក្តៅក្រហាយនឹងការស្នើសុំម្តងហើយម្តងទៀតរបស់នាង ។

ជាចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណីបានចាកចេញពីបន្ទប់សវនាការ ហើយប្តេជ្ញាថានឹងត្រឡប់មកម្តងទៀតដរាបណា «នាងមានសំឡេង» ។

ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនូវចំណុចសំខាន់មួយដោយសម្អាងលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមដោយផ្ទាល់ ។ វិធាន២៣(៧) បានអនុម័តគោលការណ៍ទូទៅថាដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមដោយមិនមានអ្នកតំណាងច្បាប់ ។ ចំពោះការបដិសេធនឹងការស្នើរបស់ សេង ធារី អង្គចៅក្រមបានសម្អាងទៅលើវិធាន៧៧(១០) ដែលសរសេរថា នៅក្នុងបណ្តឹងឧទ្ធរណ៍អង្គបុរេជំនុំជម្រះ «សហព្រះរាជអាជ្ញានិងមេធាវីតម្រូវឲ្យធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេប» ។ បទបញ្ញត្តិនេះមានលក្ខណៈផ្ទុយពីគោលការណ៍ទូទៅក្នុងវិធាន២៣(៧) ភាពផ្ទុយគ្នានេះបង្ហាញពីការបរាជ័យរបស់អ្នកព្រាងច្បាប់ដែលមិនបានរំពឹងទុកដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានអ្នកតំណាង ។ ដូច្នេះ ការបដិសេធសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានអ្នកតំណាងមិនឲ្យនិយាយផ្ទាល់ មិនយោងទៅតាមវិធានច្បាប់ទេ ។

ចំពោះសិទ្ធិរបស់ជនរងគ្រោះ អង្គចៅក្រមហាក់ដូចជាមិនបានផ្អែកលើសេចក្តីសម្រេចទៅនឹងវិធានច្បាប់ត្រឹមត្រូវទេ ផ្ទុយទៅវិញគឺផ្អែកទៅលើការមិនពេញចិត្តនឹងដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គល ។ គំនិតខុសគ្នារបស់ចៅក្រម រ៉ូវ៉ាន់ ដូនីង ផ្ទុយពី

ចៅក្រមអន្តរជាតិ កាទីនកា ឡាហ៊ីស ដែលថាវានឹង «មិនមានយុត្តិធម៌» បើមិនអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីគ្មានអ្នកតំណាងនិយាយ ។ នេះអាចនាំទៅរក «ការបំបិទសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនឲ្យធ្វើការអះអាងដែលមាននៅក្នុងវិធាន២៣(១)(ខ)» ។ កាលដែលដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឲ្យនិយាយនៅសវនាការអង្គបុរេជំនុំជម្រះ អាចធ្វើឲ្យមានយុត្តិវិធីគួរឲ្យព្រួយបារម្ភសម្រាប់ការគ្រប់គ្រងដំណើរការនីតិវិធីទៅថ្ងៃអនាគត ។

ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីព្យាយាមទាមទារសិទ្ធិឲ្យជនរងគ្រោះក៏ដោយ ប៉ុន្តែគេបានធ្វើឲ្យមានផលអាក្រក់ខ្លាំងទៅដល់ជនរងគ្រោះ ដោយទាមទារចូលរួមនៅក្នុងដំណើរការនីតិវិធីមុនពេលពេក ។ ថ្វីបើក្នុងនាមជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិដំបូងគេដែលអនុញ្ញាតឲ្យជនរងគ្រោះអាចចូលរួមដោយពេញសិទ្ធិក៏ដោយ ក៏រហូតមកដល់ពេលនេះអង្គចៅក្រមនៅតែអនុម័តយុត្តិសាស្ត្រជាបន្តបន្ទាប់ ។ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីព្យាយាមទាមទារការចូលរួម ចៅក្រមបែរជាឆ្លើយតបដោយអវិជ្ជមានទៅនឹងយុត្តិសាស្ត្រ ដោយប្រើកម្លាំងបាយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនិងដាក់កំហិតចំពោះការចូលរួមដោយផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ។ ដើមបណ្តឹងរដ្ឋប្បវេណីគួរតែចៀសវាងកុំធ្វើឲ្យសេចក្តីសម្រេចដែលទាក់ទងនឹងការបន្សាក់របស់ចៅក្រមកាន់តែអាក្រក់ឡើង ការបន្សាក់នេះបណ្តាលមកពីនីតិវិធីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

ការខឹងសម្បាររបស់អង្គចៅក្រមចំពោះនីតិវិធីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រឹមតែអាចសន្មតឲ្យឃើញពីឥរិយាបថរបស់បុគ្គលទេ តែថែមទាំងបង្ហាញឲ្យឃើញពីការគ្រប់គ្រងដំណើរការនីតិវិធីដ៏ទន់ខ្សោយរបស់អង្គចៅក្រមផង ។ នៅចំពោះមុខសវនាការ ចៅក្រមហាក់ដូចជាមិនដឹងពីនីតិវិធីសមស្របសម្រាប់ដឹកនាំដំណើរការនីតិវិធីទេ (ភាពមិនច្បាស់របស់ចៅក្រមក្នុងការដឹកនាំថាភាគីណាគួរតែធ្វើសារណានៅពេលណា) ។ ទោះបីជាមានមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៦រូបក៏ដោយ អង្គចៅក្រមទំនងជាមិនមានបំណងអនុញ្ញាតឲ្យមេធាវីទាំងនេះនិយាយទេ រហូតទាល់តែសហមេធាវីអន្តរជាតិ មីសេល ខាណាវ៉ាស ចោទសួរពីប្រសិទ្ធភាពនៃពហុសារណាដើម្បីជាជំនួយដល់សហព្រះរាជអាជ្ញាធ្វើឲ្យមានភាពស្មើគ្នា ។

នីតិវិធីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅតែមានភាពច្របូកច្របល់ ប្រសិនបើអង្គចៅក្រមមិនផ្តួចផ្តើមគំនិតអភិវឌ្ឍន៍ ។ ដូចដែលបានបង្ហាញនៅក្នុងសារណារួមរបស់សហមេធាវី នៅថ្ងៃទី២៧ ខែកុម្ភៈ ភាពសមស្របនៃដំណើរការនីតិវិធីនឹងត្រូវបានសម្របសម្រួលប្រសិនបើចំនួនដើមបណ្តឹងរដ្ឋប្បវេណីកើនឡើង ។ នៅក្នុងសេចក្តីសម្រេចកាលពីថ្ងៃទី២០ ខែមីនា សវនាការនៅអង្គបុរេជំនុំជម្រះបដិសេធមិនផ្តល់សេចក្តីណែនាំក្នុងករណីដូចជា «មិនអាចប្រមើលមើលពីការពិតដែលអាចនឹងត្រូវបានបង្ហាញនៅថ្ងៃអនាគត...» (កថាខណ្ឌទី៤៨) ។ ខណៈពេលដែលចំនួនដើមបណ្តឹងរដ្ឋប្បវេណីកើនឡើង ហើយមេធាវីបន្ថែមត្រូវបានរំពឹងថានឹងចូលរួមក្នុងដំណើរការនីតិវិធី គណៈកម្មាធិការនីតិវិធីនិងវិធានច្បាប់គួរតែអនុម័តសេចក្តីណែនាំអនុវត្តដែលណែនាំពីនីតិវិធីសម្រាប់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

ជាសរុប យើងអាចនិយាយបានថា សវនាការនៅអង្គបុរេជំនុំជម្រះបានបង្កើតជាយុត្តិវិធីដ៏គួរឲ្យព្រួយបារម្ភសម្រាប់ការចូលរួមដោយផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធី ។ ចំពោះការដាក់កំហិតនៅក្នុងបណ្តឹងឧទ្ធរណ៍អង្គបុរេជំនុំជម្រះ សេចក្តីសម្រេចនៅថ្ងៃទី១ និងថ្ងៃទី២ ខែកក្កដា បានដាក់កំហិតយ៉ាងខ្លាំងទៅលើសិទ្ធិចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ផលវិបាកនៃសេចក្តីសម្រេចទាំងនេះមិនត្រឹមតែប៉ះពាល់ទៅដល់ដំណើរការនីតិវិធីមុនពេលមានសវនាការជំនុំជម្រះទេ ថែមទាំងអាចប៉ះពាល់ដល់គំរូដែលអនុម័តសម្រាប់ការចូលរួមរបស់ជនរងគ្រោះនៅក្នុងតុលាការអន្តរជាតិទៅថ្ងៃអនាគតផង ។ ខណៈពេលដែលនីតិវិធីរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្ថិតនៅក្នុងដំណាក់កាលដំបូង ភាគីទាំងអស់និងសវនាការគួរតែធ្វើការពិចារណាទៅលើផលប៉ះពាល់នៃសេចក្តីសម្រេចរបស់ខ្លួន ដើម្បីធានាឲ្យមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីច្រើនបំផុតនិងធានាឲ្យមានភាពសមស្របក្នុងដំណើរការនីតិវិធី ។ **សារ៉ា ថូម៉ាស**

# ខាលពិឃាតនៅព្រៃខ្មោច

គោលបំណងខ្ញុំសរសេរអត្ថបទនេះគឺដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធជនរងគ្រោះចំនួន១២២៨នាក់ ដែលត្រូវខ្មែរក្រហមសម្លាប់នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៥ នៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង និងចង់បញ្ជាក់ប្រាប់បងប្អូនដែលបានបាត់បង់សាច់ញាតិតាមភិនភាគនេះ ពីព្រោះអ្នកនោះបានរួមដំណើរជាមួយខ្ញុំបាទ ហើយត្រូវពួកខ្មែរក្រហមយកទៅសម្លាប់យ៉ាងព្រៃផ្សៃបំផុត ។

ខ្ញុំសូមអំពាវនាវដល់មតិជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលក្នុងប្រទេសនិងក្រៅប្រទេស ព្រមទាំងអ្នកដែលមានបងប្អូនសាច់ញាតិបានស្លាប់នៅក្នុងរបបនោះឲ្យជួយសហការនិងស្រាវជ្រាវរកទីកន្លែងដែលខ្មែរក្រហមបានសម្លាប់និងគាស់យកអដ្ឋិធាតុយកទៅធ្វើបុណ្យតាមប្រពៃណី ។

ប្រសិនបើបងប្អូនមានការសង្ស័យនិងបានបាត់បង់បងប្អូននៅឆ្នាំ១៩៧៥ ដែលរស់នៅឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង អាចទំនាក់ទំនងមកខ្ញុំបាទ នៅភូមិស្រែតាដៃ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។

## ១) ព្រឹត្តិការណ៍ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥

ចាប់ផ្តើមពីម៉ោងមួយរំលងអធ្រាត្រ ខ្ញុំឮសូរសំឡេងផ្ទុះអាវុធរវាងទាហានលន់ នល់និងកងទ័ពខ្មែរក្រហម ។ លុះព្រឹកឡើងការចាក់ផ្សាយតាមវិទ្យុជាតិរបស់របបកម្ពុជាប្រជាធិបតេយ្យត្រូវបានជំនួសការចាក់ផ្សាយរបស់វិទ្យុរបបសាធារណរដ្ឋ ។ ខ្មែរក្រហមបានប្រកាសឲ្យទម្លាក់អាវុធ ហើយឯកឧត្តម ឡុង បូរ៉េត ត្រូវបានចាប់ខ្លួន ។ ពេលនោះ ប្រជាជនទូទាំងខេត្តមានការត្រេកអរជាខ្លាំង ។

លុះដល់ថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមរាប់ពាន់នាក់មកពីគ្រប់បណ្តាកងឯកភាពនិងគ្រប់មុខព្រួញក្នុងឯកសណ្ឋានពណ៌ខ្មៅ ពាក់មួក ឬ ជួតក្រមា និងកាន់អាវុធគ្រប់ដៃធ្វើដំណើរដោយថ្មើរជើងចូលមកសាលាខេត្ត ហើយខ្ញុំក៏មានវត្តមាននៅទីនោះដែរ ។ មេដឹកនាំខ្មែរក្រហមបាននិយាយថា ខ្ញុំសប្បាយចិត្តណាស់ដែលខ្ញុំបានមកឈរនៅទីនេះ និងបានជួបជាមួយបងប្អូនពុកម៉ែ ។ ប្រទេសយើងចប់សង្គ្រាមហើយ យើងរួបរួមគ្នាចាប់ផ្តើមកសាងប្រទេសជាតិឡើងវិញដើម្បីឲ្យរួចផុតពីការជិះជាន់របស់ចក្រពត្តិអាមេរិកដែលបង្កវិនាសកម្មមកលើប្រទេសយើង ។ ចុងបញ្ចប់ មេខ្មែរក្រហមរូបនោះបាននិយាយថា មន្ត្រីរាជការទាំងអស់ត្រូវទៅរៀនសូត្រនៅថ្នាក់លើមួយរយៈ ពិសេសបញ្ជាឲ្យទាហានលន់ នល់ទៅចុះបញ្ជីរាយនាមពីថ្នាក់លើដល់ថ្នាក់ក្រោម ព្រមទាំងដកអាវុធទាំងអស់ទុកក្នុងបន្ទាយនិងប្រមូលផ្តុំទាហានចូលបន្ទាយដើម្បីត្រៀមខ្លួនទៅរៀនសូត្រ ។ ការប្រជុំបានរំសាយនៅសល់តែមេបញ្ជាការខ្មែរក្រហមនិងមន្ត្រីលន់ នល់ ប៉ុណ្ណោះដែលនៅបន្តការពិភាក្សាគ្នា ។

កងទ័ពខ្មែរក្រហមរាប់ពាន់នាក់ដែលដើរជាជួរត្រូវបានរំសាយ ។ ពេលនោះ ភាពច្របូកច្របល់កើតមានពេញសាលាខេត្ត ខ្លះសើចសប្បាយ ខ្លះយំ ។ ដោយឡែក កូនទាហានលន់ នល់វិញនៅជាក្រុមៗដោយមានទឹកមុខស្រងូតស្រងាត់ ខ្លះដេកអស់សង្ឃឹម ។

ល្ងាចថ្ងៃនោះ ខ្ញុំឃើញទាហានខ្មែរក្រហមបីនាក់មកលេងផ្ទះរបស់ខ្ញុំ ។ បន្ទាប់មក ខ្ញុំឃើញបុរសម្នាក់បានរាយការណ៍ប្រាប់មេខ្មែរក្រហមពីរនាក់ថា ថ្នាក់លើមានការគោរពនិងកោតសរសើរឪពុកខ្ញុំ ព្រោះនេះជាផ្ទះបងប្អូនគាត់ នេះជាកម្លាំងផ្ទៃក្នុងរបស់យើងទទួលបន្ទុកផ្នែកភ័ស្តុភារ ជាអ្នកលួចបញ្ជូនក្រណាត់ខ្មៅក្រមានិងគ្រាប់កាំភ្លើងមួយចំនួនធំឲ្យកងទ័ពរំដោះ ។ ដូច្នេះ ចាំយើងគាត់រាយការណ៍ជូនថ្នាក់លើផ្តល់កិត្តិយស និងបុណ្យស័ក្តិ រួចហើយទទួលបាយទឹកមួយពេល ។

## ២) ព្រឹត្តិការណ៍គួរឲ្យរន្ធត់

នៅយប់ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ វេលាម៉ោង៩ៈ៣០នាទីយប់ ពេលឪពុកម្តាយខ្ញុំអង្គុយនិយាយលេងជាមួយមិត្តភក្តិ ចំណែកខ្ញុំរត់ពួនលេងជាមួយក្មេងៗនៅមុខផ្ទះ ស្រាប់តែឃើញ

ទាហានអាវខ្មៅជិះកង់មានកូនមីក្រូមួយ ស្រែកឃោសនាដោយពាក្យដដែលៗថា បងប្អូនរួមជាតិជាទីស្នេហា ប្រទេសជាតិយើងបានរំដោះ យើងរស់នៅយ៉ាងវេទនាដោយសារពួកចក្រពត្តិអាមេរិក ឥឡូវនេះវាមិនឲ្យយើងបានសុខទេ អង្គការថ្នាក់លើបានឲ្យដំណឹងថា នៅពេលបន្តិចទៀតនេះ ឬថ្ងៃស្អែកពួកវានឹងទម្លាក់គ្រាប់បែកតាមទីប្រជុំជនធំៗ ទូទាំងប្រទេសដើម្បីសងសឹកយើងវិញហើយ ។ ដូច្នេះ សូមបងប្អូនរៀបចំភៀសខ្លួនចេញទៅនៅក្នុងព្រៃមួយរយៈក្រោមការគ្រប់គ្រងដោយអង្គការយើង បើពុំដូច្នោះទេ អ្នកនឹងត្រូវស្លាប់ដោយសារគ្រាប់បែករបស់ចក្រពត្តិអាមេរិក ។ ប្រហែលជាពីរម៉ោងក្រោយមក ខ្មែរក្រហមបានបាញ់កាំភ្លើងតូចធំនៅកណ្ដាលទីរួមខេត្តដើម្បីបំបាក់ស្មារតីប្រជាជនឲ្យឆាប់ចាកចេញ ។ ឪពុកម្ដាយខ្ញុំក៏បានរៀបចំអំបិល ប្រហុក អង្ករ និងសម្លៀកបំពាក់បន្តិចបន្តួចដាក់ក្នុងរថយន្តតាក់ស៊ីមួយចេញដំណើរពីមុខផ្ទះមកដល់ផ្លូវធំ ។ ប្រកផ្លូវដែលត្រូវធ្វើដំណើរមានបីគឺ ផ្លូវជាតិលេខ៥ឆ្ពោះទៅព្រៃខ្មែរ ទីពីរផ្លូវជាតិលេខ៥ ឆ្ពោះទៅពគ្រ និងទីបីផ្លូវជាតិលេខ៥៣ មកលើស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។ ឪពុកខ្ញុំធ្វើដំណើរឆ្ពោះទៅតាមផ្លូវទី៣ ។

ម៉ោង៦ព្រឹក ថ្ងៃទី២២ ខែមេសា ពេលធ្វើដំណើរបាន៦គីឡូម៉ែត្រ គ្រួសារខ្ញុំស្រាប់តែបានឃើញព្រះសង្ឃជាច្រើនអង្គនិមន្តដើរចម្ងាយ២០គីឡូម៉ែត្រមកភូមិក្រាំងតាមុំ ។ ឪពុកខ្ញុំទិញបានប្រេងម៉ាស៊ូតចំនួន៣០លីត្រពីរោងម៉ាស៊ីនកិនស្រូវ រួចបន្តដំណើរទៅមុខទៀត រហូតដល់ម៉ោង៦ល្ងាចទើបបានសម្រាកនៅទីរួមស្រុកទឹកផុសមួយយប់ ។ នៅទីនោះ ផ្ទះជាច្រើនខ្ទង់ត្រូវឆេះខ្ទេចខ្ទីរលាយទៅជាផេះផង់ ដោយសារការទម្លាក់គ្រាប់បែករបស់ចក្រពត្តិអាមេរិកកាលពីចុងឆ្នាំ១៩៧២ ។

ព្រឹកឡើងថ្ងៃទី២៣ ខែមេសា ខ្មែរក្រហមពីរនាក់បានប្រមូលកម្លាំងដែលទើបមកដល់ឲ្យដើរស្រង់យកឈ្មោះមន្ត្រីរាជការនិងប្រជាជនរស់នៅទីរួមខេត្តកំពង់ឆ្នាំងឲ្យទៅរស់នៅម្ដុំភូមិក្បាលឡានចម្ងាយ៣គីឡូម៉ែត្រពីទីរួមស្រុក ។ ខ្មែរក្រហមប្រកាសថា យើងឈប់ចាយលុយ ហើយការដោះដូរធ្វើឡើងដោយអង្ករនិងមាស ។ ស្នាក់នៅទីនោះបានតែរយៈពេល៥ថ្ងៃ គឺថ្ងៃទី២៨ ខែមេសា ខ្មែរក្រហមបានប្រមូលកម្លាំងឲ្យដើរទៅមុខដែលមានចម្ងាយប្រហែលជា២០គីឡូម៉ែត្រ ។

## ៣) សោកនាដកម្មមិនអាចបំភ្លេចបាន

នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៥ នៅពេលខ្ញុំចេញដំណើរទៅក្នុងព្រៃចម្ងាយប្រហែល៣គីឡូម៉ែត្រពីកន្លែងស្នាក់នៅដើម្បីបេះបន្លែផ្លែឈើ ខ្ញុំស្រាប់តែឃើញទាហានលន់ នល់រាប់ពាន់នាក់ដែលគេប្រមូលមកពីគ្រប់ទីកន្លែង ខ្លះពាក់មួកដែកនៅខ្លួនមានស្ពាយសាក់កាដូ តែពុំមានកាន់កាំភ្លើងទេ ខ្លះមានរួមដំណើរជាមួយប្រពន្ធនិងកូនផង ។

ពេលខ្ញុំពួនសម្ងំនៅក្នុងគុម្ពោតព្រៃចម្ងាយប្រហែល២០ម៉ែត្រ ខ្ញុំឃើញទាហានប្រហែលជា១០០នាក់ដើរជាពីរជួរ ក្នុងនោះអ្នកដើរការពារចំនួន១០នាក់ប្រដាប់ដោយអាវុធគ្រប់ដៃធ្វើដំណើរឆ្ពោះទៅភ្នំឱរ៉ាល់ ។

ដោយទាហានច្រើនពេករង់ចាំមើលមិនអស់ ខ្ញុំក៏ត្រឡប់មកកន្លែងវិញ ។ ពេលមកដល់ភ្លាម ម្ដាយខ្ញុំសួរថា ឯងទៅណាអីក៏យូរម្ល៉េះ? ព្រឹកមិញខ្មែរក្រហមពីរនាក់មកប្រាប់ឲ្យប្រុសៗទៅចូលរួមប្រជុំ ព្រោះឮថា ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ ចុះមកប្រជុំផ្ទាល់ ហើយប្រហែលជាអង្គការអនុញ្ញាតឲ្យគ្រួសារនីមួយៗត្រឡប់ទៅផ្ទះវិញ ។ ដំណឹងនេះធ្វើឲ្យម្នាក់ៗត្រេកអរ នាំគ្នាដាំបាយនិងរៀបចំអីវ៉ាន់ដើម្បីរង់ចាំការប្រជុំនេះតាំងពីម៉ោង១០ព្រឹក រហូតដល់ម៉ោង៣រសៀល ។ ដោយរង់ចាំបាត់យូរទៅ ស្រាប់តែឃើញទាហានអាវខ្មៅ២នាក់មកដល់ ហើយស្រែកប្រាប់ថា ស្នើទៅប្រជុំទាំងអស់គ្នា ទាំងក្មេងទាំងចាស់ ទុកតែប្រពន្ធ សូ លន (ម្ដាយខ្ញុំ) និង៤គ្រួសារទៀតដែលខ្ញុំមិនចាំឈ្មោះនៅយាមសម្ភារៈ ។ ពេលនោះ ខ្ញុំក៏ចេះតែធ្វើដំណើរទៅតាមមនុស្សពីរនាក់នាំទៅ (លាក់ឈ្មោះ) ដោយឆ្លងទំនប់អូកេលចូលទៅក្នុងព្រៃមួយសន្ទុះធំ រួចក៏បានជួបទាហានអាវខ្មៅ២៥នាក់គ្មានកាន់កាំភ្លើង ។ ខ្ញុំបានសុំទាហានអាវខ្មៅរើសផ្លែធ្លកទុំហូប ។ ខ្ញុំហៅទាហាននោះថា លោកៗ ប៉ុន្តែទាហាននោះឆ្លើយមកវិញថា ឥឡូវនេះមិនឲ្យហៅលោកទេ គឺហៅថា សមមិត្ត ឬសមមិត្តបង ។

ខ្ញុំទៅដល់ទីនោះមុនគេ បន្ទាប់មក មានមនុស្សរាប់រយនាក់មកដល់ រួចនាំគ្នាអង្គុយចោងហោងជាជួរៗ ។ ខណៈនោះ ទាហានអាវខ្មៅនិយាយថា សមមិត្តចាំអីទៀត ល្មមដល់ពេលឲ្យប្រជាជន

អង្គុយមួយខណ្ឌ៥០នាក់ៗហើយ ។ ពេលនោះ ទាហានអាវខ្មៅ៤នាក់កាន់កាំភ្លើងអាកា៤៧ អមមុខពីរនាក់ ក្រោយពីរនាក់បណ្តើរពួកខ្ញុំយកទៅឲ្យទាហានអាវខ្មៅប្រហែល៣០នាក់ ដែលមានកាំភ្លើងអាកា៤៧និងបេ៤០គ្រប់ដៃ ។ ខ្ញុំនិងអ្នកទាំងអស់គ្នាភ័យតក់ស្លុតចំពោះវត្តមានទាហាននេះណាស់ ដោយយកកាំភ្លើងភ្ជង់តម្រង់មកពួកខ្ញុំ ។ ដោយខ្លែករូបខ្ញុំទើបអាយុ១៥ឆ្នាំ ហើយក្រិនតូចមិនត្រូវបានចងដៃទេ ។ ទាហានទាំងនោះនិយាយថា ពួកនាយទុនសក្តិភូមិ ខ្ញុំកញ្ជះដាច់ថ្លៃរបស់ចក្រពត្តិអាមេរិក ម៉េចចង់ជួបប្តីហ្អី? ទៅដើរឲ្យលឿន បន្តិចទៀតឃើញហើយ ។ ដើរបានចម្ងាយប្រហែល១០០ម៉ែត្រ យើងបានឃើញរណ្តៅសាកសពជាច្រើនដែលទើបជីកទុកមុនថ្មីៗ និងឃើញប្តីដែលមកពីព្រឹកត្រូវបានសម្លាប់អស់ហើយ ។ ពេលនោះ សំឡេងយំក៏ឮទ្រហឹងអឹងកងឡើង ខ្ញុំស្រឡាំងកាំងបាក់ស្មារតីមិនស្មានថាទាហានទាំងនោះយកមនុស្សមកសម្លាប់ដូចសត្វធាតុយ៉ាងដូច្នេះសោះ ។ កំពុងតែភ័យ ស្រាប់តែទាហានអាវខ្មៅ២នាក់រត់មកពីក្រោយ ហើយស្រែកពីចម្ងាយថា ឈប់សិនកុំអាលសម្លាប់មនុស្ស ។ ភ្លាមនោះទាហានទាំងអស់ស្រឡាំងកាំង អ្នកដែលកំពុងតែវាយមនុស្សក៏ផ្អាកសកម្មភាព ហើយសួរថាមានរឿងអី? អង្គការបិទមិនឲ្យសម្លាប់មនុស្សឬយ៉ាងម៉េច? ទាហាននោះឆ្លើយថា អង្គការអត់បិទទេ ការងារនៅតែអនុវត្តតាមការគ្រោងទុក តែប្រទ្បំមនុស្សម្នាក់ដែលអង្គការត្រូវទុក ។

តើគេជានរណា? ហើយពិតជាមកដល់ទីនេះមែនឬ? មិនដឹងទេ តែរកពីក្រោយមិនឃើញ ឥឡូវខ្ញុំប្រកាសរកសិន តើមានសមមិត្តណាជាកូនដែលឪពុកឈ្មោះ សូ លន ម្តាយឈ្មោះ ខៀវឡង់ មុខរបររត់ឡានតាក់ស៊ីទេ បើមានស្នើលើកដៃ ។ ពេលនោះខ្ញុំបានលើកដៃយ៉ាងឆាប់រហ័ស ។ ទាហាននោះបន្ទោសខ្ញុំថាគ្រួសារសមមិត្តត្រូវនៅចាំកន្លែង ហេតុអ្វីបានជាអ្នកមកទីនេះ? សំណាងហើយខ្ញុំមកទាន់ ។ បន្ទាប់មក ខ្មែរក្រហមសួរបន្តទៀតថាក្នុងចំណោមហ្នឹងតើអ្នកមានបងប្អូនដែរឬទេ? ខ្ញុំក្រឡេកមើលជុំវិញខ្លួន ឃើញមានបងប្អូនជីដូនមួយ ជីទួតមួយជាច្រើនបាញ់ភ្នែកសម្លឹងមករកខ្ញុំ ។ ប៉ុន្តែ ហាក់ដូចមានអ្វីមកបិទមាត់ខ្ញុំ ខ្ញុំក៏ឆ្លើយថា «គ្មាន» ។ ដើរបានប្រហែល១០០ម៉ែត្រ គេក៏ហៅខ្ញុំឲ្យដើរមកក្រោយ ហើយព្រមានថា ចំពោះព្រឹត្តិការណ៍ដែលអ្នកបានឃើញអម្បាញ់មិញត្រូវលាក់ការណ៍ឲ្យជិត ទោះបីជាម្តាយឬបងប្អូនក៏មិនត្រូវនិយាយប្រាប់ដែរ ត្រូវលាក់ទុកមួយជីវិត ។ រឿងឯងសឹងតែជួយមិនបានពីព្រោះឯងមកដល់កន្លែងអាថ៌កំបាំងលឿនពេក ។


សកម្មភាពរបស់អ្នកភូមិកំពុងអានទស្សនាវដ្តីស្វែងរកការពិត

ការបរបោររបស់ខ្ញុំជាមួយទាហានអាវខ្មៅស្មើរតែមិនព្រម ពីព្រោះខ្ញុំបានដឹងរឿងសម្ងាត់នេះ ។ ខ្ញុំក៏សន្យាថា ខ្ញុំមិននិយាយទេ ។ ពេលខ្ញុំត្រឡប់មកវិញ មានមនុស្សបីនាក់អមដំណើរខ្ញុំ ។

នៅពេលដែលត្រឡប់មកដល់ខ្ទមវិញ ម្តាយខ្ញុំត្រេកអរណាស់ ។ តែខ្ញុំស្រាប់តែភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយខ្ញុំឃើញមានរទេះគោរាប់រយគ្រឿងដឹកជយភណ្ឌនិងអីវ៉ាន់របស់អ្នកដែលត្រូវយកទៅសម្លាប់ត្រឡប់មកវិញ ។ បន្ទាប់មក ទាហានអាវខ្មៅប្រហែលជា២០នាក់ចាប់ផ្តើមប្រមូលមនុស្សដែលនៅសេសសល់ដូចជាអ្នកមានជំងឺ ចាស់ជរា ខ្វាក់ខ្វិន ស្ត្រីកូនខ្ចី ។ល ។ យកទៅសម្លាប់ក្រោយគេ ។

មួយសន្ទុះក្រោយមក ឪពុកខ្ញុំក៏បានមកដល់ដោយគាត់បានគេចផុតពីការសម្លាប់ដែរ ព្រោះបានប្រធានភូមិជួយអន្តរាគមន៍ដោះលែងជាមួយបុរស៤នាក់ទៀត ។

គ្រាន់តែមកដល់ភ្លាម ខ្មែរក្រហមបញ្ជូនយើងឲ្យទៅកន្លែងផ្សេង ដោយមានរទេះគោចំនួន៥គ្រឿងដឹកសម្ភារៈ មួយគ្រួសារមួយគ្រឿង ។

## គេចរួចពីស្លាប់នៅតែស្លាប់ដដែល

អ្នកគេចរួចពីស្លាប់ចំនួន៥គ្រួសារបានដឹកសម្ភារៈតាមទេះគោមកដល់ចុងភូមិអូរកេល អង្គការបានចែកផ្ទះមួយខ្នងសម្រាប់មួយគ្រួសារ ។ ផ្ទះនោះសង់អំពីឈើប្រក់ស្លឹកមានរយៈពេលប្រហែលជា៤ឬ៥ឆ្នាំ និងមានទំហំប្រហែល៤គុណនឹង៥ ម៉ែត្រ ។ ក្រៅពីផ្ទះទាំង៥នេះ មានខ្ទមតូចៗចំនួន១៥ទៀត ខ្លះប្រក់ស្បូវ ខ្លះប្រក់ស្លឹកខ្ទង់ ដែលជាខ្ទមប្រជាជនថ្មីទើបជម្លៀសពីលង្វែកប្រហែល២ខែមុនថ្ងៃ១៧ មេសា មានមនុស្សជាង១០០នាក់រស់នៅទីនោះ ។

ព្រឹកថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៥ វេលាម៉ោង៧ព្រឹក ទាហានខ្មែរក្រហម២នាក់បានចុះមកស្រង់ស្ថិតិគ្រួសារ ។ ពេលនោះស្រាប់តែឃើញថា ៥គ្រួសារដែលមានសមាជិកសរុប២៧នាក់នៅសល់តែចំនួន១៩នាក់ប៉ុណ្ណោះ ។ បន្ទាប់ពីសួរដេញដោលទើបដឹងថា មាន៣គ្រួសារមិនបាននៅជួបជុំគ្នាទេ គឺបាត់ប្តី ឪពុក កូន ប្រពន្ធ ទៅប្រជុំម្សិលមិញមិនឃើញត្រឡប់មកវិញ ។

ចំណែកពីរគ្រួសារទៀត គឺគ្រួសារខ្ញុំមានគ្នាចំនួន៥នាក់ និងមួយគ្រួសារទៀតមិនស្គាល់ឈ្មោះមានគ្នាចំនួន៨នាក់ ត្រូវខ្មែរក្រហមប្រកាសថាឲ្យរស់នៅទីនេះសិន ។

ព្រឹកថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៥ ប្រជាជនលង្វែកទាំង១៥គ្រួសារក៏ត្រូវយកទៅសម្លាប់តាំងពីព្រឹកព្រលឹម នៅសល់តែមួយគ្រួសារដែលមានសមាជិក៤នាក់ប៉ុណ្ណោះ ។ សរុបមានចំនួន៣គ្រួសារដែលនៅរស់ គឺគ្រួសារខ្ញុំ៥នាក់ គ្រួសារ ម៉ែអាចិត្ត៣នាក់និងគ្រួសារអ្នកលង្វែក៤នាក់ ។ ពេលនោះប្រធានភូមិប្រកាសថា ពីថ្ងៃនេះទៅបីគ្រួសារនេះស្ថិតនៅក្នុងក្រុមជាមួយគ្នា ហើយថ្ងៃស្អែកអង្គការនឹងបញ្ជូនប្រជាជនថ្មីចំនួនជាង១៥០នាក់ឲ្យមករស់នៅទីនេះដើម្បីបង្កបង្កើនផលធ្វើស្រែចម្ការ ។ ចំណែកឯឪពុកខ្ញុំខ្មែរក្រហមហៅឲ្យទៅបើករថយន្តប្រមាណជា៣០គ្រឿងដែលនៅរាយពាសពេញព្រៃ យកមកចតនៅទីស្នាក់ការឃុំ ។

ស្អែកឡើងប្រជាជនប្រមាណ១៥០នាក់ក៏បានមករស់នៅក្នុងក្រុមជាមួយពួកយើង ។ នៅក្នុងនោះ ភាគច្រើនជាគ្រូ បង្រៀន ពេទ្យ ប៉ូលិស និងមន្ត្រីរាជការក្នុងរបបសាធារណរដ្ឋខ្មែរ ។ បន្ទាប់មក យើងខ្ញុំក៏ចាប់ផ្តើមធ្វើការ ដូចជាលើកទំនប់ ជីកប្រឡាយ និងធ្វើស្រែ ។

លុះដល់ខែតុលា ឆ្នាំ១៩៧៥ ឪពុកខ្ញុំបានស្លាប់ដោយជំងឺគ្រុនចាញ់ ។ ម្តាយខ្ញុំមានជំងឺខ្សះជីវជាតិនិងជំងឺផ្លូវចិត្ត ។

ដើមឆ្នាំ១៩៧៦ ខ្ញុំត្រូវបញ្ជូនទៅធ្វើការនៅកងចល័តយុវជនស្រុក ស្នាក់នៅភ្នំអង្គមានគ្នាជិត៥០០នាក់ ដើម្បីគាស់គល់ លើកភ្លឺស្រែ និងជីកប្រឡាយ ។

ខ្ញុំមានការភិតភ័យព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់រហូតដល់ទៅបីដង ។ លើកទី១ ពេលខ្ញុំរត់ទៅផ្ទះ គេ (ខ្មែរក្រហម) យកកងទៅឱបមកវិញ លើកទី២នៅចុងឆ្នាំ១៩៧៦ នៅខែដកស្ទូង ម៉ោង៧យប់ពេលទៅមើលខ្សែភាពយន្ត មេកងបានដើរសួររកអ្នកដែលមានក្រមាថ្មីៗចំនួន៥០នាក់ ឲ្យតម្រង់ជួរ ហើយធ្វើដំណើរដោយមិនប្រាប់ថាទៅណាទេ ធ្វើឲ្យខ្ញុំភ័យនិងមានការប្រុងប្រយ័ត្ន ហើយឆ្ងល់ថាតើគេនាំយកទៅណា ។ ដើរមួយសន្ទុះមកដល់ថ្នល់ក៏មានមនុស្សស្លៀកពាក់ខោអាវខ្មៅរាប់ពាន់នាក់មកពីបណ្តាឃុំទាំងអស់ធ្វើដំណើរឆ្ពោះទៅវត្តសុវណ្ណនៅទីរួមស្រុក ។ ពេលនោះខ្ញុំឃើញមានបញ្ចាំងខ្សែភាពយន្តដោយរៀបចំតាមបណ្តាអង្គភាព

នីមួយៗ ជាជួរៗ ទស្សនារហូតដល់ម៉ោង៧រំលងអធ្រាត្រទើបវិលត្រឡប់ទៅវិញ ។

ខ្លឹមសារខ្សែភាពយន្ត រឿងទី១គឺទិដ្ឋភាពរត់បោលស្រុករបស់ទាហានលន់ នល់ ពណ៌ធម្មជាតិ ។ រឿងទី២ ការបង្កបង្កើនផល ការលើកទំនប់ ជីកប្រឡាយ ធ្វើស្រែនៅគ្រប់ភូមិភាគទាំងអស់ ។ រឿងទី៣ ទង់ក្រហមតាំងចាយ ។ អ្នកអត្ថាធិប្បាយខ្សែភាពយន្តនិយាយថា រឿងទង់ក្រហមតាំងចាយនេះគេហៅថាតាចាយៗ មិនមែនជាឈ្មោះមនុស្សទេ គឺជាឈ្មោះភ្នំមួយនៅប្រទេសចិន ដែលដឹកនាំដោយសមមិត្ត ឆឹង យ៉ុងគុយ ជាអគ្គមគ្គុទ្ទេសក៍ផ្ដើមដឹកនាំប្រជាជនតស៊ូតាំងពីបាតដៃទទេរហូតម្ចាស់ការលើភ្នំនេះបានទាំងស្រុង ។

បីខែក្រោយមក សមមិត្ត ឆឹង យ៉ុងគុយ ក៏បានមកទស្សនកិច្ចប្រទេសកម្ពុជា ។ ប្រជាពលរដ្ឋឈរអមទទួលពីទីរួមស្រុកទឹកផុសរហូតដល់ភូមិខ្លងពពក ចម្ងាយផ្លូវ៦គីឡូម៉ែត្រ ដោយជិះក្នុងរថយន្តខ្មៅមួយគ្រឿង ។ កាលណោះ អង្គភាពខ្ញុំដែលអ្នកធាត់ៗត្រូវទៅទទួល ចំណែកអ្នកស្គមៗត្រូវបានយកទៅលាក់ទុកក្នុង ព្រៃ ។

លើកទី៣ នៅថ្ងៃបុណ្យ១៧មេសា ឆ្នាំ១៩៧៧ ខ្ញុំដេកពេទ្យ ហើយសុំពេទ្យត្រឡប់មកអង្គភាពវិញ ។ ខ្ញុំបានលួចទៅលេងម្ដាយនៅផ្ទះ ប៉ុន្តែទៅដល់ គេប្រាប់ថា ម្ដាយខ្ញុំជាប់គុក ហើយត្រូវបានយកទៅសម្លាប់បាត់ហើយព្រោះគាត់ប្រឆាំងនឹងអង្គការ ។ មេកងសួរថា តើសមមិត្តដឹងទេថាម្ដាយសមមិត្តទៅណា? ខ្ញុំឆ្លើយថាត្រូវគេយកទៅសម្លាប់ហើយ ។ អ៊ីចឹងសមមិត្តមានខឹងនឹងបដិវត្តន៍ទេ?

ខ្ញុំឆ្លើយតបវិញថា មិនខឹងទេព្រោះសម័យបដិវត្តន៍គឺឪពុកផ្សេង កូនផ្សេង ខ្ញុំជាកូនអង្គការ អ្នកណាក្បត់នឹងអង្គការអ្នកនោះត្រូវតែស្លាប់ គេក៏លែងសួរខ្ញុំទៀត ។

## ព្រឹត្តិការណ៍ក្រោយថ្ងៃទី៧ មករា ១៩៧៩

ជារឿងដែលខ្ញុំបានឃើញផ្ទាល់ភ្នែក កងទ័ពបូព៌ាដែលមកពីខេត្តស្វាយរៀង ព្រៃវែង និងខេត្តកំពង់ចាម ត្រូវបានអង្គការដកសេចក្ដីទុកចិត្ត រួចបញ្ជូនមកធ្វើព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ដូចជាអ្នកទោស ដោយសារមានថ្នាក់ដឹកនាំនាយទាហាន ពលទាហានជាច្រើនរត់ចូលយួនធ្វើការតស៊ូប្រឆាំងនឹងខ្មែរក្រហមវិញ ។

ក្រោយពីទីក្រុងភ្នំពេញត្រូវបានរំដោះថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ ខ្មែរក្រហមបានយកទ័ពបូព៌ារាប់រយនាក់ទៅសម្លាប់ភ្លាមៗនៅខាងលិចទីរួមស្រុកទឹកផុស ។

ពេលនោះខ្ញុំជាកងចល័តចុះប្រូតតាមមូលដ្ឋានបានឮគេនិយាយថា ពួកក្បត់ទ័ពបូព៌ាត្រូវបានយកមកសម្លាប់ចោលទីនេះ ។ ស្អែកឡើងដូចគេនិយាយមែន នៅវេលាម៉ោង៩ព្រឹក ខ្ញុំឃើញរថយន្តកាមីញ៉ុងបីគ្រឿងដឹកទាហានបូព៌ាពេញមួយឡានមានគ្នា៨៥នាក់ យកទៅសម្លាប់នៅសល់តែ១៥នាក់ប៉ុណ្ណោះ ដោយមាននិរសារម្នាក់ តៃកុងឡានម្នាក់ ទាហានបំពាក់អាវុធកាន់អាកា៤៧ពីរនាក់ គឺជាកម្លាំងបង្កប់របស់ខ្មែរក្រហម ក្នុងមួយថ្ងៃជញ្ជូន២លើកស្មើនឹង៥០០នាក់ ហើយយកមកសម្លាប់ជាង១០ថ្ងៃ ។

ពេលព្រឹកព្រលឹមថ្ងៃមួយខ្ញុំកំពុងប្រូតស្រូវនៅជាប់ផ្លូវលំស្រាប់តែឃើញរថយន្តបីគ្រឿងដឹកទាហានបូព៌ាពេញបើកមកជិតពួកខ្ញុំដែលកំពុងប្រូតស្រូវ រួចស្រែកថា ប្អូនៗបងឲ្យមួកមួយ ចាំបងមកពីវាយយួន បងសុំមួកវិញ ។ ពេលបើកហួសចម្ងាយមួយគីឡូម៉ែត្រ រថយន្តចាប់ផ្ដើមស៊ីប្លេបន្តៗគ្នា បន្ទាប់មកឮសូរផ្ទុះអាវុធ ។ ប្រហែលជាមួយម៉ោងក្រោយមក រថយន្តបើកមកវិញមានដឹកមនុស្ស៥នាក់ប៉ុណ្ណោះ ។ នៅពេលល្ងាច ខ្ញុំឃើញរថយន្តមកដឹកមួយលើកទៀតដូចពេលព្រឹកដែរ ។ សកម្មភាពនេះមានជារៀងរាល់ថ្ងៃ ប្រហែលជា១៥ថ្ងៃ ។

នៅពេលកងទ័ពវៀតណាមធ្វើដំណើរកាន់តែខិតជិតដល់ការសម្លាប់នេះគឺលើកទៅកន្លែងផ្សេងទៀត ប៉ុន្តែខ្ញុំមិនបានឃើញនិងមិនបានដឹងថាមានប៉ុន្មាននាក់ទេ ។ ចំណែកនៅភូមិដែលខ្ញុំរស់នៅមានទាហានរាប់រយនាក់នៅការពារជុំវិញព្រៃនិងមានគ្រឿងចក្រមួយសម្រាប់ចូកដីជីករណ្ដៅ ។ របៀបសម្លាប់ គឺពេលរថយន្តបើកបានចម្ងាយមួយគីឡូម៉ែត្រ ចាប់ផ្ដើមស៊ីប្លេឲ្យអ្នករង់ចាំសម្លាប់ចូលតាមគោលដៅរៀងៗខ្លួន ដោយត្រៀមនៅមាត់ព្រៃនិងឈរអមសងខាងផ្លូវចម្ងាយប្រហែល៣០ម៉ែត្រ ។ ពេលរថយន្តបើកមកដល់ ត្រូវបើកជិតៗគ្នា ហើយចាប់ផ្ដើមផ្ទុះអាវុធឡើងលើ ។ អ្នកខ្លះមិនព្រមលើកដៃ វាបែរចុងកាណុងបាញ់ឲ្យរបួស រួចហើយភ្ជួន្ធ័ទ្ធជុំវិញបញ្ឆោឲ្យហក់ចុះដី រួចយកខ្សែចងជាប់មួយខ្សែ១២នាក់ ហើយយកក្រមារុំភ្នែក ។ រថយន្តបើកចេញចម្ងាយប្រហែល

១០០ម៉ែត្រ ប្រានទម្លាក់អីវ៉ាន់ចេញ រួចបើកទៅយកអ្នកថ្មីមកទៀត ឯអ្នកទោសត្រូវកងសន្តិសុខខ្មែរក្រហមនាំយកដាក់ក្នុងរណ្តៅម្តងមួយៗ ។ ពេលទម្លាក់មនុស្សពេញរណ្តៅ ម៉ាស៊ីនចូកដី កាយដីលុបៗ ហើយជីករណ្តៅកន្លែងថ្មីទៀត ។

ចំណែកខ្ញុំភិតភ័យណាស់នៅពេលឮស៊ីប៉េនិងស្នូរបាញ់ ដោយគិតថាស្លាប់ហើយ ព្រោះខ្ញុំរត់តាមពីក្រោយរថយន្តបែបនេះ ។ ប៉ុន្តែខ្ញុំសំណាងណាស់បានរួចជីវិត ព្រោះចំពេលគេទម្លាក់ជយភណ្ឌ ។ ចំណែកអ្នកផ្សេងត្រូវស្លាប់ដោយសារតែកម្លាំងទ័ពបូព៌ាមានការសង្ស័យបើករថយន្តមិនជាប់គ្នា ធ្វើឲ្យមានការតដៃហក់ចេញពីរថយន្ត បាញ់រះច្របូកច្របល់ស្លាប់ពេញវាលស្រែ អ្នកខ្លះមិនទាន់ស្លាប់ដើរបាញ់សម្លាប់ថែម ។ តាំងពីមានរឿងនោះកើតឡើងមក ខ្មែរក្រហមបានហាមមិនឲ្យពួកខ្ញុំនិងប្រជាជនចូលកន្លែងនោះទេ ។

ចំពោះសៀវភៅដែលខ្ញុំយកបាននោះ ភាគច្រើនជាបញ្ជីរាយនាមឈ្មោះទ័ពបូព៌ា វរសេនាតូច វរសេនាធំ អ្នកដែលមានដើមកំណើតនៅព្រៃវែង ស្វាយរៀង និងខេត្តកំពង់ចាម ។

បញ្ជីរាយនាមឈ្មោះមេក្បត់រត់ចូលយួនចំនួនបីនាក់ ប្រាំនាក់ ប្រាំពីរនាក់ និងទ្រង់ទ្រាយធំជាវរសេនាតូច វរសេនាធំ ភាគច្រើននៅចុងឆ្នាំ១៩៧៨ ។ និយាយរឿងខ្លះមុនគេយកទៅសម្លាប់អង្គការបានរៀបចំកម្មវិធីប្រជុំដែលមានកម្មវិធីជាបន្តបន្ទាប់ ៈ

១) ប្រកាសហេតុ
២) ខទ្ទេសនាម
៣) ការបំពេញភារកិច្ចកន្លងមក
៤) ផ្សេងៗនិងប្រកាសបិទកម្មវិធី

**ក្នុងនោះផ្នែកសំខាន់ៗមាន ៈ**

ហាមទាក់ទងជាមួយប្រជាជននៅក្នុងតំបន់នោះ និងហាមដើររើសក្តួរស្រូវតាមវាលស្រែនិងបាចត្រីក្នុងអូរ ។ ចំណុចពិសេសបំផុតនោះគឺត្រៀមបំពាក់អាវុធដើម្បីវាយយួននៅពេលខាងមុខ ។

កាលពីដើមខែធ្នូ ឆ្នាំ២០០៧ ខ្ញុំបានទៅស្រាវជ្រាវរកមើលរណ្តៅដែលគេបានយកទៅមនុស្សសម្លាប់នៅទីនោះ គឺឃើញចំនួន ៩កន្លែងនិងផ្លូវនាំចូលព្រៃនិងដើមធ្លកមួយដើមនៅទីនោះដដែល ។

**ស្វ សារឿន**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## សេចក្តីប្រកាសព័ត៌មាន

### សហចៅក្រមស៊ើបអង្កេតបញ្ជូនដីកាដំណោះស្រាយចោទប្រកាន់ឌុច

អនុលោមទៅតាមវិធាន៦៧ នៃវិធានផ្ទៃក្នុង នាថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ នេះ សហចៅក្រមស៊ើបអង្កេតបានបញ្ជូនដីកាដំណោះស្រាយ ចោទប្រកាន់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅឌុច ទៅជំនុំជម្រះពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ (ឧក្រិដ្ឋកម្មសង្គ្រាម) កាលដែលជនជាប់ចោទមានតួនាទីក្នុងមន្ទីរស-២១។

ក្នុងគោលបំណងរក្សាការសម្ងាត់នៃការស៊ើបសួរ ព័ត៌មានមួយចំនួនមិនត្រូវបានបញ្ចូលនៅក្នុងដីកាដំណោះស្រាយដែលដាក់ផ្សាយជាសាធារណៈនេះទេ។ ដីកាដំណោះស្រាយបំលែងនេះមានផ្សាយជាបីភាសាផ្លូវការនៅក្នុងគេហទំព័ររបស់អ.វ.ត.ក www.eccc.gov.kh។

# រស់នៅជាស្ត្រីមេម៉ាយ

លី វ៉ាន់ ជាស្ត្រីមេម៉ាយជនជាតិចាមម្នាក់បានរៀបការជាមួយប្តីទីមួយនៅក្នុងសម័យសង្គមរាស្ត្រនិយមតាមរយៈឪពុកម្តាយជាអ្នករៀបចំទុកដាក់ឲ្យ ។ ចំណែកប្តីទីពីរ គឺខ្មែរក្រហមជាអ្នករៀបចំ ។ ប្តីទីមួយរបស់វ៉ាន់បានស្លាប់បាត់បង់ជីវិតនៅក្នុងសម័យខ្មែរក្រហមដោយសារធ្វើការហួសកម្លាំង និងគ្មានអាហារហូបគ្រប់គ្រាន់ ។ បន្ទាប់មកកូនៗទាំង៥នាក់របស់វ៉ាន់ក៏ស្លាប់ជាបន្តបន្ទាប់ដោយសារជំងឺ និងការបង្អត់បាយ ។ ឪពុកម្តាយ និងបងប្អូនរបស់ វ៉ាន់ ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលជាបន្តបន្ទាប់ដែរ ។ វ៉ាន់ បានស្គាល់ប្តីទីមួយតាមរយៈការរស់នៅជាអ្នកជិតខាងជាមួយគ្នានៅក្នុងភូមិ ។ នៅមុនពេលឪពុកក្មេកគាត់ស្លាប់ បានផ្តាំម្តាយក្មេកថា ប្រសិនបើគាត់ស្លាប់ទៅ សូមស្វែងរកនារីណាម្នាក់ដែលរស់នៅក្បែរផ្ទះមកធ្វើជាកូនប្រសា សូមកុំយកនារីណាដែលនៅតំបន់ឆ្ងាយ ព្រោះនៅពេលគាត់ឈឺយប់ព្រលប់ងាយស្រួលដល់កូន និងកូនប្រសាមកសួរសុខទុក្ខ ។ ម្តាយក្មេករបស់ វ៉ាន់ បានចូលស្តីដណ្តឹង វ៉ាន់ ឲ្យទៅកូនប្រុសរបស់គាត់ដែលជាជនជាតិចាមដូចគ្នា ។ វ៉ាន់ មិនបានប្រកែកតវ៉ាជាមួយឪពុកម្តាយឡើយ ព្រោះការជ្រើសរើសគូស្រករគឺឪពុកម្តាយជាអ្នកសម្រេច ។ ម្យ៉ាងទៀត វ៉ាន់ និងគូដណ្តឹងធ្លាប់រត់លេងជាមួយគ្នាតាំងពីវ័យកុមារម្ល៉េះ ។ អាពាហ៍ពិពាហ៍របស់ វ៉ាន់ បានប្រារព្ធធ្វើទៅតាមពិធីសាសនាឥស្លាម ។ ក្រោយពីរៀបការរួច វ៉ាន់ និងប្តីបានចាប់ដៃគ្នាប្រកបរបរនេសាទត្រី ។ ពេលនោះ នៅក្នុងភូមិមានសភាពច្របូកច្របល់យ៉ាងខ្លាំងដោយសារកងទ័ពខ្មែរក្រហមចូលមកអុកឡុក វ៉ាន់ និងប្តីត្រូវបានចាត់តាំងឲ្យចូលបម្រើកងទ័ព លន់ នល់ ដើម្បីការពារភូមិ និងសម្លាប់ខ្មាំងសត្រូវដោយការងារនេះទទួលបានប្រាក់កម្រៃ៧០រៀលក្នុងមួយខែ ។ ក្រោយមកដោយសារខ្លាចជួបនឹងគ្រោះថ្នាក់ វ៉ាន់ និងប្តីក៏បានរត់ភៀសខ្លួនទៅរស់នៅក្នុងភូមិកោះមនោ ខេត្តកំពង់ឆ្នាំងវិញ ព្រោះនៅទីនោះជាប់បឹងទន្លេសាបអាចប្រកបមុខរបរធ្វើស្រែចម្ការ និងនេសាទបានខ្លះ ។ វ៉ាន់ ខិតខំសន្សំលុយទិញបានកូនទូកមួយសម្រាប់នេសាទត្រីដែលអាចឲ្យគាត់មានលទ្ធភាពចិញ្ចឹមកូនតូចៗបាន ។

នៅឆ្នាំ១៩៧៥ ពេលឃើញកប៉ាល់បើកកាត់មុខផ្ទះគ្រវីទង់ជ័យស វ៉ាន់ គិតថា ប្រទេសជាតិនឹងមានសន្តិភាពហើយ ។ មិនយូរប៉ុន្មានខ្មែរក្រហមក៏បានប្រកាសឲ្យប្រជាជនរៀបចំអីវ៉ាន់ចាកចេញពីផ្ទះរយៈពេលបីថ្ងៃដើម្បីទៅធ្វើបុណ្យ ។ វ៉ាន់ យករបស់របរប្រើប្រាស់ទៅជាមួយបានតែបន្តិចបន្តួចប៉ុណ្ណោះព្រោះជឿថាប្រាកដជាបានត្រឡប់មកផ្ទះវិញ ។ ប៉ុន្តែមិនដូចជាអ្វីដែលគាត់បានគិតទេ សមាជិកគ្រួសាររបស់ វ៉ាន់ ត្រូវខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅជាច្រើនកន្លែង និងបានស្លាប់បាត់បង់ជីវិតជាបន្តបន្ទាប់អស់ចំនួន១៣នាក់ ។ កូនៗរបស់ វ៉ាន់ រស់នៅនិងធ្វើការនៅក្នុងកងចល័តកុមារ ហើយត្រូវបង្ខំឲ្យធ្វើការហួសកម្លាំង ។ នៅចុងឆ្នាំ១៩៧៦ ឪពុកពូ មីង អ៊ំ និងប្អូនៗរបស់ វ៉ាន់ ត្រូវខ្មែរ


បុគ្គលិករបស់មជ្ឈមណ្ឌលកំពុងជួយបំពេញពាក្យបណ្តឹងឲ្យអ្នកភូមិនៅខេត្តកំពង់ឆ្នាំង

ក្រហមយកទៅសម្លាប់ដោយអារ-កនឹងធាងត្នោតរួចទម្លាក់ចូលក្នុងទឹកទន្លេ ។ ចំណែកឯម្តាយរបស់ វ៉ាន់ ស្លាប់ដោយសារពុលស្លឹកឈើព្រៃ ។ ក្រោយមក ប្តីនិងកូនៗរបស់គាត់ក៏ស្លាប់ជាបន្តបន្ទាប់តាមក្រោយដែរ ។ ដោយសារតែមានជីវភាពខ្វះខាតនិងខ្លាចខ្មែរក្រហមធ្វើបាប វ៉ាន់ មិនបានធ្វើបុណ្យឲ្យប្តីនិងសាច់ញាតិដែលបានស្លាប់តាមប្រពៃណីសាសនាឥស្លាមទេ ។ វ៉ាន់ គ្រាន់តែយកស្លឹកឈើគ្របពីលើសាកសព ហើយយកទៅទុកចោលនៅក្នុងព្រៃក្បែរភូមិប៉ុណ្ណោះ ។

បន្ទាប់ពីបាត់បង់ប្តីនិងកូន វ៉ាន់ បានមករស់នៅក្នុងសហករណ៍ជាមួយជនជាតិចាម និងជនជាតិខ្មែរដទៃទៀត ។ គាត់ខិតខំធ្វើការងារដោយមិនហ៊ានប្រកែកតវ៉ាអ្វីឡើយ ។ គាត់យល់ថា ប្រសិនបើគាត់ស្លាប់ទៅប្រាកដជាល្អ ព្រោះគាត់រស់នៅតែម្នាក់ឯងគ្មានញាតិមិត្តទីពឹង និងខ្លាចខ្មែរក្រហមធ្វើទារុណកម្មផង ។ មិនយូរប៉ុន្មានអង្គការបានរៀបចំឲ្យ វ៉ាន់ មានគ្រួសារថ្មីទៀត ។ ដំបូង វ៉ាន់ ប្រកែកមិនព្រមទេព្រោះបុរសនោះជាជនជាតិខ្មែរ ។ ប៉ុន្តែដោយខ្មែរក្រហមចេះតែបន្ទុំនិងព្រួយបារម្ភខ្លាចខ្មែរក្រហមចោទថាប្រឆាំងនឹងអង្គការ គាត់ក៏សុខចិត្តទទួលយកបុរសនោះធ្វើជាស្វាមីទៅ ។

វ៉ាន់ រស់នៅជាមួយគ្នាបានតែមួយថ្ងៃគាត់ក៏បែកបាក់ពីប្តីនៅពេលដែលកងទ័ពវៀតណាមចូលមករំដោះប្រទេស ។ វ៉ាន់ បានសម្រេចចិត្តធ្វើដំណើរជាមួយប្រជាជនផ្សេងៗទៀតមកកាន់ផ្លូវជាតិ ហើយក៏បានស្ម័គ្រចិត្តចូលបម្រើកងទ័ពវៀតណាមដើម្បីប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហម ។ រយៈពេល៣ខែក្រោយមក គាត់ក៏បានជួបជាមួយបងស្រីដែលបែកគ្នាក្នុងសម័យខ្មែរក្រហម ។ បងស្រីរបស់ វ៉ាន់ បានប្រាប់គាត់ឲ្យឈប់ធ្វើទ័ព ហើយត្រឡប់មករស់នៅភូមិកំពង់ហ្លួង ដើម្បីប្រកបរបរនេសាទត្រីវិញ ។ នៅទីនោះ វ៉ាន់ បានជួបជាមួយប្តីម្តងទៀត ហើយក៏បានរៀបការទៅតាមប្រពៃសាសនាឥស្លាមវិញ ។

សព្វថ្ងៃ វ៉ាន់ នៅសល់កូន២នាក់ ចំណែកកូន២នាក់ទៀតស្លាប់ដោយសារលង់ទឹកនៅពេលហែលឆ្លងទន្លេ ។ នៅឆ្នាំ១៩៩៣ ប្តីរបស់ វ៉ាន់ ក៏បានស្លាប់ដោយសារជំងឺស្ទូត ។ វ៉ាន់ រស់នៅជាមួយកូននិងរកស៊ីជួសមងនិងលក់ខោអាវបន្តិចបន្តួចដើម្បីចិញ្ចឹមជីវិត ។ ទោះបីជារបបនេះបានកន្លងផុតទៅរយៈពេលជាង៣០ឆ្នាំហើយក៏ដោយ វ៉ាន់ នៅតែមានកំហឹងចង់សងសឹកដោយផ្ទាល់ដៃចំពោះអ្នកដែលបានសម្លាប់ឪពុករបស់គាត់ដើម្បីរំសាយកំហឹង ព្រោះអ្នកទាំងនោះរស់នៅក្នុងឃុំជាមួយគ្នាគាត់សព្វថ្ងៃ ។ ប៉ុន្តែតាមគម្ពីរសាសនាឥស្លាម វ៉ាន់ មិនអាចសម្លាប់អ្នកទាំងនេះបានទេព្រោះមានបាប ។ វ៉ាន់ បន្ថែមទៀតថា ប្រជាជនចាមខំថ្វាយបង្គំ៥ដងក្នុងមួយថ្ងៃដើម្បីសាងបុណ្យកុំឲ្យមានបាប ។ ដោយសាររឿងរ៉ាវនេះកន្លងផុតទៅយូរឆ្នាំហើយ គាត់ក៏រសាយកំហឹងបានខ្លះ ។ ប៉ុន្តែចុងក្រោយ វ៉ាន់ ចង់ចូលរួមមើលការកាត់ទោសមេខ្មែរក្រហមដោយផ្ទាល់ភ្នែក ដើម្បីឲ្យដឹងថាតើអ្នកណាជាមេឃាតករដែលបញ្ជាឲ្យយកឪពុកគាត់និងសាច់ញាតិរបស់គាត់ទៅសម្លាប់ចោល ។

**ប៊ុន ពីរ័ន**

# ដំណឹងស្វែងរកបងប្រុស

នាងខ្ញុំឈ្មោះ ប៊ុន ឡាម៉ៃ សព្វថ្ងៃរស់នៅទីក្រុងហុងកុង សូមស្វែងរកបងប្រុសឈ្មោះ ប៊ុន ឡាទោត ដែលបានបែកគ្នានៅចុងឆ្នាំ១៩៧៥ កាលពីអាយុ១៦ឆ្នាំ ក្នុងភូមិដងអៀន ស្រុកអារញ្ញប្រាថេត ខេត្តសាកែវ ប្រទេសថៃ ក្បែរព្រំប្រទល់ប្រទេសខ្មែរនៃខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះ ប៊ុនឡា ប៊ុតស៊ី (នៅរស់) និងម្តាយឈ្មោះ ប៊ុន ឡាតឿ (នៅរស់) ។ ខ្ញុំបាទមានបងប្អូនបួននាក់ បងទី១) ប៊ុន ឡាទោត (បាត់ខ្លួន), បងទី២) ប៊ុន ឡាអាត (នៅរស់), បងទី៣) ប៊ុន ឡាលេត (នៅរស់) និងបងទី៤) ប៊ុន ឡាឡៃ (នៅរស់) ។


ប៊ុន ឡាទោត

ប្រសិនបើបងប្អូនណាស្គាល់ឈ្មោះ ប៊ុន ឡាទោត នេះ សូមទំនាក់ទំនងមកទូរស័ព្ទលេខ ០១២ ១៨៣៧ ៣៥៨ ដែលមានអសយដ្ឋានផ្ទះលេខ៣៩AEo ផ្លូវលេខ២៨២ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ យើងខ្ញុំនឹងមានជូនជាសគុណ ។




ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ⬥ Preah Sihanouk Blvd ⬥ Phnom Penh ⬥ Cambodia ⬥ Tel: (855) 23 211 875 ⬥ Fax: (855) 23 210 358 ⬥ dccam@online.com.kh ⬥ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ⬥ Number 103, July 2008 ⬥ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.